

# របាយការណ៍ប្រចាំឆ្នាំ

# ២០២២

# ធនាគារដៃគូល្អបំផុតសម្រាប់

## សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា



**លោកស្រី ភោគ ហឿង**
ម្ចាស់ សិប្បកម្មហ្គោលដិន យេម

គម្រោងហិរញ្ញប្បទាន
**សហគ្រិនស្ត្រី (CWES)**
អត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី
**5.5%**



គម្រោងហិរញ្ញប្បទាន
**វិស័យឌីជីថល និងទំនើបកម្ម (CDAS)**
អត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី
**5.88%**



**លោក សុង ខេងលាន**
ម្ចាស់ សហគ្រាស ស៊ី អេស អិល

គម្រោងហិរញ្ញប្បទាន
**សហគ្រាសធុនតូច និងមធ្យម (CSS)**
អត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី
**5.88%**



គម្រោងហិរញ្ញប្បទាន
សហគ្រាសធុនតូច (CMES)
**ជាគម្រោងហិរញ្ញប្បទាន**
**គ្មានទ្រព្យធានា**
អត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី
**7.50%**

# មាតិកា

## អំពីធនាគារ

សារពីប្រធានក្រុមប្រឹក្សាភិបាល ........................ ៦
សារពីអគ្គនាយក ........................................ ៨
សារតាធនាគារ ........................................ ១០
របាយការណ៍សម្រេចបានឆ្នាំ២០២២ ............... ១២
បណ្តាញសាខា ........................................ ១៣
វឌ្ឍនភាព ................................................ ១៤
ដៃគូទូទាត់សាច់ប្រាក់ .................................. ១៦
ស្ថាប័នដៃគូយុទ្ធសាស្ត្រ ................................ ១៧

## លទ្ធផលអាជីវកម្ម

គម្រោងសហហិរញ្ញប្បទាន ............................ ១៩
គម្រោងហិរញ្ញប្បទានដោយផ្ទាល់ .................... ២១
មតិពីអតិថិជន ........................................ ២២

## ព្រឹត្តិការណ៍

កិច្ចប្រជុំប្រចាំឆ្នាំ២០២២ .............................. ២៤
កម្មវិធីទទួលស្គាល់បុគ្គលិកឆ្នើមប្រចាំឆ្នាំ២០២២ ... ២៥
ព្រឹត្តិការណ៍សំខាន់ៗ .................................. ២៦
អនុស្សរណៈ នៃការយោគយល់
ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម ..................... ៣៦

## អភិបាលកិច្ចសាជីវកម្ម

រចនាសម្ព័ន្ធធនាគារ .................................. ៣១
ក្រុមប្រឹក្សាភិបាល ...................................... ៣៤
គណៈគ្រប់គ្រងជាន់ខ្ពស់ .............................. ៣៧
អភិបាលកិច្ចសាជីវកម្ម ................................ ៣៩
កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ............................ ៤០
គណៈកម្មការគ្រប់គ្រងហានិភ័យ
និងប្រតិបត្តិតាម ........................................ ៤១
គណៈកម្មការសវនកម្ម .................................. ៤៤
គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ ............ ៤៦

## របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ .................................. ៤៨

# សារពីប្រធានក្រុមប្រឹក្សាភិបាល



> “ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា គឺជាធនាគារគោលនយោបាយ ដែលបានបង្កើតឡើងក្រោមការដឹកនាំដ៏វៃឆ្លាតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីជួយគាំទ្រទៅដល់សហគ្រាសធុនតូច និងមធ្យម ដែលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ និងសហគ្រាសទើបបង្កើតថ្មី ដែលមានតម្រូវការគាំទ្រផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេស។”

តាងនាមឲ្យធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និងក្រុមប្រឹក្សាភិបាល ខ្ញុំពិតជាមានកិត្តិយស និងសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញជូនលោកអ្នកនូវរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារ សម្រាប់ឆ្នាំសារពើពន្ធដែលបញ្ចប់នៅឆ្នាំ២០២២។

ស្ថានភាពសេដ្ឋកិច្ច និងពាណិជ្ជកម្ម លើសកលលោកនៅមានកំណើនយឺត ទោះបីជាជំងឺកូវីដ-១៩ បានថមថយនៃការរីករាលដាល ប៉ុន្តែវិបត្តិសង្គ្រាមរបស់ប្រទេសរុស្ស៊ី ជាមួយប្រទេសអ៊ុយក្រែន នៅតែបន្តអូសបន្លាយ ដែលបានជះឥទ្ធិពលទៅដល់សេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងប្រទេសនៅអាស៊ីអាគ្នេយ៍ផងដែរ។

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានចាប់ផ្តើមងើបឡើងវិញតាំងពីឆ្នាំ២០២១មក ដោយមានការគាំទ្រពីវិស័យពាក់ព័ន្ធផ្សេងៗ ប៉ុន្តែប្រទេសកម្ពុជានៅតែប្រឈមមុខនឹងឧបសគ្គច្រើនទៀតនៅក្នុងការស្តារសេដ្ឋកិច្ចឡើងវិញ។ សហគ្រាសតូច ធំជាច្រើននៅមិនទាន់ដំណើរការរលូន ម្ចាស់សហគ្រាសមួយចំនួននៅមានកង្វះខាតធនធាន ផលិតផលគាំទ្រ ដើមទុន និងអត្រាអតិផរណា។ ស្ថានភាពបែបនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើនដើម្បីបន្តការស្តារឡើងវិញនូវគ្រប់វិស័យដូចជា ក្របខណ្ឌគោលនយោបាយសង្គមសេដ្ឋកិច្ចឌីជីថលកម្ពុជា ២០២១-២០៣៥, ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣។

ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា គឺជាធនាគារគោលនយោបាយ ដែលបានបង្កើតឡើងក្រោមការដឹកនាំដ៏វៃឆ្លាតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយគាំទ្រទៅដល់សហគ្រាសធុនតូច និងមធ្យម ដែលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ និងសហគ្រាសទើបបង្កើតថ្មី ដែលមានតម្រូវការគាំទ្រផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេស។ ធនាគារបានដាក់ចេញនូវគម្រោងហិរញ្ញប្បទានជាច្រើន ដើម្បីជួយសម្រួលដល់សហគ្រាសធុនតូច និងមធ្យម ឲ្យស្របទៅតាមតម្រូវការ ដោយផ្តល់ជូននូវលក្ខខណ្ឌអនុគ្រោះ និងអត្រាការប្រាក់ទាប។ គិតត្រឹមដំណាច់ឆ្នាំ២០២២ នេះ ធនាគារបានចូលរួមផ្តល់ហិរញ្ញប្បទាន ជូនដល់សហគ្រាសធុនតូច និងមធ្យម តាមរយៈការផ្តល់ឥណទានដោយផ្ទាល់ចំនួន ២៣១ សហគ្រាស ដែលមានសហគ្រិនជាស្ត្រីចំនួន ៦២ សហគ្រាស និងសហគ្រិនជាបុរសចំនួន ១៦៩ សហគ្រាស ជាមួយទំហំទឹកប្រាក់ឥណទានសរុបប្រមាណជា ៥៣,៤ លានដុល្លារអាមេរិក និងការផ្តល់ឥណទានតាមគម្រោងសហហិរញ្ញប្បទាន ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម ដែលបានផ្តល់ការគាំទ្រដល់សហគ្រាសសរុបចំនួន ៣ ០៣៧ ស្មើនឹងទំហំទឹកប្រាក់សរុបប្រមាណជា ៣៨០ លានដុល្លារអាមេរិក។

ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា ធនាគារនៅតែបន្តអនុវត្ត និងខិតខំជួយជំរុញសហគ្រាសធុនតូច និងមធ្យមទាំងអស់ឲ្យបានរីកលូតលាស់ ដើម្បីជួយស្តារសេដ្ឋកិច្ចជាតិឲ្យបានរីកចម្រើនប្រកបដោយចីរភាព។

ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ សូមថ្លែងអំណរគុណ យ៉ាងស្មោះស្ម័គ្រចំពោះអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដែលបានខិតខំប្រឹងប្រែងមិនចេះនឿយហត់ក្នុងការគាំទ្រដល់ការរីកចម្រើន និងវឌ្ឍនភាពរបស់ធនាគារ។ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះអតិថិជនជាទីរាប់អានរបស់យើងដែលបានជឿទុកចិត្តមកលើធនាគារ សូម្បីតែក្នុងអំឡុងពេលជំងឺរាតត្បាតជាសកល។ យើងប្តេជ្ញានឹងធ្វើជាដៃគូដែលមានទំនុកចិត្ត និងបន្តផ្តល់ហិរញ្ញប្បទានជូនចំពោះសហគ្រាសទាំងអស់ ដែលនៅតែមានតម្រូវការហិរញ្ញវត្ថុ ដើម្បីភាពរីកលូតលាស់អាជីវកម្មរបស់ពួកគាត់។

**បណ្ឌិត ផាន់ ផល្លា**
ប្រធានក្រុមប្រឹក្សាភិបាល

# សារពីអគ្គនាយក




**ជូនចំពោះអតិថិជន និងសាធារណជនជាទីគោរពរាប់អាន**

ទោះបីជាពិភពលោកបានទទួលរងនូវបញ្ហាប្រឈមពីការរីករាលដាលនៃជំងឺរាតត្បាត និងវិបត្តិមួយចំនួន ដែលនាំឲ្យប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ចសកល និងប្រទេសកម្ពុជា ក៏ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា (“ធនាគារ”) នៅតែបន្តបេសកកម្មរបស់ខ្លួនយ៉ាងសកម្មដើម្បីគាំទ្រដល់កំណើន និងការអភិវឌ្ឍរបស់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។ ធនាគារបានបន្តប្តេជ្ញាចិត្តក្នុងការផ្តល់ហិរញ្ញប្បទាន ប្រកបដោយប្រសិទ្ធភាពជូនដល់ម្ចាស់សហគ្រាសដែលគាំទ្រវិស័យអាទិភាព ដើម្បីចូលរួមចំណែកក្នុងការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ស្របតាមក្របខណ្ឌយុទ្ធសាស្រ្ត និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣។

នៅក្នុងឆ្នាំ២០២២ ធនាគារបានបន្តយកចិត្តទុកដាក់លើការពង្រីកបណ្តាញចែកចាយឲ្យកាន់តែទូលំទូលាយដូចជា៖ (១). ធនាគារបានធ្វើការផ្លាស់ប្តូរការិយាល័យកណ្តាលរបស់ខ្លួនមកកាន់អគារ “មជ្ឈមណ្ឌលអភិវឌ្ឍន៍ធុរកិច្ច” ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលជាទីតាំងធំទូលាយជាងមុន និងមានស្ថាប័នចម្រុះជាច្រើននៅជួយគាំទ្រដល់សហគ្រិនទាំងផ្នែកបច្ចេកទេស, ហិរញ្ញវត្ថុ និងការអភិវឌ្ឍធនធានមនុស្ស, (២). ធនាគារបានដាក់ឲ្យដំណើរការជាផ្លូវការនូវសាខាថ្មីចំនួន ២ បន្ថែមទៀត ពោលគឺ សាខាផ្សារថ្មី និងសាខាខេត្តបាត់ដំបង ដើម្បីផ្តល់ភាពងាយស្រួលទៅដល់ម្ចាស់សហគ្រាសធុនតូច និងមធ្យម ដែលត្រូវការការគាំទ្រផ្នែកហិរញ្ញវត្ថុ, (៣). ធនាគារក៏បានអភិវឌ្ឍបន្ថែមនូវដៃគូអាជីវកម្មមួយចំនួនទៀត ដែលរួមមាន៖ សមាគមថ្នាលធុរកិច្ច, ធនាគារពាណិជ្ជ, ក្រុមហ៊ុនសេវាទូទាត់, ក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ, ស្ថាប័នសាធារណៈក្នុងស្រុក និងអន្តរជាតិ ដើម្បីពង្រីកវិសាលភាពនៃការផ្តល់សេវាកម្មឲ្យកាន់តែទូលំទូលាយ និងខិតកាន់តែជិតអតិថិជនគោលដៅ។ លើសពីនេះ ធនាគារបានដាក់ចេញនូវផែនការច្បាស់លាស់សម្រាប់ការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្នាលឌីជីថល ឲ្យកាន់តែទំនើបដើម្បីធ្វើឲ្យប្រសើរឡើងនូវបទពិសោធន៍នៃការប្រើប្រាស់សេវាកម្មពីសំណាក់អតិថិជនឲ្យកាន់តែមានប្រសិទ្ធភាព និងចំណេញពេលវេលា ស្របតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថល និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥។

ដើម្បីពន្លឿនការផ្តល់ហិរញ្ញប្បទានឲ្យមានប្រសិទ្ធភាពខ្ពស់ ធនាគារបានធ្វើការកែសម្រួលនិយមន័យសហគ្រាសធុនតូច និងមធ្យម ឲ្យសមស្របនឹងការវិវឌ្ឍនៃសង្គម-សេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងបានបង្កើនទំហំឥណទានអតិបរមាពី ៥០០,០០០ ដុល្លារអាមេរិក ទៅ ១,០០០,០០០ ដុល្លារអាមេរិក សម្រាប់អតិថិជនម្នាក់។ ជាងនេះទៀត ធនាគារក៏បានដាក់ចេញនូវគម្រោងហិរញ្ញប្បទានគ្មានទ្រព្យធានា និងហិរញ្ញប្បទានវិបារូបន៍ ដែលបានផ្តល់នូវជម្រើសបន្ថែមដល់សហគ្រាសគោលដៅក្នុងការប្រើប្រាស់ឲ្យស្របតាមគោលបំណង និងប្រភេទអាជីវកម្មជាក់ស្តែង។

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០២២ នេះ ធនាគារសម្រេចបានទ្រព្យសកម្មសរុបចំនួន ២៨១ លានដុល្លារអាមេរិក ដែលកើនលើសពីឆ្នាំ២០២១ ចំនួន ១៣១ លានដុល្លារអាមេរិក ក្នុងនោះសមតុល្យឥណទានសរុបមានចំនួន ២១៤ លានដុល្លារអាមេរិក។ ទន្ទឹមនេះ នៅខែកញ្ញា ឆ្នាំ២០២២ ធនាគារបានបញ្ចប់ដោយជោគជ័យនូវគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ជំហានទី២ ដែលបានផ្តល់ការគាំទ្រដល់សហគ្រាសសរុបចំនួន ១ ៩៩២ ស្មើនឹងទំហំទឹកប្រាក់សរុប ២៤០ លានដុល្លារអាមេរិក (១២០ លានដុល្លារអាមេរិក បានមកពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ធនាគារ និង ១២០ លានដុល្លារអាមេរិកផ្សេងទៀត បានមកពីគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម)។ មិនតែប៉ុណ្ណោះ ធនាគារ ក៏បានរៀបចំ និងដាក់ឲ្យដំណើរការគម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍ នូវចំនួនទឹកប្រាក់សរុប ១៥០ លានដុល្លារអាមេរិក (៧៥ លានដុល្លារអាមេរិក បានមកពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ធនាគារ និង ៧៥ លានដុល្លារអាមេរិក ផ្សេងទៀត បានមកពីគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម) ដែលគិតត្រឹមខែធ្នូ ឆ្នាំ២០២២ មានសហគ្រាសសរុបចំនួន ២៩១ និងកំពុងប្រើប្រាស់ហិរញ្ញប្បទានសរុបចំនួន ៤១,៥២ លានដុល្លារអាមេរិក ដែលស្មើនឹង ២៧.៦៨% នៃគម្រោងថវិកាសរុប។

ផែនការយុទ្ធសាស្រ្តសំខាន់សម្រាប់ឆ្នាំបន្ទាប់ រួមមាន៖ (១). ធ្វើការកែលម្អ និងអភិវឌ្ឍផលិតផល និងសេវាកម្មឲ្យកាន់តែល្អប្រសើរ ដើម្បីឆ្លើយតប នឹងតម្រូវការរបស់អតិថិជនគោលដៅ, (២). បន្តអភិវឌ្ឍបណ្តាញចែកចាយដូចជាសាខា៖ ដៃគូអាជីវកម្ម, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ថ្នាលឌីជីថល ដែលជាចំណុចតភ្ជាប់យ៉ាងទូលំទូលាយ និងខិតឲ្យនៅជិតអតិថិជនគោលដៅ, (៣). អភិវឌ្ឍធនធានមនុស្សឲ្យមានចំណេះ និងជំនាញគ្រប់គ្រាន់ដែលធានាបាននូវប្រសិទ្ធភាព និងតម្លាភាពការងារ, និង (៤). រៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងហានិភ័យ និងវប្បធម៌គ្រប់គ្រងហានិភ័យ ឲ្យកាន់តែល្អប្រសើរ។

សមិទ្ធផលទាំងអស់នេះ ទទួលបានតាមរយៈការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ព្រមទាំងកិច្ចសហប្រតិបត្តិការ របស់អាជ្ញាធរមានសមត្ថកិច្ចជាពិសេស ធនាគារជាតិ នៃ កម្ពុជា ដែលជាអាណាព្យាបាល លើសពីនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអតិថិជន ក្រុមប្រឹក្សាភិបាល ថ្នាក់គ្រប់គ្រង និងបុគ្គលិក ព្រមទាំងដៃគូអាជីវកម្មដែលតែងតែផ្តល់ការគាំទ្រចំពោះធនាគារដើម្បីបានសម្រេច នូវលទ្ធផលស្របតាមផែនការ ជាពិសេសក្នុងឆ្នាំ២០២២។



**បណ្ឌិត លឹម អួន**
អគ្គនាយក និងជាអភិបាល

# សារតាធនាគារ




សហគ្រាសធុនតូច និងមធ្យម (SMEs) គឺជាកត្តាជំរុញដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ចក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដូចជាកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ សហគ្រាសធុនតូច និងមធ្យមមួយចំនួនកំពុងជួបនូវបញ្ហាប្រឈម ក្នុងការទទួលបានសេវាហិរញ្ញវត្ថុដែលមានតម្លៃសមរម្យដោយសារតម្រូវការទ្រព្យធានា និងអត្រាការប្រាក់ខ្ពស់។ ដោយមានកត្តាប្រឈមទាំងនេះ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក នេះឡើង។

ធនាគារ ទទួលបានអាជ្ញាបណ្ណផ្លូវការជាធនាគារពាណិជ្ជពីធនាគារជាតិ នៃ កម្ពុជា (“NBC”) កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០។ ជាមួយគ្នានេះដែរ ធនាគារស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (“MEF”)។ ទន្ទឹមនេះ គោលបំណង និងទិសដៅចម្បងរបស់ធនាគារ គឺការផ្តល់ហិរញ្ញប្បទានប្រកបដោយប្រសិទ្ធភាព និងចីរភាពដើម្បីគាំទ្រសហគ្រាសធុនតូច និងមធ្យម សំដៅជំរុញពិពិធកម្មសេដ្ឋកិច្ច និងការនាំចេញស្របតាមគោលនយោបាយដែលបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា។

វត្តមានរបស់ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា នៅក្នុងប្រទេសកម្ពុជានារយៈពេលជិត ៣ឆ្នាំកន្លងមក ត្រូវបានសាធារណជនទទួលស្គាល់ជា ធនាគារគោលនយោបាយ ដែលកំពុងផ្តល់ហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ និងជួយទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ដោយផ្តោតលើវិស័យអាទិភាពរួមមាន ការកែច្នៃម្ហូបអាហារ, ការផលិតទំនិញប្រើប្រាស់ និងគ្រឿងបន្លាស់, ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន, ការផលិតឧបករណ៍វេជ្ជសាស្ត្រ និងឱសថ, និងវិស័យគាំទ្រផ្សេងៗទៀត។ បច្ចុប្បន្ន ធនាគារផ្តោតសំខាន់ទៅលើការអនុវត្តគម្រោងសហហិរញ្ញប្បទាន ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIs) និងការផ្តល់ហិរញ្ញប្បទានដោយផ្ទាល់។





## បេសកកម្ម

ផ្តល់ហិរញ្ញប្បទាន និងសេវាធនាគារពាណិជ្ជប្រកបដោយប្រសិទ្ធភាព និងចីរភាព ដើម្បីគាំទ្រសហគ្រាសធុនតូច និងមធ្យម សំដៅជំរុញពិពិធកម្មសេដ្ឋកិច្ច និងការនាំចេញស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

## ចក្ខុវិស័យ

ជាធនាគារជម្រើសដំបូង និងល្អបំផុតសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ក្នុងការទទួលបានសេវាកម្មហិរញ្ញវត្ថុដែលមានតម្លៃសមស្រប, ងាយស្រួលក្នុងការទទួលបានហិរញ្ញប្បទាន, ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងការបម្រើសេវាកម្មល្អ។

## គុណតម្លៃ

### ទំនួលខុសត្រូវ

យើងមានទំនួលខុសត្រូវខ្ពស់ និងប្រកបដោយវិជ្ជាជីវៈ ចំពោះអ្នកពាក់ព័ន្ធក្នុងអាជីវកម្ម និងទៅលើតួនាទី ក៏ដូចជាមុខងារដែលយើងបានកំណត់។

### បុគ្គលិក

យើងចាត់ទុកគ្រប់បុគ្គលិកជាទ្រព្យដ៏សំខាន់ ហើយគោរព ផ្តល់តម្លៃ និងផ្តល់ឱកាសឲ្យពួកគាត់ចូលរួមយ៉ាងសកម្មក្នុងដំណើរការអាជីវកម្មរបស់យើង។

### អតិថិជន

ដោយសារតែអតិថិជន ជាគោលដៅចម្បងសម្រាប់ការអភិវឌ្ឍអាជីវកម្មរបស់យើង នោះយើងនឹងផ្តល់ជូនសេវាកម្មដ៏ល្អឥតខ្ចោះ។

### សច្ចៈភាព

លើកកម្ពស់សច្ចៈភាពក្នុងអត្តសញ្ញាណរបស់យើង ដើម្បីធានាឲ្យបាននូវកេរ្តិ៍ឈ្មោះ និងទំនុកចិត្តខ្ពស់ក្នុងអាជីវកម្ម។

### ប្រសិទ្ធភាព

យើងខិតខំប្រឹងប្រែងសម្រាប់ប្រតិបត្តិការដ៏ល្អ ដើម្បីប្រាកដថាម្ចាស់ភាគហ៊ុនទាំងអស់ទទួលបានប្រាក់ចំណេញភាពរីកចម្រើន និងស្ថេរភាពអាជីវកម្ម។

# របាយការណ៍សម្រេចបានឆ្នាំ២០២២

ចំនួន
អតិថិជនសរុប

+៣,២០០

សមតុល្យ
ហិរញ្ញប្បទាន

លានដុល្លារអាមេរិក

+២១៤

ទ្រព្យសកម្ម

លានដុល្លារអាមេរិក

២៨១

ចំនួនអតិថិជនជាស្ត្រី

+២៤%

ហិរញ្ញប្បទានក្នុង
វិស័យអាទិភាព

+៥១%

ចំនួនបុគ្គលិកសរុប

+១៣៨

ចំនួនសាខា

៣

ចំនួនដៃគូ

១០

មូលធនធនាគារ
(លានដុល្លារអាមេរិក)

| ២០២០ | ២០២១ | ២០២២ |
|---|---|---|
| ១០០ | ១៤៨ | ១៩៩ |

ទ្រព្យសកម្មសរុប
(លានដុល្លារអាមេរិក)

| ២០២០ | ២០២១ | ២០២២ |
|---|---|---|
| ១០០ | ១៥០ | ២៨១ |



# បណ្តាញសាខា





**ទីស្នាក់ការកណ្តាល**

**អគារ "មជ្ឈមណ្ឌលអភិវឌ្ឍន៍ធុរកិច្ច"**
ជាន់ផ្ទាល់ដី និងជាន់ទី២០
ផ្លូវអូស៊ីអាយស៊ី ខណ្ឌជ្រោយចង្វារ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា



**សាខាផ្សារថ្មី**

អគារលេខ ៣០ ផ្លូវប៉ាស្ទ័រ កែងផ្លូវព្រែនគរ
សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា



**សាខាខេត្តបាត់ដំបង**

"ផ្ទះលេខ ១៦១ និង ១៦២ ផ្លូវជាតិលេខ ៥ ក្រុមទី ៦
ភូមិរំចេក ៥ សង្កាត់រតនៈ ក្រុងបាត់ដំបង
ខេត្តបាត់ដំបង ព្រះរាជាណាចក្រកម្ពុជា

# វឌ្ឍនភាព

## ២០២០

- ទទួលបានអាជ្ញាបណ្ណជាធនាគារពាណិជ្ជ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០
- ដាក់ឲ្យដំណើរការគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ជំហានទី ១ ជាមួយគម្រោងទឹកប្រាក់សរុប ១០០ លានដុល្លារអាមេរិក ដោយសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមចំនួន ៣៣ និងបានបញ្ចប់ជាស្ថាពរនៅខែតុលា ឆ្នាំ២០២០
- ដាក់ឲ្យដំណើរការគម្រោងហិរញ្ញប្បទានដោយផ្ទាល់ រួមមាន៖
    - គម្រោងហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យម (CSS)
    - គម្រោងហិរញ្ញប្បទានវិស័យឌីជីថល និងទំនើបកម្ម (CDAS)
    - គម្រោងហិរញ្ញប្បទានសហគ្រិនស្ត្រី (CWES)
    - និងគម្រោងហិរញ្ញប្បទានស្តារសហគ្រាសធុនតូច និងមធ្យម (CRSS)
- សម្រេចបានទ្រព្យសកម្មសរុបជាង **១០០ លានដុល្លារអាមេរិក**

## ២០២១

- ទទួលបានពានរង្វាន់ជា **“ធនាគារឆ្នើមសម្រាប់សហគ្រាសធុនតូច និងមធ្យម ប្រចាំឆ្នាំ២០២១ នៅកម្ពុជា”** ពីស្ថាប័ន Asian Banking & Finance
- ចុះកិច្ចសហប្រតិបត្តិការក្នុងការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម ជាមួយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា, សហគ្រិនខ្មែរ, និងក្រុមហ៊ុនបញ្ជី ហ្វាញថេក ។ល។
- ដាក់ឲ្យដំណើរការគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ជំហានទី២ ជាមួយទំហំទឹកប្រាក់សរុប ២៤០ លានដុល្លារអាមេរិក ដោយសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមចំនួន ២៨ និងបានផ្តល់ហិរញ្ញប្បទានជូនដល់សហគ្រាសចំនួន ៩៨១
- សម្រេចបានទ្រព្យសកម្មសរុបជាង **១៥០ លានដុល្លារអាមេរិក**

## ២០២២

- ដាក់ឲ្យដំណើរការគម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍ ជាមួយ**ទំហំទឹកប្រាក់សរុប ១៥០ លានដុល្លារអាមេរិក** ដោយសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមចំនួន២៤
- បានចូលរួមជាសមាជិកសេវាទូទាត់រហ័ស (Fast Payment) របស់ធនាគារជាតិ នៃ កម្ពុជា ដើម្បីអនុញ្ញាតឲ្យអតិថិជនអាចផ្ទេរប្រាក់ឆ្លងធនាគារបានលឿនទាន់ចិត្ត
- ដាក់ឲ្យដំណើរការគម្រោងហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូចដែលជាគម្រោងហិរញ្ញប្បទានគ្មានទ្រព្យធានា (CMES)
- ដាក់ឲ្យដំណើរការសាខាថ្មីចំនួន ២ បន្ថែមទៀត រួមមានសាខាផ្សារថ្មី និងសាខាខេត្តបាត់ដំបង
- បានអភិវឌ្ឍដៃគូអាជីវកម្មជាមួយនឹងសមាគមសហគ្រាសធុនតូច និងមធ្យម ចំនួន ៥ បន្ថែម ដើម្បីជំរុញការបញ្ចេញឥណទានដោយផ្ទាល់ទៅអតិថិជនគោលដៅ រួមមាន CEO Master Club នៃក្រុមហ៊ុនឡាយហ្វ៍ អេឌ្យូខេសិន ឯ.ក, សមាគមសហគ្រិនវ័យក្មេងកម្ពុជា, ក្រុមហ៊ុន អាហ្វ្រីប៊ី (ខេមបូឌា), សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា, និងសមាគមអ្នកផលិតចំណីអាហារកម្ពុជា
- សម្រេចបាន**ទ្រព្យសកម្មសរុប ជាង ២៨១ លានដុល្លារអាមេរិក**

# ដៃគូទូទាត់សាច់ប្រាក់

ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា មានគោលដៅពង្រីកវិសាលភាពការផ្តល់ហិរញ្ញប្បទានជូនដល់សហគ្រាសធុនតូច និងមធ្យមនៅគ្រប់ខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា។ ដោយយោងលើចំនួនសាខារបស់ធនាគារ និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យានៅមានកម្រិត ធនាគារបាននឹងកំពុងធ្វើការសហការជាមួយស្ថាប័នហិរញ្ញវត្ថុមួយចំនួនក្នុងគោលដៅជួយសម្រួលដល់ការសងត្រឡប់ប្រាក់កម្ចីមកធនាគារវិញតាមរយៈបណ្តាញចែកចាយរបស់ស្ថាប័នដៃគូ។

ធនាគារបានចុះកិច្ចសហប្រតិបត្តិការស្តីពីសេវាហិរញ្ញវត្ថុជាមួយ ធនាគារ ABA និងក្រុមហ៊ុន ទ្រូម៉ាន់នី (ខេមបូឌា) ដើម្បីផ្តល់លទ្ធភាពឲ្យអតិថិជនរបស់ខ្លួនអាចធ្វើប្រតិបត្តិការសងត្រឡប់ហិរញ្ញប្បទាន តាមរយៈសេវាធនាគារតាមទូរស័ព្ទដៃ នៃធនាគារ ABA, ភ្នាក់ងារទ្រូម៉ាន់នី ចំនួនជាង ១១ 000 ទីតាំងនៅទូទាំងប្រទេស និង TrueMoney Wallet ជាដើម។ កិច្ចសហប្រតិបត្តិការនេះនឹងផ្តល់ជូនបទពិសោធន៍ប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុប្រកបដោយសុវត្ថិភាព និងភាពងាយស្រួល។








# ស្ថាប័នដៃគូយុទ្ធសាស្ត្រ





# លទ្ធផលអាជីវកម្ម

ក្នុងឆ្នាំ២០២២ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា មានកំណើនហិរញ្ញប្បទាន ៩៣% ពី ១១១ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ ដល់ ២១៤ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២២ ទោះបីជាកំណើនសេដ្ឋកិច្ចពិភពលោកស្ថិតក្នុងស្ថានភាពធ្លាក់ចុះក៏ដោយ។ កំណើនហិរញ្ញប្បទាន បានពីការចូលរួមចំណែករបស់គម្រោងសំខាន់ចំនួនពីរគឺ គម្រោងសហហិរញ្ញប្បទាន និងគម្រោងហិរញ្ញប្បទានដោយផ្ទាល់។ ហិរញ្ញប្បទាន ក្នុងគម្រោងសហហិរញ្ញប្បទានត្រូវបានកើនឡើង ៥៨% ពី ៩៦ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ ធៀបនឹង ១៥២ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២២។ លើសពីនេះគម្រោងហិរញ្ញប្បទានដោយផ្ទាល់ មានការកើនឡើងគួរឲ្យកត់សម្គាល់ ដែលឥណទានក្នុងគម្រោងនេះមានចំនួន ៤ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ ដល់ ៥៣ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២២។ លើសពីនេះ គោលដៅចម្បងរបស់ធនាគារ គឺផ្ដល់ហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះដល់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យផលិត និងកែច្នៃម្ហូបអាហារ ក៏ដូចជាវិស័យផ្សេងៗទៀត។ ធនាគារបានផ្ដល់ហិរញ្ញប្បទានដោយផ្ទាល់ដល់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យផលិត និងកែច្នៃ ៤៦% ក្នុងឆ្នាំ២០២២ តាមរយៈគម្រោងហិរញ្ញប្បទានសហគ្រាសធុនតូច និង មធ្យម (CSS) គម្រោងហិរញ្ញប្បទានសហគ្រិនស្ត្រី (CWES) គម្រោងហិរញ្ញប្បទានវិស័យឌីជីថល និងទំនើបកម្ម (CDAS) និងគម្រោងហិរញ្ញប្បទានសហគ្រាសធុនតូច (CMES)។





# គម្រោងសហហិរញ្ញប្បទាន

## គម្រោងសហហិរញ្ញប្បទានស្ដារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍

គម្រោងសហហិរញ្ញប្បទានស្ដារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍ (TRCS) គឺជាផ្នែកមួយនៃការគាំទ្រសម្រាប់ការអនុវត្ត “ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្ដារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣”។

ដើម្បីលើកកម្ពស់ និងពង្រឹងវិស័យទេសចរណ៍ឲ្យងើបឡើងវិញ រាជរដ្ឋាភិបាលបានសម្រេចអនុវត្តគម្រោងនេះ ដើម្បីដោះស្រាយបញ្ហាកង្វះហិរញ្ញប្បទានសម្រាប់អាជីវកម្មទាក់ទងនឹងវិស័យទេសចរណ៍។

គម្រោង TRCS នឹងគាំទ្រ (ក). ដំណើរការអាជីវកម្មឡើងវិញ (ខ). ការកែលម្អ និងទំនើបកម្ម និង (គ). ការពង្រឹង និងធ្វើពិពិធកម្មសេវាកម្មទេសចរណ៍ ដើម្បីរៀបចំសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិក្នុងវិបត្តិក្រោយកូវីដ-១៩។

គម្រោង TRCS ត្រូវបានផ្ដួចផ្ដើមបង្កើតឡើងនៅខែកក្កដា ឆ្នាំ២០២២ ជាមួយនឹងថវិកាសរុបចំនួន ១៥០ លានដុល្លារអាមេរិក ដែលជាសហហិរញ្ញប្បទានរវាងរាជរដ្ឋាភិបាលកម្ពុជា និងគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម។

គិតត្រឹមចុងខែធ្នូ ឆ្នាំ២០២២ គ្រឹះស្ថានហិរញ្ញវត្ថុចូលរួមមានចំនួន ២៤ កំពុងចូលរួមក្នុងគម្រោង TRCS។ គម្រោងនេះត្រូវបានផ្ដល់ហិរញ្ញប្បទានដល់សហគ្រាសប្រមាណ ២៩១ រួមមានអាជីវកម្មសណ្ឋាគារ ៥០, អាជីវកម្មផ្ទះសំណាក់ ៩៧ អាជីវកម្មភោជនីយដ្ឋាន ១២០, អាជីវកម្មគាំទ្រដល់វិស័យទេសចរណ៍ ៥១ ជាមួយនឹងទំហំហិរញ្ញប្បទានសរុបប្រមាណ ៤១.៥២ លានដុល្លារអាមេរិក។

### វឌ្ឍនភាពគម្រោងសហហិរញ្ញប្បទានស្ដារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍

គម្រោងថវិកាសរុប
150 លាន ដុល្លារអាមេរិក

ឥណទានបានបញ្ចេញ
41.52 លាន ដុល្លារអាមេរិក

291 សហគ្រាសដែលទទួលបានឥណទាន

26% អាជីវកម្មសណ្ឋាគារ

28% អាជីវកម្មផ្ទះសំណាក់

32% អាជីវកម្មភោជនីយដ្ឋាន

14% អាជីវកម្មគាំទ្រវិស័យទេសចរណ៍

43% សហគ្រិនស្ត្រី

## គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ជំហានទី២

គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ជំហានទី២ (“SCFS II”) បានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់សហគ្រាសធុនតូច និង មធ្យមដែលរងផលប៉ះពាល់ដោយកូវីដ-១៩ ដើម្បីចាប់ផ្តើមអាជីវកម្មរបស់ពួកគេឡើងវិញស្របតាមផែនការស្តារឡើងវិញក្នុងអំឡុងពេល និងក្រោយ កូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា និងដើម្បីរួមចំណែកដល់ការស្តារសេដ្ឋកិច្ចឡើងវិញ។

SCFS II ត្រូវបានផ្តួចផ្តើមឡើងក្នុងខែសីហា ឆ្នាំ២០២១ ជាមួយនឹងថវិកាសរុបចំនួន ២៤០ លានដុល្លារអាមេរិក ដែលជាថវិកាបដិភាគរវាងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និង គ្រឹះស្ថានហិរញ្ញវត្ថុចូលរួមចំនួន ៣២។ គម្រោងនេះត្រូវបានបញ្ចប់នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ ដោយផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យមចំនួន ១៩៩២ សហគ្រាស ដែលក្នុងនោះមានវិស័យអាទិភាពចំនួន ៤២%, វិស័យទូទៅមាន ៥៨%, និងសហគ្រិនស្ត្រី ៣០%។

### សមិទ្ធផលសម្រេចបាន

**គម្រោងថវិកាសរុប**
**240** លានដុល្លារអាមេរិក

**ឥណទានបានបញ្ចេញ**
**239.97** លានដុល្លារអាមេរិក

**1,992** សហគ្រាសដែលទទួលបានឥណទាន

| 42% | 58% | 30% |
|---|---|---|
| វិស័យអាទិភាព | វិស័យទូទៅ | សហគ្រិនស្ត្រី |



# គម្រោងហិរញ្ញប្បទានដោយផ្ទាល់

ធនាគារបានដំណើរការស្របតាមបេសកកម្មរបស់ខ្លួនក្នុងការគាំទ្រគោលនយោបាយរបស់រដ្ឋាភិបាល ជាពិសេសការផ្តល់លទ្ធភាពទទួលបានហិរញ្ញវត្ថុដល់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យអាទិភាព។ ធនាគារបានផ្តួចផ្តើមគម្រោងហិរញ្ញប្បទានដោយផ្ទាល់ ចំនួនបួនប្រភេទគឺ គម្រោងហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យម (CSS) គម្រោងហិរញ្ញប្បទានសហគ្រិនស្ត្រី (CWES) គម្រោងហិរញ្ញប្បទានវិស័យឌីជីថល និងទំនើបកម្ម (CDAS) និងគម្រោងហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូច (CMES) ដែលចាប់ផ្តើមដំណើរការតាំងពីចុងឆ្នាំ២០២១ មក។ ធនាគារបានផ្តល់ការគាំទ្រយ៉ាងសកម្មដោយផ្ទាល់ផ្នែកហិរញ្ញវត្ថុដល់សហគ្រាសចំនួន ២៣១ ជាមួយទំហំឥណទានសរុបចំនួន ៥៣ លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ ក្នុងនេះផងដែរ ៦៩% នៃហិរញ្ញប្បទានសរុបត្រូវបានផ្តល់ដល់សហគ្រាសដែលស្ថិតក្នុងវិស័យអាទិភាព, ៤៦% ត្រូវបានផ្តល់ជូនក្នុងវិស័យកែច្នៃកសិផល និងកម្មន្តសាល។












# មតិពីអតិថិជន



### លោក សុង ខេងលាន

**ម្ចាស់ សហគ្រាស ស៊ី អេស អិល ជាសហគ្រាសផលិត និងផ្គត់ផ្គង់អាហារកញ្ចប់ ដែលផលិតពីផ្លែឈើគ្រាប់ធញ្ញជាតិ និងផលិតគ្រឿងទេស ស្ថិតក្នុងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ**

https://cslsnack.com/en/products

> “ បើគ្មានជំនួយហិរញ្ញប្បទានពីធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ទេ ការកែច្នៃ និងការអភិវឌ្ឍផលិតផលក្នុងស្រុក ឬវត្ថុធាតុដើមឲ្យទៅជាផលិតផលដែលមានតម្លៃបន្ថែម រឺផលិតផលសម្រេចនឹងមិនអាចទៅរួចដោយរលូននោះឡើយ។ ”

សហគ្រាសរបស់ខ្ញុំចាប់ផ្ដើមដំណើរការក្នុងឆ្នាំ២០១៧ ជាមួយនឹងការផលិតទំនិញមួយចំនួនប៉ុណ្ណោះ ដោយសង្កេតឃើញពីតម្រូវការទីផ្សារក៏ដូចជាមានការគាំទ្រលើផលិតផលអាហារកញ្ចប់ និងគ្រឿងទេសថ្មីៗពីសំណាក់អតិថិជនកាន់តែច្រើន ក្នុងឆ្នាំ២០២១ ខ្ញុំក៏បានសម្រេចបង្កើតផលិតផលថ្មីមួយចំនួនបន្ថែមរួមមានអាហារកញ្ចប់ដែលផលិតពីគ្រាប់ស្វាយចន្ទី, ស្វាយ, ចេក, ត្រាវ និងមៀនជាដើម បូកបន្ថែមជាមួយគ្រឿងទេសដូចជា សណ្ដែកបាយ, សណ្ដែកសៀង,សណ្ដែកក្រហម, ម្ទេសក្រៀម, និងម្ទេសកិនជាដើម ។ល។

ដើម្បីសម្រេចបាននូវគោលដៅមួយនេះ តម្រូវឲ្យខ្ញុំមានដើមទុនមួយចំនួនសម្រាប់វិនិយោគដូចជាទិញម៉ាស៊ីនដែលមានគុណភាពល្អជាងមុនបន្ថែម ទុនបង្វិលសម្រាប់ទិញវត្ថុធាតុដើម។ ជាដំណោះស្រាយ ខ្ញុំបានដាក់ពាក្យស្នើសុំហិរញ្ញប្បទានពីធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ដើម្បីទិញម៉ាស៊ីនបន្ថែម ពង្រីកឃ្លាំង និងទិញវត្ថុធាតុដើម។

ជាការពិតបន្ទាប់ពីទទួលបានទុនពីធនាគារ អាជីវកម្មរបស់ខ្ញុំក៏កាន់តែដំណើរការយ៉ាងល្អ ដោយសារតែផលិតផលរបស់សហគ្រាសខ្ញុំអាចបំពេញតម្រូវការដល់អតិថិជនបានទាន់ពេលវេលា ប្រកបដោយគុណភាព។ កំណើននៃការកម្មង់ទំនិញរបស់ខ្ញុំកាន់តែកើនឡើង ពីសំណាក់ផ្សារទំនើបធំៗ ដូចជា ផ្សារអ៊ីអន ផ្សារទំនើបឡាក់គី ផ្សារម៉ាក្រូ ផ្សារថៃហួត ផ្សារបាយ័នជាដើម និងដេប៉ូជាច្រើនទូទាំងប្រទេស។

ខ្ញុំពិតជាសប្បាយចិត្ត និងពេញចិត្តចំពោះធនាគារដែលបានផ្ដល់ហិរញ្ញប្បទានដល់ខ្ញុំជាមួយអត្រាការប្រាក់សមរម្យបំផុត ដែលធ្វើឲ្យខ្ញុំមានលទ្ធភាពសងត្រឡប់ក្នុងកំឡុងពេលនៃដំណើរការនៃការពង្រីកអាជីវកម្មរបស់ខ្ញុំ។







### លោកស្រី ភោគ ហឿង

**ម្ចាស់ សិប្បកម្មហ្គោលដិន យេម ជាសិប្បកម្មផលិតតែ និងនំកញ្ចប់ ស្ថិតក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ**

Golden Yem

> “ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា មិនត្រឹមតែផ្ដល់សេវាកម្មហិរញ្ញវត្ថុដល់សហគ្រាសកែច្នៃម្ហូបអាហារ មិនតែប៉ុណ្ណោះ ធនាគារក៏បានផ្ដល់ និងលើកទឹកចិត្តដល់ម្ចាស់អាជីវកម្ម ដែលគ្រប់គ្រងដោយស្ត្រី ប្រកបដោយភាពស្មោះត្រង់ និងសុច្ចចិត្ត ផងដែរ។ ”

ដំបូងឡើយអាជីវកម្មរបស់ខ្ញុំដំណើរការជាមួយនឹងផលិតផលតែមួយមុខគត់ គឺតែធម្មជាតិ ដោយសារតែនាងខ្ញុំមានផែនការពង្រីកអាជីវកម្មបន្ថែម និងចង់ធ្វើឲ្យអាជីវកម្មរបស់នាងខ្ញុំកាន់តែរីកចម្រើន នាងខ្ញុំក៏បានសម្រេចបង្កើតនូវផលិតផលនំកញ្ចប់ចំនួន ៤ប្រភេទបន្ថែមដែលមានរសជាតិផ្សេងៗគ្នាជាច្រើនមុខដើម្បីឲ្យស្របនឹងតម្រូវការទីផ្សារ។

កង្វះដើមទុនដើម្បីទិញម៉ាស៊ីន សម្ភារៈ ក្នុងការផលិតនំ ក៏ដូចជា តែធម្មជាតិ ជាមូលហេតុ ដែលធ្វើឲ្យនាងខ្ញុំបានសម្រេចដាក់ពាក្យស្នើសុំឥណទានពីធនាគារ ដើម្បីទិញម៉ាស៊ីនផលិតនំ ជាច្រើនគ្រឿងបន្ថែម ផ្លាស់ប្ដូរទីតាំងឃ្លាំងធំជាងមុន និងទិញវត្ថុធាតុដើម សម្រាប់ផលិតនំ និងតែធម្មជាតិបន្ថែម។

សិប្បកម្មរបស់នាងខ្ញុំមានដំណើរការរលូន និងរីកចម្រើនទៅមុខគួរឲ្យកត់សម្គាល់ ដោយសារមានការកម្មង់ទិញពីអតិថិជនបោះដុំជាច្រើន ដូចជាផ្សារទំនើបធំៗដូចជា ផ្សារអ៊ីអន, ផ្សារទំនើបឡាក់គី, ផ្សារម៉ាក្រូ, ផ្សារថៃហួត, ផ្សារបាយ័ន, និងដេប៉ូចែកចាយទូទាំងប្រទេស។ អាជីវកម្មរបស់នាងខ្ញុំចាប់ផ្ដើមដំបូងជាមួយបុគ្គលិកត្រឹមតែ ១០នាក់ ចំណែកឥឡូវខ្ញុំអាចផ្ដល់ការងារដល់បុគ្គលិករហូតដល់ ៣០នាក់ ដែលស្មើនឹង ៣០០% បើប្រៀបនឹងមុនពេលមិនទាន់បានទទួលឥណទាន ពីធនាគារ។

នាងខ្ញុំបានស្គាល់ និងដាក់ពាក្យស្នើសុំឥណទានពីធនាគារតាមរយៈមិត្តភក្តិដែលមានអាជីវកម្មស្រដៀងនឹងនាងខ្ញុំដែរ ដែលធ្លាប់បានស្នើសុំហិរញ្ញប្បទានពីធនាគារ ជាពិសេសនាងខ្ញុំពិតជាសប្បាយចិត្តដែលធនាគារមាននូវគម្រោងហិរញ្ញប្បទានសម្រាប់សហគ្រិនស្ត្រីជាមួយអត្រាការប្រាក់ពិសេសក្នុងការជួយដល់ម្ចាស់អាជីវកម្មដូចនាងខ្ញុំ។ សូមផ្ដាំផ្ញើផងដែរ ទៅកាន់សហគ្រិនស្ត្រីទាំងឡាយ ដែលត្រូវការទុនបន្ថែមក្នុងការពង្រីកអាជីវកម្ម មកស្នើសុំឥណទានពីធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា។

# ព្រឹត្តិការណ៍

## កិច្ចប្រជុំប្រចាំឆ្នាំ២០២២











ធនាគារបានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ ដែលមានការចូលរួមពីបុគ្គលិកគ្រប់ជាន់ថ្នាក់ និងគណៈគ្រប់គ្រងរបស់ធនាគារ ក៏ដូចជាមានការអញ្ជើញចូលរួមពី ឯកឧត្តមប្រធាន និងឯកឧត្តម/លោកជំទាវ សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល។ កិច្ចប្រជុំប្រចាំឆ្នាំនេះ បានប្រព្រឹត្តទៅនៅសណ្ឋាគារសុខា ខេត្តព្រះសីហនុ នារសៀលថ្ងៃសុក្រ ទី០៤ ខែកុម្ភៈ ឆ្នាំ២០២៣។

នៅក្នុងកិច្ចប្រជុំនេះ ធនាគារបានបូកសរុបលទ្ធផលការងារកាលពីឆ្នាំ២០២២ ដោយរំលេចឲ្យឃើញអំពីលទ្ធផលការងារប្រកបដោយផ្លែផ្កា ដែលឆ្លុះបញ្ចាំងអំពីភាពលូតលាស់របស់ធនាគារ និងលើកទិសដៅការងារ ក៏ដូចជាផែនការយុទ្ធសាស្ត្រថ្មីសម្រាប់ការអនុវត្តនៅក្នុងឆ្នាំ២០២៣ ដែលជាការជំរុញភាពរីកចម្រើនរបស់ធនាគារប្រកបដោយចីរភាពស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។





## កម្មវិធីទទួលស្គាល់បុគ្គលិកឆ្នើមប្រចាំឆ្នាំ២០២២
















ធនាគារបានរៀបចំពិធីប្រគល់ពានរង្វាន់បុគ្គលិកឆ្នើមប្រចាំឆ្នាំ២០២២ ជូនដល់បុគ្គលិកឆ្នើមដែលបានចូលរួមចំណែកយ៉ាងសកម្មធ្វើឲ្យប្រតិបត្តិការធនាគារមានភាពរីកចម្រើនផងដែរ។ កម្មវិធីទទួលស្គាល់បុគ្គលិកឆ្នើមប្រចាំឆ្នាំនេះត្រូវបានរៀបចំឡើងកាលពីល្ងាចថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៣ នៅសណ្ឋាគារសុខា ខេត្តព្រះសីហនុ។ ការផ្តល់ពានរង្វាន់បុគ្គលិកឆ្នើម មានការសម្រិតសម្រាំងយ៉ាងខ្លាំង ដែលនាយកដ្ឋានធនធានមនុស្ស បានជ្រើសរើសចេញពីគ្រប់សាខា និងការិយាល័យទាំងអស់ ទើបយកទៅពិភាក្សា និងស្នើសុំការអនុម័តពីគណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ។

កម្មវិធីនេះត្រូវបានរៀបចំឡើងដើម្បីទទួលស្គាល់បុគ្គលិកដែលមានស្នាដៃឆ្នើម លើកទឹកចិត្តដល់បុគ្គលិកដែលខិតខំសម្រេចលទ្ធផលខ្ពស់ ជំរុញវប្បធម៌សមត្ថភាពការងារខ្ពស់ និងជាការផ្តល់តម្លៃសម្រាប់បុគ្គលិកដែលមានទេពកោសល្យ។ ក្នុងនោះ ធនាគារបានរកឃើញនូវបុគ្គលិកឆ្នើមប្រចាំឆ្នាំ ចំនួន ១២ រូប ដែលបានទទួលសេចក្តីអបអរសាទរ រួមជាមួយនឹងពានរង្វាន់បុគ្គលិកឆ្នើមប្រចាំធនាគារ។

## ព្រឹត្តិការណ៍សំខាន់ៗ



ពិធីផ្សព្វផ្សាយតាមរយៈប្រព័ន្ធអនឡាញ ស្តីពី “ការបន្ថែមមូលនិធិសម្រាប់ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម”

ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២



វេទិកាពិភាក្សាតាមរយៈប្រព័ន្ធអនឡាញស្តីពី “ការបន្ថែមថវិកាបដិភាគនៃគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ជំហានទី២”

ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២



ការចូលរួមកិច្ចពិភាក្សាក្រោមប្រធានបទស្តីពី “ការស្វែងយល់ពីលទ្ធភាពទទួលបានហិរញ្ញប្បទាន” នៅក្នុងពិធីបើកដំណើរការ “កម្មវិធីលទ្ធភាពទទួលបានហិរញ្ញប្បទាន”

ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ នៅសណ្ឋាគារអូឡាំព្យា ស៊ីធី



វេទិកាពិភាក្សាតាមរយៈប្រព័ន្ធអនឡាញស្តីពី “គម្រោងសហហិរញ្ញប្បទានទ្រទ្រង់វិស័យទេសចរណ៍”

ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២



កិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់ធនាគារ អាណត្តិទី១ លើកទី១០

ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ នៅអគារការិយាល័យកណ្តាល នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា



ការប្រកាសដាក់ឲ្យអនុវត្ត “គម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍”

ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២







ការចូលរួមក្នុងវេទិកាពិភាក្សាសហគ្រិនស្ត្រី ក្រោមប្រធានបទស្តីពី “លទ្ធភាពទទួលបានហិរញ្ញប្បទាន និងទីផ្សារក្នុងការអភិវឌ្ឍអាជីវកម្មរបស់ស្ត្រី”

ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២
នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)



វេទិកាពិភាក្សាតាមរយៈប្រព័ន្ធអនឡាញស្តីពី “ការអនុវត្តគម្រោងស្តារ និងជំរុញវិស័យទេសចរណ៍”

ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២



លោកបណ្ឌិត លឹម អូន ទទួលបានពានរង្វាន់ International Global Leadership Awards 2022 in Management

ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២ នៅសណ្ឋាគារ Westin ក្នុងទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី



កិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់ធនាគារ អាណត្តិទី១ លើកទី១១

ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ នៅអគារការិយាល័យកណ្តាល នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា



ការចូលរួមឧបត្ថម្ភកម្មវិធី “ពន្លឿនអាជីវកម្មថ្នាលឌីជីថល”

ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២
នៅមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី “តេជោ”



ការចូលរួមវគ្គបិទបញ្ចប់នៃ “កម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថល”

ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២
នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)



កិច្ចពិភាក្សាស្តីពី “វឌ្ឍនភាព និងការធ្វើវិសោធនកម្មលើលក្ខខណ្ឌមួយចំនួន នៃគម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍”

ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ នៅអគារការិយាល័យកណ្តាល នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា



ការចូលរួមកម្មវិធី ទិវាសហគ្រិនស្ត្រីកម្ពុជា ក្រោមប្រធានបទ “ការចូលទៅកាន់ផ្នែកហិរញ្ញវត្ថុរបស់សហគ្រាស ខ្នាតមីក្រូ តូច និងមធ្យម ក្នុងយុគសម័យឌីជីថល”

ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២ នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា



កិច្ចប្រជុំកំណត់គោលដៅយុទ្ធសាស្ត្រ និងផែនការអាជីវកម្មរបស់ធនាគារ សម្រាប់ឆ្នាំ២០២៣-២០២៥

ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ



វគ្គបណ្តុះបណ្តាលស្តីពី “ការគ្រប់គ្រងប្រតិបត្តិការធនាគារ និងការបម្រើសេវាកម្មហិរញ្ញវត្ថុជូនដល់សហគ្រាសធុនតូច និងមធ្យម”

ថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ នៅអគារការិយាល័យកណ្តាល នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា



សិក្ខាសាលាស្តីពី លទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍទីផ្សារសកលសម្រាប់សហគ្រាសធុនតូច និងមធ្យម

ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ នៅអគារការិយាល័យកណ្តាល នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា



ការចូលរួមក្នុងកម្មវិធីជំនួបម្ចាស់អាជីវកម្មលើកទី៤ និងជំនួបរវាងសហគ្រាសធុនមីក្រូ តូច និងមធ្យម ជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុលើកទី២

ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២ នៅសណ្ឋាគារ អូឡាំព្យា ស៊ីធី







កិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់ធនាគារ អាណត្តិទី១ លើកទី១២

ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ នៅអគារការិយាល័យកណ្តាល នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា



ការចូលរួមឧបត្ថម្ភ វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា នៃពិព័រណ៍បច្ចេកវិទ្យាកម្ពុជា ២០២២

ថ្ងៃទី១១ ១២ និង១៣ ខែវិច្ឆិកា ឆ្នាំ២០២២ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ



សន្និសីទសារព័ត៌មាន ស្តីពីសមិទ្ធផលនៃការអនុវត្ត “គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម”

ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២២ នៅសណ្ឋាគារ រ៉ាហ្វិល ឡឺ រ៉ូយ៉ាល់

## អនុស្សរណៈនៃការយោគយល់ ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម



ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ក្នុងការអនុវត្តគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ជំហានទី២

ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២២



ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាង ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និងធនាគារ សាខមប៊េង ខេមបូឌា ក្នុងការអនុវត្តគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ជំហានទី២

ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២



ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាង ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និងធនាគារ កម្ពុជា អាស៊ី ចំកាត់ ក្នុងការអនុវត្តគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ជំហានទី២

ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២



ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាង ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រ៉ឹត ម.ក ក្នុងការអនុវត្តគម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍

ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២



ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និង ធនាគារ កម្ពុជា អាស៊ី ក្នុងការអនុវត្តគម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍

ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២



ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាង ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក ក្នុងការអនុវត្តគម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍

ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២





## រចនាសម្ព័ន្ធធនាគារ





ក្រុមប្រឹក្សាភិបាល



គណៈគ្រប់គ្រងជាន់ខ្ពស់

# ក្រុមប្រឹក្សាភិបាល



## ឯកឧត្តមបណ្ឌិត ផាន់ ផល្លា

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាល

ឯកឧត្តមបណ្ឌិត ផាន់ ផល្លា បានចាប់ផ្តើមបម្រើការងារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្នុងឆ្នាំ២០០៤។ ឯកឧត្តមបណ្ឌិត បានចូលរួមយ៉ាងសកម្មក្នុងការងារអភិវឌ្ឍគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ (FMIS), កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(PFMRP), ការរៀបចំយុទ្ធសាស្ត្រជាតិ និងយុទ្ធសាស្ត្រតាមវិស័យ, យុទ្ធសាស្ត្រកៀរគរចំណូល, ការគ្រប់គ្រង និងវិភាគម៉ាក្រូសេដ្ឋកិច្ច, ការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣។ល។

បច្ចុប្បន្ន ឯកឧត្តមបណ្ឌិត មានតួនាទីជា សមាជិកនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, សមាជិកក្រុមប្រឹក្សាភិបាលនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ, អគ្គលេខាធិការនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធានក្រុមប្រឹក្សាភិបាលរបស់ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា។ ឯកឧត្តមបណ្ឌិត បានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ផ្នែកសេដ្ឋកិច្ច ពីប្រទេសអូស្ត្រាលី។



## ឯកឧត្តម សុន សេងហួត

សមាជិកក្រុមប្រឹក្សាភិបាល

ឯកឧត្តម សុន សេងហួត ជារដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ធ្លាប់មានបទពិសោធន៍ជាច្រើនរួមមាន មុនឆ្នាំ២០១៣ ឯកឧត្តមជាប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានីភ្នំពេញ។ ក្នុងឆ្នាំ២០១៣ ដល់ឆ្នាំ២០១៤ ឯកឧត្តមជាអគ្គនាយករង នៃនាយកដ្ឋានសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ចាប់ពីឆ្នាំ២០១៤ រហូតមកដល់ពេលបច្ចុប្បន្ន ឯកឧត្តមជារដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ទទួលបន្ទុកអគ្គនាយកដ្ឋានសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម និងនាយកដ្ឋានកិច្ចការឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម។

ឯកឧត្តមបានបញ្ចប់ការសិក្សាលើជំនាញគ្រប់គ្រងសហគ្រាសធុនតូច និងមធ្យម ពីប្រទេសវៀតណាម និងជំនាញគ្រប់គ្រង ភូមិមួយផលិតផលមួយ ពីប្រទេសជប៉ុន។ ឯកឧត្តមបានឆ្លងកាត់វគ្គបណ្តុះបណ្តាលរយៈពេលខ្លី ស្តីពីការគ្រប់គ្រងសហគ្រាសធុនតូច និងមធ្យម ពីប្រទេសសិង្ហបុរី និងកូរ៉េ។ ឯកឧត្តមទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែករដ្ឋបាលសាធារណៈ ពីសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប។







## ឯកឧត្តម ទេព ភិយ្យោរិទ្ធ

សមាជិកក្រុមប្រឹក្សាភិបាល

ឯកឧត្តម ទេព ភិយ្យោរិទ្ធ បច្ចុប្បន្នកាន់តំណែងជាអនុរដ្ឋលេខាធិការនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កន្លងមក ឯកឧត្តមធ្លាប់ជាអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ។ ឯកឧត្តមក៏ធ្លាប់បម្រើការងារជាទីប្រឹក្សានៃនាយកប្រតិបត្តិធនាគារពិភពលោករបស់ World Bank Group ដែលមានទីតាំងនៅទីក្រុង Washington D.C. សហរដ្ឋអាមេរិក។ ឯកឧត្តមបានចូលបម្រើការងារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងឆ្នាំ១៩៩៩ ក្នុងតំណែងជាមន្ត្រីផ្នែកថវិកា ហើយបន្តពីពេលនោះ ឯកឧត្តមក៏បានកាន់តំណែងជាច្រើនផងដែរនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលរួមមាន ប្រធានការិយាល័យម៉ាក្រូសេដ្ឋកិច្ច, អនុប្រធាននាយកដ្ឋាន, និងប្រធាននាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។

ឯកឧត្តម បានបញ្ចប់ការសិក្សាផ្នែកគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ពី University of Birmingham នៃចក្រភពអង់គ្លេស និងផ្នែកសេដ្ឋកិច្ច ពី Kharkov State University of Economics នៃប្រទេសអ៊ុយក្រែន។ បច្ចុប្បន្នឯកឧត្តមទទួលខុសត្រូវលើការតាមដានការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច, ការត្រួតពិនិត្យគោលនយោបាយ និងវិភាគបញ្ហាអភិវឌ្ឍ។ ឯកឧត្តមក៏ទទួលបន្ទុកផ្នែកក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច សារពើពន្ធរយៈពេលមធ្យម និងផ្តល់យោបល់ផ្នែកសេដ្ឋកិច្ច, ហិរញ្ញវត្ថុ និងការគ្រប់គ្រងវិស័យសាធារណៈផងដែរ។



## លោកស្រី ឈន ដាលិះ

សមាជិកាក្រុមប្រឹក្សាភិបាលឯករាជ្យ

លោកស្រី ឈន ដាលិះ ត្រូវបានតែងតាំងជាសមាជិកាក្រុមប្រឹក្សាភិបាលឯករាជ្យ នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា នៅឆ្នាំ២០២០។ លោកស្រី មានបទពិសោធន៍ជាង ២០ឆ្នាំ ក្នុងអាជីពជាគណនេយ្យករ និងដឹកនាំ អាជីវកម្មធុនតូច និងមធ្យម ក្នុងវិស័យផ្សេងៗ រួមមាន វិស័យកសិ-ឧស្សាហកម្ម និងវិស័យទឹកស្អាត។

លោកស្រី បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម នៅ Asian Institute of Technology ប្រទេសថៃ និងអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុអន្តរជាតិនៅ Ceram Sophia Antipolis ប្រទេសបារាំង នៅឆ្នាំ២០០២។



**ឯកឧត្តម ចាន់ សុខទី**

សមាជិកក្រុមប្រឹក្សាភិបាល

ឯកឧត្តម ចាន់ សុខទី បច្ចុប្បន្នកាន់តំណែងជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានអគ្គនាយក ក្រុមហ៊ុនហ្គ្រីនត្រេដ នៃក្រសួងពាណិជ្ជកម្ម ឋានៈស្មើរដ្ឋលេខាធិការ និងជាសមាជិកក្រុមប្រឹក្សាភិបាល ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា។

ឯកឧត្តម ចាន់ សុខទី ជាសមាជិកគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា (ប.ស.ប.ក) ដែលទទួលខុសត្រូវសម្រាប់គ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងរបស់រាជរដ្ឋាភិបាល។

ឯកឧត្តម ចាន់ សុខទី ធ្លាប់ធ្វើជាអគ្គនាយកពាណិជ្ជកម្មក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្មផងដែរ ឯកឧត្តមបានធ្វើជានាយកគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច (AIMS)។

ឯកឧត្តម បានចូលបម្រើការងារនៅក្រសួងពាណិជ្ជកម្ម នៅក្នុងឆ្នាំ១៩៩៧ ក្នុងតំណែងជាមន្ត្រីការិយាល័យមន្ទីរពិសោធន៍នៃអគ្គនាយកដ្ឋានកាំកុងត្រូល ហើយបន្ទាប់ពីនោះមក ឯកឧត្តម ក៏បានកាន់តំណែងជាច្រើនផងដែរនៅក្នុងក្រសួងពាណិជ្ជកម្មរួមមាន៖ ជាអនុប្រធានសាខាផែស្វួតចុងទី, ជាអនុប្រធាននាយកដ្ឋាន និងជាអគ្គនាយករងនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ អគ្គនាយកស្តីទី នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

ឯកឧត្តម ចាន់ សុខទី បានបញ្ចប់ការសិក្សាផ្នែកវិស្វករ គីមីចំណីអាហារនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងអនុបណ្ឌិតផ្នែកកសិកម្មនៅសាកលវិទ្យាល័យតូក្យូប្រទេសជប៉ុន។



**បណ្ឌិត លឹម អូន**

អគ្គនាយក និងជាអភិបាល



**លោក នៀវ សុគន្ធ**

នាយកប្រតិបត្តិ ប្រតិបត្តិការ និងជាអភិបាល





# គណៈគ្រប់គ្រងជាន់ខ្ពស់



**បណ្ឌិត លឹម អូន**

អគ្គនាយក និងជាអភិបាល

បណ្ឌិត លឹម អូន មានបទពិសោធន៍ការងារជាង ២៥ឆ្នាំ ក្នុងវិស័យធនាគារ និងក្រុមហ៊ុនសវនកម្មអន្តរជាតិ។ មុនចាប់ផ្តើមបម្រើការងារនៅ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០២១ លោកធ្លាប់បម្រើការងារជាសវនករជាន់ខ្ពស់ នៅក្រុមហ៊ុន ខេភីអឹមជី ក្នុងប្រទេសកម្ពុជា និងម៉ាឡេស៊ី, ជាអគ្គនាយករង នៅធនាគាររឌ្ឍនៈ និងចុងក្រោយជាអគ្គនាយកនៅធនាគារស្ថាបនា។

លោកត្រូវបានតែងតាំងជាអគ្គនាយក និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ដោយរាជរដ្ឋាភិបាលកម្ពុជា នាខែសីហា ឆ្នាំ២០២១។

លោកទទួលបានសញ្ញាបត្រថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងធុរកិច្ច ពីប្រទេសបារាំង។



**លោក នៀវ សុគន្ធ**

នាយកប្រតិបត្តិ ប្រតិបត្តិការ និងជាអភិបាល

លោក នៀវ សុគន្ធ មានបទពិសោធន៍ការងារជាង ២០ឆ្នាំ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ លោកចាប់ផ្តើមអាជីពក្នុងវិស័យហិរញ្ញវត្ថុតាំងពីឆ្នាំ២០០៣។ លោកធ្លាប់កាន់តំណែងជាន់ខ្ពស់ជាច្រើនរួមមាន នាយកប្រតិបត្តិគ្រប់គ្រងសាខា នាយកប្រតិបត្តិឥណទាន និងនាយកសាខាជាដើម ជាមួយនឹងធនាគារធំៗមួយចំនួន។ នាខែសីហា ឆ្នាំ២០២១ លោកបានចូលបម្រើការងារជាមួយធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ក្នុងមុខតំណែងជា នាយកប្រតិបត្តិ ប្រតិបត្តិការ ដែលទទួលខុសត្រូវលើការគ្រប់គ្រងដំណើរការ និងប្រតិបត្តិការរបស់នាយកដ្ឋានអាជីវកម្ម, នាយកដ្ឋានប្រតិបត្តិការ, នាយកដ្ឋានទីផ្សារ, នាយកដ្ឋានអភិវឌ្ឍន៍អាជីវកម្ម, ផ្នែករដ្ឋបាល, និងសាខា។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងធុរកិច្ច ពីសាកលវិទ្យាល័យន័រតុន លោកបានទទួលបរិញ្ញាបត្រផ្នែកឯកទេសអប់រំភាសាអង់គ្លេស ពីសាកលវិទ្យាល័យបៀលប្រាយ។ លោកក៏ទទួលបាននូវវិញ្ញាបនបត្រក្នុងវគ្គបណ្តុះបណ្តាលគ្រប់គ្រង និងដឹកនាំពីបណ្តា ប្រទេសជាច្រើនរួមមាន ប្រទេសអ៊ីតាលី, ប្រទេសឥណ្ឌា, និងប្រទេសវៀតណាម។



## លោក ដែន ដារុទ្ធ

**នាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មាន**

លោក ដែន ដារុទ្ធ បានចាប់ផ្តើមអាជីពរបស់គាត់នៅឆ្នាំ២០០៥ ជាមួយនឹងធនាគារក្នុងស្រុកមួយ ក្នុងផ្នែកព័ត៌មានវិទ្យា។ លោកបានចូលបម្រើការងារនៅ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា នៅខែកក្កដា ឆ្នាំ២០២១ ជានាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មានវិទ្យាដែលមានទំនួលខុសត្រូវចម្បងដូចជាការអនុវត្តគោលការណ៍ យុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មានវិទ្យា ដឹកនាំការកែលម្អពន្លឿនប្រព័ន្ធ ប្រតិបត្តិការផ្សេងៗ និងគ្រប់គ្រង និងពង្រឹងការពារហានិភ័យព័ត៌មានវិទ្យា។

នៅឆ្នាំ២០១០ លោកជាបុគ្គលិកក្នុងចំណោមអ្នកចូលរួមដំបូងក្នុងការបង្កើតស្ថាប័នធនាគារថ្មី នៃធនាគារធំក្នុងតំបន់មួយ មានតួនាទីជា នាយកនាយកដ្ឋានព័ត៌មានវិទ្យា និងប្រតិបត្តិការ។ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០១៩ លោកបានដឹកនាំអនុវត្តគម្រោងធនាគារក្នុងស្រុកថ្មីមួយ លើការដំឡើងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា និងប្រព័ន្ធធនាគារឌីជីថលថ្មី។ ចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២១ លោកជានាយកប្រតិបត្តិបច្ចេកទេសព័ត៌មានវិទ្យា និងឌីជីថល នៃធនាគារស្ថាបនា។

លោកបានទទួលបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅឆ្នាំ២០០៤ បរិញ្ញាបត្រផ្នែកទំនាក់ទំនងសាធារណៈ ពីវិទ្យាស្ថានភាសាបរទេសនៅឆ្នាំ២០០៩ និងទទួលបានវិញ្ញាបនប័ត្រផ្នែកគ្រប់គ្រង និងដឹកនាំពីមហាវិទ្យាល័យបច្ចេកទេសណានយ៉ាង ប្រទេសសឹង្ហបុរី នៅឆ្នាំ២០១៣។



## លោក អឿ វិបុល

**នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ**

លោក អឿ វិបុល មានបទពិសោធន៍ការងារជាង ១៧ឆ្នាំក្នុងវិស័យធនាគារ។ លោកចាប់ផ្តើមអាជីពនៅធនាគារក្នុងស្រុកឈានមុខគេមួយចាប់តាំងពីឆ្នាំ២០០៤ ជាមួយនឹងតួនាទីជាច្រើន ក្នុងផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ។ ចាប់ពីឆ្នាំ២០១០ លោកបានផ្លាស់ទៅបម្រើការងារក្នុងធនាគារមួយនៃធនាគារដ៏ធំក្នុងតំបន់ ជាអ្នកចូលរួមក្នុងការបង្កើតធនាគារដំបូង ដែលអាចផ្តល់បន្ថែមនៅបទពិសោធន៍ និងវិជ្ជាជីវៈក្នុងផ្នែកគណនេយ្យ, ហិរញ្ញវត្ថុ, និងការគ្រប់គ្រងហានិភ័យ ព្រមទាំងតួនាទីចុងក្រោយជានាយកផ្នែកវិភាគ និងគ្រប់គ្រងហានិភ័យ ជាមួយនឹងទំនួលខុសត្រូវចម្បង គឺការអភិវឌ្ឍ និងការអនុវត្តក្របខ័ណ្ឌ និងគោលនយោបាយគ្រប់គ្រងហានិភ័យឲ្យសមស្របនឹងប្រតិបត្តិការ និងបទប្បញ្ញត្តិនានា។

នៅក្នុងខែសីហា ឆ្នាំ២០២០ លោកបានចូលបម្រើការងារជាមួយ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ក្នុងតួនាទីជានាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ ដើម្បីត្រួតពិនិត្យមុខងារគ្រប់គ្រងហានិភ័យ រួមមានហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យសន្ទនីយភាព និងហានិភ័យទីផ្សារ។

នៅក្នុងឆ្នាំ២០០៤ លោកបានបញ្ចប់ការសិក្សាផ្នែកគណនេយ្យ និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។







# អភិបាលកិច្ចសាជីវកម្ម

ធនាគារមានអភិបាលកិច្ចដ៏រឹងមាំ ដោយទទួលបានការណែនាំបច្ចេកទេស និងហិរញ្ញវត្ថុពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការត្រួតពិនិត្យបន្ថែមពីធនាគារជាតិនៃ កម្ពុជា។ ធនាគារត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធានក្រុមប្រឹក្សាភិបាល និងសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។

ធនាគារ បានអនុវត្តការងារផ្អែកលើគោលការណ៍, បទប្បញ្ញត្តិ, នីតិវិធី, ការផ្ទៀងផ្ទាត់, និងយន្តការវាយតម្លៃដែលបានរៀបចំឡើងដោយគណៈគ្រប់គ្រង និងផ្នែកពាក់ព័ន្ធផ្សេងៗក្នុងធនាគារ និងត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

# កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសមាជិកចំនួនប្រាំពីរ (០៧) រូប ដែលរួមមាន៖ អភិបាលប្រតិបត្តិចំនួន ២ រូប និងអភិបាលមិនប្រតិបត្តិចំនួន ៥ រូប។ ក្រុមប្រឹក្សាភិបាលរបស់ធនាគារមានទំនួលខុសត្រូវក្នុងការកំណត់គោលដៅ និងត្រួតពិនិត្យការគ្រប់គ្រង និងកិច្ចការទូទៅរបស់ធនាគារ ស្របតាមគោលនយោបាយ និងបទប្បញ្ញត្តិប្រកបដោយប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល និងទទួលខុសត្រូវជាចម្បងចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ម្ចាស់ភាគហ៊ុនតែមួយគត់) ចំពោះការប្រព្រឹត្តទៅនៃអាជីវកម្មរបស់ធនាគារ។ ធនាគារបានបង្កើតនូវគណៈកម្មការកម្រិតក្រុមប្រឹក្សាភិបាល ចំនួន បី (០៣) គឺ៖ ១). គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម, ២). គណៈកម្មការសវនកម្ម និង ៣). គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ ដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ក្រុមប្រឹក្សាភិបាល និងមានគណៈកម្មការកម្រិតប្រតិបត្តិចំនួន ប្រាំមួយ (០៦) រួមមាន ១). គណៈកម្មការគ្រប់គ្រងហានិភ័យ, ២). គណៈកម្មការប្រតិបត្តិ, ៣). គណៈកម្មការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម, ៤). គណៈកម្មការឥណទាន, ៥). គណៈកម្មការលទ្ធកម្ម, និង ៦). ក្រុមប្រឹក្សាវិន័យ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកធនាគារ។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៅឆ្នាំ២០២២ សរុបចំនួនបួន(០៤)ដង នឹងមានការចូលរួមពីសមាជិក-សមាជិកាដូចខាងក្រោម៖

| ល.រ | ឈ្មោះ | សមាសភាពក្នុងអង្គប្រជុំ |
|---|---|---|
| ១ | ឯកឧត្តមបណ្ឌិត ផាន់ ផល្លា | ប្រធាន |
| ២ | ឯកឧត្តម ទេព ភិយ្យោរិទ្ធ | សមាជិក |
| ៣ | ឯកឧត្តម សុន សេងហួត | សមាជិក |
| ៤ | ឯកឧត្តម ចាន់ សុខទី | សមាជិក |
| ៥ | បណ្ឌិត លឹម អូន | សមាជិក |
| ៦ | លោកស្រី ឈន ដាលិះ | សមាជិកា |
| ៧ | លោក នៀវ សុគន្ធ | សមាជិក |
| ៨ | ឯកឧត្តមបណ្ឌិត គង់ ម៉ារី | មន្ត្រីត្រួតពិនិត្យរដ្ឋ |



# គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល និងមានអភិបាលមិនប្រតិបត្តិចំនួនបី (៣) រូប។ គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម ត្រូវបានអនុញ្ញាតដោយក្រុមប្រឹក្សាភិបាលដើម្បីធានាថាមុខងារគ្រប់គ្រងហានិភ័យនៅក្នុងធនាគារត្រូវបានធ្វើឡើងដោយមានប្រសិទ្ធភាព។

គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម ត្រួតពិនិត្យលើហានិភ័យឥណទាន, ហានិភ័យសន្ទនីយភាព, ហានិភ័យទីផ្សារ និង ហានិភ័យប្រតិបត្តិការ រួមមានការពិនិត្យឡើងវិញនូវហានិភ័យ យុទ្ធសាស្ត្រ គោលនយោបាយ គោលការណ៍ វិធីសាស្ត្រ វាយតម្លៃ និងរបាយការណ៍គ្រប់គ្រងហានិភ័យ។ គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាមមានតួនាទីរាយការណ៍ទៅក្រុមប្រឹក្សាភិបាលស្តីពីបញ្ហាគ្រប់គ្រងហានិភ័យទាំងអស់របស់ធនាគារ។

កិច្ចប្រជុំគណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម មានសរុប ចំនួន ៧ ដែលបានធ្វើឡើងនៅឆ្នាំ២០២២ និងមានការចូលរួមពីសមាជិក-សមាជិកា ដូចខាងក្រោម៖

| ល.រ | ឈ្មោះ | សមាសភាពក្នុងអង្គប្រជុំ |
|---|---|---|
| ១ | ឯកឧត្តម ទេព ភិយ្យោរិទ្ធ | ប្រធាន |
| ២ | ឯកឧត្តម សុន សេងហួត | សមាជិក |
| ៣ | លោកស្រី ឈន ដាលិះ | សមាជិកា |

**តួនាទី និងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម មានដូចខាងក្រោម៖**

## › ការងារគ្រប់គ្រងហានិភ័យ

- ពិនិត្យ និងផ្តល់អនុសាសន៍ លើការរៀបចំគោលនយោបាយពាក់ព័ន្ធផ្សេងៗ សម្រាប់ក្រុមប្រឹក្សាភិបាលអនុម័ត
- ពិនិត្យលើភាពគ្រប់គ្រាន់នៃគោលនយោបាយ, ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ, ការកំណត់, និងការវាស់វែង, ដែលប្រតិបត្តិការទាំងនេះអាចអនុវត្តប្រកបដោយប្រសិទ្ធភាព
- ធានាឲ្យបាននូវហេដ្ឋារចនាសម្ព័ន្ធ ធនធាន និងប្រព័ន្ធគ្រប់គ្រងហានិភ័យ ព្រមទាំងធានាថាបុគ្គលិកដែលទទួលខុសត្រូវ អាចអនុវត្តភារកិច្ចទាំងនោះប្រកបដោយឯករាជ្យ
- ពិនិត្យមើលឡើងវិញនូវរបាយការណ៍ជាប្រចាំរបស់អ្នកគ្រប់គ្រងលើសមាសធាតុហានិភ័យប្រឈម ប្រព័ន្ធវាយតម្លៃហានិភ័យរីសអាប់ភៃថាយ (Risk Appetite) ការធ្វើស្ត្រេស-តេស្ត និងសកម្មភាពគ្រប់គ្រងហានិភ័យ
- ពិនិត្យ និងអនុម័តសកម្មភាពហានិភ័យដែលអាចទទួលយកដូចដែលបានផ្តល់សិទ្ធិ
- ពិនិត្យ និងផ្តល់អនុសាសន៍លើបញ្ហាផ្សេងទៀត ដែលតម្រូវដោយក្រុមប្រឹក្សាភិបាល

## › ការងារប្រតិបត្តិតាម

- ពិភាក្សាអំពីបញ្ហាប្រតិបត្តិតាម និងបញ្ហាហានិភ័យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងធានាថាបញ្ហាទាំងនេះ ត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព និងភាពឆាប់រហ័ស
- ពិនិត្យ និងគាំទ្រការប្រតិបត្តិតាម និងក្របខ័ណ្ឌគោល-នយោបាយប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការកែប្រែសំខាន់ៗលើការប្រតិបត្តិតាម
- ទទួល និងពិនិត្យឡើងវិញយ៉ាងហោចណាស់មួយឆ្នាំម្តង នូវរបាយការណ៍ស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលផ្តល់ជូនដោយមន្ត្រីប្រតិបត្តិតាម និងសកម្មភាពជាក់លាក់ណាមួយ ដែលបានអនុវត្តដោយថ្នាក់ដឹកនាំទាក់ទងនឹងរបាយការណ៍នោះ
- ពិនិត្យឡើងវិញនូវរបាយការណ៍ពីមន្ត្រីប្រតិបត្តិតាម ស្តីពីការរៀបចំនានា ដោយអ្នកគ្រប់គ្រង ដើម្បីធានាបានការប្រកាន់ខ្ជាប់នូវគោលនយោបាយ និងនីតិវិធីប្រតិបត្តិតាមផ្ទៃក្នុង និងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាក់លាក់តាមការស្នើសុំរបស់គណៈកម្មការ ឬតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិ
- ពិនិត្យ និងផ្តល់អនុសាសន៍លើកិច្ចការងារផ្សេងៗដែលតម្រូវដោយក្រុមប្រឹក្សាភិបាល

### ការងារសំខាន់ៗដែលបានត្រួតពិនិត្យ និងអនុម័តដោយគណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

ក្នុងអំឡុងឆ្នាំ២០២២ គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម បានប្តេជ្ញាចិត្តក្នុងការធានាស្ថេរភាព រចនាសម្ព័ន្ធរបស់ធនាគារ ទោះបីជាមានការជួបប្រទះបញ្ហាប្រឈម នឹងភាពតានតឹងជាច្រើន ជាពិសេស យុទ្ធសាស្ត្រស្តារឡើងវិញក្រោយការរាតត្បាត និងការធ្លាក់ចុះនូវវិស័យសេដ្ឋកិច្ចដែលមិនបានរំពឹងទុកក៏ដោយ។ ការងារសំខាន់ៗដែលបានត្រួតពិនិត្យ និងការអនុម័តមានដូចខាងក្រោម៖

- បានពិភាក្សាអំពីរបាយការណ៍គ្រប់គ្រងហានិភ័យ
- បានពិភាក្សាអំពីរបាយការណ៍ស្តីពីហានិភ័យប្រតិបត្តិតាមបទប្បញ្ញត្តិ និងហានិភ័យប្រតិបត្តិតាម
- បានពិភាក្សាអំពីការប្រតិបត្តិតាម ការប្រឆាំងនឹងការសម្អាតប្រាក់ និងការប្រយុទ្ធប្រឆាំងនឹងហានិភ័យហិរញ្ញប្បទានភេរវកម្ម
- បានពិភាក្សាអំពីការគ្រប់គ្រងនិរន្តរភាពអាជីវកម្មរបស់ធនាគារ (BCP)
- ត្រួតពិនិត្យ និងអនុម័តយល់ព្រមលើសិទ្ធិសម្រេច លើសំណើសុំកម្ចីក្រៅពីគោលការណ៍ផ្ទៃក្នុង
- ត្រួតពិនិត្យ និងអនុម័តលើគោលនយោបាយហិរញ្ញវត្ថុ និងគណនេយ្យ
- ត្រួតពិនិត្យ និងអនុម័តលើសំណើសុំសិទ្ធិអនុម័តទាក់ទងនឹងផ្នែកហិរញ្ញវត្ថុ
- ត្រួតពិនិត្យ និងអនុម័តយល់ព្រមលើសិទ្ធិអនុម័តឥណទាន
- ត្រួតពិនិត្យ និងអនុម័តលើសិទ្ធិអនុម័តឥណទានសម្រាប់កម្ចីជាប្រាក់រៀល
- ត្រួតពិនិត្យ និងអនុម័តលើយុទ្ធសាស្ត្របណ្តាញចែកចាយលក់
- ត្រួតពិនិត្យ និងអនុម័តលើភាពជាដៃគូអាជីវកម្មសម្រាប់សេវាកម្មទូទាត់ប្រាក់
- ត្រួតពិនិត្យ និងអនុម័តលើគម្រោង សហហិរញ្ញប្បទានស្តារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍
- ត្រួតពិនិត្យ និងអនុម័តលើការកំណត់ក្រុមហ៊ុនអចលនទ្រព្យសម្រាប់ឥណទានគេហដ្ឋានបុគ្គលិក
- ត្រួតពិនិត្យ និងអនុម័តលើការបើកគណនី និងប្រគល់សិទ្ធិអនុញ្ញាតលើប្រតិបត្តិការគណនីនៅធនាគារ
- ត្រួតពិនិត្យ និងអនុម័តលើសំណើបើកគណនី ជាមួយធនាគារ Wing
- បានអនុម័តលើឯកសារ តួនាទី និងការទទួលខុសត្រូវរបស់នាយកដ្ឋានគ្រប់គ្រងហានិភ័យ និងនាយកដ្ឋានប្រតិបត្តិតាម
- បានអនុម័តលើនីតិវិធីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បានអនុម័តលើឯកសារ តួនាទី និងការទទួលខុសត្រូវរបស់នាយកដ្ឋានគ្រប់គ្រងហានិភ័យ
- បានអនុម័តលើបច្ចុប្បន្នភាពអត្រាឥណទានខាតបង់
- បានអនុម័តលើឯកសារណែនាំប្រតិបត្តិការទូទាត់ប្រាក់
- បានអនុម័តលើលទ្ធផលនៃការធ្វើស្ត្រេសតេស្ត និងការវិភាគគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២២

### › ផ្នែកគ្រប់គ្រងហានិភ័យ

ការគ្រប់គ្រងហានិភ័យដើរតួនាទីចម្បងក្នុងវិស័យធនាគារ និងកាន់តែសំខាន់ក្នុងស្ថានភាពសេដ្ឋកិច្ចមិនច្បាស់លាស់។ វប្បធម៌គ្រប់គ្រងហានិភ័យត្រូវបានដាក់បញ្ចូលទៅក្នុងផ្នែកនីមួយៗនៃអាជីវកម្ម ដើម្បីធានានូវភាពគ្រប់គ្រាន់នៃប្រព័ន្ធគ្រប់គ្រងហានិភ័យក្នុងកម្រិតមួយដែលអាចទទួលយកបាន សម្រាប់ការរីកចម្រើនប្រកបដោយនិរន្តរភាព។ ការគ្រប់គ្រងហានិភ័យមានមុខងារឯករាជ្យ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយផ្នែកពាក់ព័ន្ធ ដើម្បីធានាបាននូវប្រព័ន្ធ និងវប្បធម៌គ្រប់គ្រងហានិភ័យល្អ ប្រកបដោយភាពរឹងមាំ។

ជាការសន្និដ្ឋានរួម ការគ្រប់គ្រងហានិភ័យ ទទួលខុសត្រូវចំពោះមុខងារគ្រប់គ្រងហានិភ័យប្រចាំថ្ងៃ ក៏ដូចជាការត្រួតពិនិត្យហានិភ័យប្រឈមរបស់ធនាគារ និងធ្វើការរាយការណ៍ជាប្រចាំទៅគណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម។





### ធនាគារបានផ្តោតសំខាន់ទៅលើហានិភ័យចម្បងៗមួយចំនួនដូចខាងក្រោម៖

**ហានិភ័យឥណទាន**

ជាការខាតបង់ដែលកើតឡើងដោយភាគីអ្នកខ្ចី ឬដៃគូសហការខកខានមិនបានអនុវត្តកាតព្វកិច្ចសងតាមកិច្ចសន្យារបស់ខ្លួនជាមួយធនាគារ។ ដំណាក់កាលនៃការគ្រប់គ្រងហានិភ័យឥណទាន ត្រូវបានផ្តោតសំខាន់លើការវិភាគ អនុម័ត និងតាមដានឥណទានប្រកបដោយភាពឯករាជ្យ និងវិជ្ជាជីវៈ ដើម្បីធ្វើឲ្យប្រាកដថាលក្ខខណ្ឌដែលបានអនុម័តត្រូវបានត្រួតពិនិត្យយ៉ាងត្រឹមត្រូវ។ ក្រៅពីការវាយតម្លៃឥណទានឯករាជ្យ ផ្នែកគ្រប់គ្រងឥណទានអនុវត្តតួនាទីនៃការដាស់តឿន និងតាមដាន ដើម្បីធានាថាលក្ខខណ្ឌដែលបានអនុម័តត្រូវបានត្រួតពិនិត្យយ៉ាងត្រឹមត្រូវ។ ផ្នែកគ្រប់គ្រងឥណទានក៏មានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យឥណទានទាំងអស់របស់ធនាគារ និងកម្រិតកំណត់ដែលទាក់ទងនឹងឥណទាន។ ក្រៅពីការវាយតម្លៃឥណទាន ផ្នែកគ្រប់គ្រងឥណទាន មានតួនាទីក្នុងការត្រួតពិនិត្យគុណភាពឥណទាន និង ការត្រួតពិនិត្យ និងការស្តារឥណទាន ដើម្បីពង្រឹងគុណភាពទ្រព្យសកម្ម និងនិរន្តរភាពរយៈពេលវែងរបស់ធនាគារផងដែរ។ ការអភិវឌ្ឍជំនាញនៃការគ្រប់គ្រងហានិភ័យឥណទានជូនដល់គ្រប់បុគ្គលិកពាក់ព័ន្ធ ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយហានិភ័យឥណទាន។

**ហានិភ័យសន្ទនីយភាព**

ហានិភ័យដែលធនាគារមិនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ដល់ការរីកចម្រើន ឬបំពេញកាតព្វកិច្ចនៃកិច្ចសន្យារបស់ខ្លួន ដោយមិនមានការខាតបង់ដែលមិនអាចទទួលយកបាន។

ធនាគារ ត្រូវរក្សាកម្រិតសន្ទនីយភាពឲ្យបានគ្រប់គ្រាន់ គ្រប់ពេលវេលាដូចជាស្ថានភាពលំហូរសាច់ប្រាក់ និង/ឬ ទ្រព្យសកម្មដែលងាយស្រួលក្នុងការដោះដូរ ដើម្បីអាចបំពេញបានទៅតាមកាតព្វកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិក្រោមលក្ខខណ្ឌអាជីវកម្មធម្មតា និងស្ថានភាពស្ត្រេស។

ការទទួលយកហានិភ័យសន្ទនីយភាពរបស់ធនាគារត្រូវបានគ្រប់គ្រងដោយ Liquidity Risk Appetite កំណត់កម្រិតហានិភ័យសន្ទនីយភាព ដែលធនាគារនឹងទទួលយកតាមយុទ្ធសាស្ត្រ និងគោលដៅអាជីវកម្មរបស់ខ្លួន។ វិសអាប់ភៃថាយ (Risk Appetite) គិតគូរពីកំណើនផលចំណូល និងគោលបំណងអាជីវកម្មរបស់ធនាគារ ក៏ដូចជាសមត្ថភាពគ្រប់គ្រងហានិភ័យ។

តួនាទីគ្រប់គ្រងហានិភ័យ ទទួលខុសត្រូវតាមដានដោយឯករាជ្យនូវទម្រង់ហានិភ័យសន្ទនីយភាពរបស់ធនាគារ និងផ្តល់របាយការណ៍ជាប្រចាំដល់គណៈកម្មការគ្រប់គ្រងហានិភ័យ (កម្រិតប្រតិបត្តិ) ក៏ដូចជាគណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម ដើម្បីឲ្យធនាគារចាត់ចែងស្ថានភាពសន្ទនីយភាព ហើយឆ្លើយតបនឹងតម្រូវការប្រតិបត្តិការប្រចាំថ្ងៃ និងតម្រូវការបទប្បញ្ញត្តិ។

**ហានិភ័យទីផ្សារ**

ត្រូវបានកំណត់ថាជាការប្រែប្រួល នៅក្នុងតម្លៃទីផ្សារហិរញ្ញវត្ថុដោយសារតែការផ្លាស់ប្តូរ អត្រាហានិភ័យទីផ្សារ ដូចជាអត្រាការប្រាក់, ប្តូរប្រាក់ និងការប៉ះពាល់លើប្រាក់ចំណេញឥណទាន, តម្លៃភាគហ៊ុន, តម្លៃទំនិញ និងបម្រែបម្រួលពីកត្តាផ្សេងៗដែលពាក់ព័ន្ធ ។

**ហានិភ័យប្រតិបត្តិការ**

សំដៅទៅលើហានិភ័យនៃការបាត់បង់ដែលបណ្តាលមកពីភាពមិនគ្រប់គ្រាន់ ឬបរាជ័យនៃដំណើរការផ្ទៃក្នុង មនុស្ស និងប្រព័ន្ធ ឬព្រឹត្តិការណ៍ខាងក្រៅ។ ហានិភ័យប្រតិបត្តិការ បានរួមបញ្ចូលទាំងហានិភ័យផ្នែកច្បាប់ ប៉ុន្តែមិនមានហានិភ័យយុទ្ធសាស្ត្រ និងហានិភ័យកេរ្តិ៍ឈ្មោះទេ។ តម្រូវការសំខាន់មួយនៃរចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យរឹងមាំ គឺត្រូវមានឧបករណ៍គ្រប់គ្រងហានិភ័យប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពដើម្បីកំណត់ វាស់វែង តាមដាន ត្រួតពិនិត្យ និងរាយការណ៍អំពីហានិភ័យប្រតិបត្តិការរបស់ធនាគារ។

# គណៈកម្មការសវនកម្ម

គណៈកម្មការសវនកម្ម ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល និងមានអភិបាលមិនប្រតិបត្តិចំនួនបួន (០៤) រូប ដើម្បីផ្តល់ការត្រួតពិនិត្យឯករាជ្យទៅលើសវនកម្មផ្ទៃក្នុង, របាយការណ៍ហិរញ្ញវត្ថុ, ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង, និងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ ដើម្បីធានាដល់ការត្រួតពិនិត្យ និងសមតុល្យ ព្រមទាំងសមភាព និងអនុលោមតាមតម្រូវការបទប្បញ្ញត្តិនៅក្នុងធនាគារ។ ការប្រជុំរបស់គណៈកម្មការសវនកម្ម នៅឆ្នាំ២០២២ សរុបចំនួនប្រាំបី (០៨) ដង ហើយមានការចូលរួមពីសមាជិក-សមាជិកា ដូចខាងក្រោម៖

| ល.រ | ឈ្មោះ | សមាសភាពក្នុងអង្គប្រជុំ |
|---|---|---|
| ១ | លោកស្រី ឈន ដាលិះ | ប្រធាន |
| ២ | ឯកឧត្តម ទេព ភិយ្យោរិទ្ធ | សមាជិក |
| ៣ | ឯកឧត្តម សុន សេងហួត | សមាជិក |
| ៤ | ឯកឧត្តម ចាន់ សុខទី | សមាជិក |

### គណៈកម្មការសវនកម្ម អនុវត្តតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ធានាថា ព័ត៌មានដែលបានផ្តល់ជូនដល់សាធារណជន និងធនាគារជាតិ នៃ កម្ពុជា មានភាពច្បាស់លាស់ត្រឹមត្រូវ និងអាចទុកចិត្តបាន
- ធានាថា សវនករផ្ទៃក្នុងធ្វើសវនកម្មជាទៀងទាត់នូវវិធីសាស្ត្រគណនេយ្យកត់ត្រា និងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីឆ្លើយតបនឹងការរំពឹងទុកនៃបទប្បញ្ញត្តិ និងក្រុមប្រឹក្សាភិបាល
- វាយតម្លៃ ត្រួតពិនិត្យ និងអនុម័ត ទៅលើគោលនយោបាយសវនកម្មផ្ទៃក្នុង នីតិវិធី និងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ជាពិសេស ប្រព័ន្ធសម្រាប់វាស់តាមដាន ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យមានភាពស៊ីសង្វាក់គ្នា និងផ្តល់អនុសាសន៍នូវចំណុចខ្វះខាត
- ជួយដល់ក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យលើការអនុវត្តស្តីពីគោលនយោបាយគណនេយ្យ និងការរៀបចំរបាយការណ៍ឲ្យបានត្រឹមត្រូវ គ្រប់គ្រាន់ និងធានាឲ្យបាននូវប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង
- ធានាឲ្យបាននូវសកម្មភាពកែតម្រូវ ដែលបានព្រមព្រៀងរវាងសវនករផ្ទៃក្នុង និងគណៈគ្រប់គ្រង ដើម្បីអនុវត្តតាមកាលបរិច្ឆេទដែលបានកំណត់

### សមិទ្ធផលដែលគណៈកម្មការសវនកម្មសម្រេចបានក្នុងឆ្នាំ២០២២៖

- ពិនិត្យ និងផ្តល់ជាអនុសាសន៍លើការរកឃើញរបស់សវនកម្មផ្ទៃក្នុង និងការរកឃើញលើសវនកម្មពិសេស
- ពិភាក្សាអំពីសូចនាករវាយតម្លៃលទ្ធផលការងារសម្រាប់ក្រុមសវនកម្មផ្ទៃក្នុង, កញ្ចប់ថវិកា, និងចំនួនបុគ្គលិក
- ត្រួតពិនិត្យការអនុវត្តតាមអនុសាសន៍ពីនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងគណៈកម្មការសវនកម្ម
- ពិនិត្យ និងឯកភាពលើសំណើក្នុងការជ្រើសរើសសវនករឯករាជ្យ មុននឹងធ្វើការដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ដឹកនាំកិច្ចប្រជុំ រវាងគណៈគ្រប់គ្រងជាមួយសវនករឯករាជ្យលើការរកឃើញរបស់សវនករឯករាជ្យ
- ត្រួតពិនិត្យលើរបាយការណ៍សវនកម្មប្រចាំឆ្នាំ២០២១ មុននឹងធ្វើការដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត ព្រមទាំងធ្វើការរាយការណ៍ជូនទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ត្រួតពិនិត្យ និងអនុម័តរបាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងដែលបានអនុម័តប្រចាំឆ្នាំ២០២១ រាយការណ៍ជូនទៅធនាគារជាតិ នៃ កម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ពិនិត្យលើវគ្គបណ្តុះបណ្តាលសម្រាប់សវនករផ្ទៃក្នុង ដើម្បីធ្វើការពង្រឹងនូវសមត្ថភាព
- ពិនិត្យ និងអនុម័តផែនការការងារនៃសវនកម្មផ្ទៃក្នុងសម្រាប់ឆ្នាំ២០២២
- វាយតម្លៃការអនុវត្តប្រចាំឆ្នាំរបស់ប្រធានសវនកម្មផ្ទៃក្នុង។





សវនកម្មផ្ទៃក្នុងមានតួនាទីក្នុងការវាយតម្លៃ ត្រួតពិនិត្យ តាមដានការអនុវត្ត ទៅលើដំណើរការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចរបស់ធនាគារជាប្រចាំគ្រា ដើម្បីឲ្យប្រាកដថាទទួលបានលទ្ធផលសមស្របទៅតាមទស្សនៈវិស័យ និងកម្មវត្ថុដែលធនាគារកំណត់ប្រកបដោយប្រសិទ្ធភាព។ ដើម្បីធានាបាននូវតម្លាភាព និងឯករាជ្យភាពនៃការងារសវនកម្ម សវនករផ្ទៃក្នុងត្រូវរាយការណ៍ដោយផ្ទាល់ជូនទៅគណៈកម្មការសវនកម្ម និងរាយការណ៍ដោយប្រយោលជូនទៅអគ្គនាយក លើការងាររដ្ឋបាលមួយចំនួន។

### តួនាទីសវនករផ្ទៃក្នុង៖

- គ្រប់គ្រងការងារសវនកម្ម តួនាទី សម្របសម្រួលពិនិត្យឡើងវិញ និងរាយការណ៍អំពីការងាររបស់សវនករផ្ទៃក្នុង និងផ្តល់ជំនាញក្នុងស្តង់ដាសវនកម្ម និងលក្ខណៈវិនិច្ឆ័យការអនុវត្ត និងតម្រូវការរបស់សវនកម្មផ្ទៃក្នុង។
- រៀបចំផែនការចាត់ចែង និងត្រួតពិនិត្យសកម្មភាព និងការងារប្រចាំថ្ងៃរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង រក្សាទំនាក់ទំនងអតិថិជន និងបុគ្គលិកប្រកបដោយប្រសិទ្ធភាព ព្រមទាំងប្រសិទ្ធផល។
- ធានាឲ្យបានថារាល់គោលនយោបាយ និងនីតិវិធីផ្ទៃក្នុងត្រូវបានអនុវត្តយ៉ាងពេញលេញដោយគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់របស់ធនាគារ។
- ណែនាំការគ្រប់គ្រងលើផលប៉ះពាល់នៃហានិភ័យដែលទាក់ទងនឹងផលិតផល សេវាកម្ម ឬសកម្មភាពថ្មីៗ និងផែនការកាត់បន្ថយផលប៉ះពាល់នៃហានិភ័យទាំងនោះ។
- រៀបចំ និងធ្វើបច្ចុប្បន្នភាពលើផែនការសវនកម្មផ្ទៃក្នុងដោយផ្អែកលើហានិភ័យសម្រាប់ការវាយតម្លៃ ប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យសំខាន់ៗ។
- ធានានូវការឆ្លើយតប និងចំណាត់ការពីគណៈគ្រប់គ្រងចំពោះលទ្ធផលនៃការធ្វើសវនកម្ម និងការអនុវត្តអនុសាសន៍នានា ដែលផ្តល់ដោយសវនករផ្ទៃក្នុង ទៅតាមពេលវេលាដែលបានព្រមព្រៀង។
- ជួយគណៈកម្មការសវនកម្ម និងក្រុមប្រឹក្សាភិបាលក្នុងការបំពេញនូវទំនួលខុសត្រូវ ទៅលើការអនុវត្តត្រឹមត្រូវនៃគោលនយោបាយគណនេយ្យ របាយការណ៍ ភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុង។

# គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ

គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ ត្រូវបានបង្កើតឡើង នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២១ ដែលជាគណៈកម្មការចំណុះឲ្យក្រុមប្រឹក្សាភិបាលនៃធនាគារ។ គណៈកម្មការនេះ មានតួនាទីភារកិច្ចជាចម្បងដោយត្រូវធានាថា គោលនយោបាយអត្ថប្រយោជន៍របស់បុគ្គលិកត្រូវមានសង្គតិភាពទៅនឹងគោលដៅរយៈពេលវែង គុណតម្លៃស្នូលរបស់ធនាគារ គោលដៅរបស់ធនាគារ អត្ថប្រយោជន៍ត្រូវមានភាពប្រហាក់ប្រហែលទៅនឹងគ្រឹះស្ថានហិរញ្ញវត្ថុនានា និងកត្តាផ្សេងៗទៀតដែលបម្រើឲ្យតម្រូវការហិរញ្ញវត្ថុ និងតម្រូវការពាណិជ្ជកម្មរបស់ធនាគារ។ គណៈកម្មការនេះ ត្រូវបានបង្កើតឡើងស្របតាមប្រកាសធនាគារជាតិ នៃ កម្ពុជា លេខធ៧-០៨-២១១ ប្រ.ក ស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ បច្ចុប្បន្នគណៈកម្មការនេះ មានសមាជិកចំនួន ៤ (បួន)រូប និងប្រធានចំនួន ១(មួយ)រូប ដូចមានរៀបរាប់ខាងក្រោម៖

| ល.រ | ឈ្មោះ | សមាសភាពក្នុងអង្គប្រជុំ |
|---|---|---|
| ១ | ឯកឧត្តម សុន សេងហួត | ប្រធាន |
| ២ | ឯកឧត្តម ទេព ភិយ្យោរិទ្ធ | សមាជិក |
| ៣ | ឯកឧត្តម ចាន់ សុខទី | សមាជិក |
| ៤ | លោកស្រី ឈន ដាលិះ | សមាជិកា |
| ៥ | លោក នៀវ សុគន្ធ | សមាជិក |

### គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ អនុវត្តតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យមើលលើគ្រប់ទិដ្ឋភាពនៃតម្លៃការទាំងអស់ មិនកំណត់តែលើប្រាក់កម្រៃរបស់អភិបាលដែលមានដូចជា៖ ប្រាក់ខែ ប្រាក់ឧបត្ថម្ភ ការចំណាយ ថ្លៃប្រឹក្សាយោបល់ (ប្រសិនបើមាន) និងអត្ថប្រយោជន៍ផ្សេងៗ។
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលអំពីតម្លៃការរបស់អភិបាលធនាគារ។
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលនូវគោលដៅប្រចាំឆ្នាំ និងផែនការអត្ថប្រយោជន៍ (រួមទាំងប្រាក់រង្វាន់ និងផែនការផ្សេងទៀត ដែលបង្កើតឡើងដើម្បីជំរុញដល់ការបង្កើនតម្លៃរួមរយៈពេលវែង) សម្រាប់គណៈគ្រប់គ្រងធនាគារ នាយកផ្នែកសវនកម្មផ្ទៃក្នុង និងប្រធានផ្នែកប្រតិបត្តិតាម សម្រាប់ឆ្នាំបន្ទាប់។
- ពិនិត្យឡើងវិញនូវប្រាក់ឧបត្ថម្ភ និងទម្រង់នៃអត្ថប្រយោជន៍ផ្សេងៗដល់គណៈគ្រប់គ្រង និងប្រធានផ្នែកសំខាន់ៗរបស់ធនាគារ ដើម្បីធានាភាពសមស្របគ្នាទៅនឹងទំនួលខុសត្រូវ និងហានិភ័យដែលអាចពាក់ព័ន្ធនឹងសមាជិកភាពប្រកបដោយប្រសិទ្ធភាពរបស់គណៈគ្រប់គ្រង។
- ពិនិត្យឡើងវិញ និងវាយតម្លៃប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មការ យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។
- ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងនីតិវិធីពាក់ព័ន្ធយ៉ាងហោចណាស់ ម្តងក្នុងមួយឆ្នាំ សម្រាប់ការអនុម័តពីក្រុមប្រឹក្សាភិបាល។

### សមិទ្ធផលដែលគណៈកម្មការតែងតាំង និងផ្តល់តម្លៃការសម្រេចបានក្នុងឆ្នាំ២០២២៖

- ពិនិត្យ និងផ្តល់យោបល់លើការដំឡើងប្រាក់បៀវត្សប្រចាំឆ្នាំ២០២២ និងការដំឡើងប្រាក់បៀវត្សពិសេសដល់បុគ្គលិកធនាគារ មុននឹងដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ពិនិត្យ និងផ្តល់យោបល់លើការផ្តល់អត្ថប្រយោជន៍បន្ថែមសម្រាប់បុគ្គលិកនាយកដ្ឋានអាជីវកម្ម មុននឹងដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ពិនិត្យ និងផ្តល់យោបល់លើការកែប្រែរចនាសម្ព័ន្ធថ្មីរបស់ធនាគារ មុននឹងដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ពិនិត្យ និងអនុម័តលើទម្រង់វាយតម្លៃលទ្ធផលការងាររបស់បុគ្គលិកប្រចាំឆ្នាំ២០២២
- ពិនិត្យ និងអនុម័តលើវគ្គបណ្តុះបណ្តាលដល់បុគ្គលិក
- ពិនិត្យលើការកំណត់លក្ខណៈវិនិច្ឆ័យសូចនាករវាយតម្លៃលទ្ធផលការងាររបស់បុគ្គលិក
- ពិនិត្យ និងផ្តល់យោបល់ លើក្រមសីលធម៌ប្រតិបត្តិ មុននឹងដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ពិនិត្យ និងវាយតម្លៃលើការបន្តសុពលភាពកិច្ចសន្យាការងារថ្នាក់នាយកប្រតិបត្តិជាន់ខ្ពស់
- ពិនិត្យ និងអនុម័តលើកម្មវិធីទទួលស្គាល់បុគ្គលិកឆ្នើមរបស់ធនាគារ



# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក (“ធនាគារ”) សូមបង្ហាញនូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់។

## ព័ត៌មានអំពីធនាគារ

ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក ត្រូវបានបង្កើតឡើង ក្នុងព្រះរាជាណាចក្រកម្ពុជា ជាក្រុមហ៊ុនគ្រប់គ្រងដោយរដ្ឋ ដែលរៀបចំឡើងក្រោមច្បាប់ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ជាមួយនឹងវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន CO 0001 M/២០២០ ដែលចេញដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។ ធនាគារ ស្ថិតនៅក្រោមការត្រួតពិនិត្យបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (“MEF”)។

ធនាគារ បានទទួលអាជ្ញាបណ្ណធនាគាររបស់ខ្លួនពីធនាគារជាតិ នៃ កម្ពុជា (“NBC”) នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ដើម្បីដំណើរការជាធនាគារពាណិជ្ជដែលមានសុពលភាពអចិន្ត្រៃយ៍។

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺការផ្តល់ហិរញ្ញប្បទាន និងសេវាធនាគារពាណិជ្ជ ដើម្បីគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អាសយដ្ឋានរបស់ការិយាល័យចុះបញ្ជីរបស់ធនាគារ មានទីតាំងនៅអគារមជ្ឈមណ្ឌលអភិវឌ្ឍន៍ធុរកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដីឡូត៍លេខ អេស ផ្លូវអូស៊ីអាយស៊ី ភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទរបស់ធនាគារ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

## ភាគលាភ

ពុំមានភាគលាភត្រូវបានប្រកាស ឬ បានបង់ទេ ហើយក្រុមប្រឹក្សាភិបាលមិនបានណែនាំឲ្យបង់ ភាគលាភណាមួយសម្រាប់បរិច្ឆេទនេះទេ។

## ការខាតបង់ឥណទានដែលរំពឹងទុកលើឥណទាន និងបុរេប្រទាន

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានាដើម្បីបញ្ជាក់ឲ្យដឹងថា ដើម្បីឈានដល់ការអះអាងថា នីតិវិធីពាក់ព័ន្ធជាមួយនឹងការជម្រះឥណទានអាក្រក់ចេញពីបញ្ជី ឬ ការទទួលស្គាល់នៃសំវិធានធនលើការខាតបង់ឥណទានដែលរំពឹងទុកត្រូវបានយកមកអនុវត្ត និងជឿជាក់ថា ឥណទានអាក្រក់ទាំងអស់ដែលបានកត់សម្គាល់ ត្រូវបានជម្រះចេញពីបញ្ជី ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានធ្វើឡើងសម្រាប់ការខាតបង់ឥណទានរំពឹងទុក លើឥណទាន និងបុរេប្រទានទាំងនោះ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលអាចបណ្តាលឲ្យចំនួនទឹកប្រាក់ នៃឥណទាន និងបុរេប្រទានអាក្រក់ដែលបានជម្រះចេញពីបញ្ជី ឬ ចំនួនទឹកប្រាក់សំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុកចំពោះឥណទាន និងបុរេប្រទានក្នុងរបាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារមិនគ្រប់គ្រាន់រហូតដល់ដំណាក់កាលជាសារវន្តនោះទេ។





## ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្របដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មទាំងឡាយដែលទំនងជាមិនអាចប្រមូលមកវិញ តាមតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថា នឹងអាចប្រមូលបានជាក់ស្តែង។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## វិធីសាស្ត្រនៃការវាយតម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើងហើយប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថា មានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

(ក) ពុំមានការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ធនាគារដែលកើតមានឡើងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុសម្រាប់ធានាចំពោះបំណុលរបស់បុគ្គលណាមួយ និង

(ខ) ពុំមានបំណុលយថាភាពណាមួយកើតមានឡើងចំពោះធនាគារនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុ ក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតា។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាភាព ឬ បំណុលផ្សេងៗទៀតរបស់ធនាគារដែលត្រូវបានទាមទារឲ្យសង ឬ អាចនឹងទាមទារឲ្យសងក្នុងអំឡុងពេល ១២ខែ បន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទ ដែលនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់ឡើយ។

## ការផ្លាស់ប្តូរនៃកាលៈទេសៈ

នាការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង មិនត្រូវបានគេដោះស្រាយក្នុងរបាយការណ៍នេះ ឬ របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលនឹងធ្វើឲ្យចំនួនទឹកប្រាក់ដែលមានចែងក្នុងរបាយការណ៍ហិរញ្ញវត្ថុមានការយល់ច្រឡំ។

## ធាតុមានលក្ខណៈមិនប្រក្រតី

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារសម្រាប់ការិយបរិច្ឆេទនេះ មិនបានរងផលប៉ះពាល់ដោយធាតុប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយជាសារវន្ត និងមានលក្ខណៈមិនប្រក្រតីឡើយ។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានប្រតិបត្តិការ ឬហេតុការណ៍ជាសារវន្ត និងមិនប្រក្រតី ដែលបានកើតឡើងនៅក្នុងចន្លោះពេលរវាងចុងការិយបរិច្ឆេទបញ្ចប់ និងកាលបរិច្ឆេទនៃរបាយការណ៍នេះ ដែលធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារក្នុងរយៈពេលដែលរបាយការណ៍នេះត្រូវបានធ្វើឡើង។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលបានដឹង និងយល់ឃើញថា ពុំមានព្រឹត្តិការណ៍សំខាន់ គួរឲ្យកត់សម្គាល់បានកើតឡើងបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ដែលតម្រូវឲ្យមានការកែតម្រូវ ឬ បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ។

## ក្រុមប្រឹក្សាភិបាល

សមាសភាពនៃក្រុមប្រឹក្សាភិបាល នៅក្នុងអំឡុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| ឈ្មោះ | មុខតំណែង |
|---|---|
| ឯកឧត្តមបណ្ឌិត ផាន់ ផល្លា | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាល |
| ឯកឧត្តម ទេព ភិយ្យោរិទ្ធ | សមាជិក |
| ឯកឧត្តម ចាន់ សុខទី | សមាជិក |
| ឯកឧត្តម សុន សេងហួត | សមាជិក |
| លោកស្រី ឈន ដាលិះ | សមាជិកា |
| បណ្ឌិត លឹម អូន | អគ្គនាយក និងសមាជិក |
| លោក នៀវ សុគន្ធ | នាយកប្រតិបត្តិ ប្រតិបត្តិការ និងសមាជិក (ត្រូវបានតែងតាំងនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២២) |

## សវនករឯករាជ្យ

ក្រុមហ៊ុនសវនកម្មឯករាជ្យ អឺនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា) គឺជាសវនកររបស់ធនាគារ។

## ភាគហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ កាន់កាប់ភាគហ៊ុនរបស់ធនាគារនោះទេ។ ពុំមានការព្រមព្រៀងណាមួយ ដែលធនាគារចូលរួមជាភាគីម្ខាងទៀត ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ដើម្បីទទួលបាននូវ ភាគហ៊ុនពីសាមីធនាគារ ឬ ពីក្រុមហ៊ុនដទៃទៀតទេ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុង និងនាចុងការិយបរិច្ឆេទ ពុំមានការព្រមព្រៀងណាមួយ ដែលមានធនាគារចូលរួមជាភាគីម្ខាងទៀត ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ ដោយការទិញយកភាគហ៊ុន ឬលិខិតបំណុលពីសាមីធនាគារ ឬពីក្រុមហ៊ុនដទៃទៀតទេ។

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាមួយរបស់ធនាគារ ដែលបានទទួល ឬមានសិទ្ធិនឹងទទួលបាននូវអត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើង ធនាគារ និងក្រុមហ៊ុនពាក់ព័ន្ធ ដែលមានក្រុមប្រឹក្សាភិបាលនោះ ជាសមាជិក ឬក៏ក្រុមហ៊ុនមួយដែលក្រុមប្រឹក្សាភិបាល មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តជាមួយគ្នា ក្រៅពីប្រតិបត្តិការដូចមានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។





## របាយការណ៍ស្តីពីការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល ជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីបង្ហាញនូវទិដ្ឋភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងលទ្ធផលហិរញ្ញវត្ថុ ហើយនិងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់។ ក្រុមប្រឹក្សាភិបាល ត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់គណៈគ្រប់គ្រង ដែលត្រូវបានតម្រូវឲ្យ៖

- អនុម័តនូវគោលនយោបាយគណនេយ្យ សមស្របដែលផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តគោលនយោបាយទាំងនេះជាអចិន្ត្រៃយ៍។
- អនុលោមតាមតម្រូវការនៃការលាតត្រដាង និងគោលការណ៍ណែនាំដែលចេញផ្សាយដោយស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRSs”) ឬ ប្រសិនបើមានគំលាតនៃការអនុវត្ត និងដើម្បីជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិត និងត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុនោះ គម្លាតទាំងនោះគួរតែត្រូវបានលាតត្រដាងជាព័ត៌មាន ពន្យល់ និងកំណត់ចំនួនទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុឲ្យបានសមរម្យ។
- ត្រួតពិនិត្យ និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។
- វាយតម្លៃសមត្ថភាពរបស់ធនាគារក្នុងការបន្តលើមូលដ្ឋាននិរន្តរភាព ការលាតត្រដាង តាមដែលអាចអនុវត្តបាន បញ្ហាដែលទាក់ទងនឹងមូលដ្ឋាននិរន្តរភាព និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លុះត្រាតែអ្នកគ្រប់គ្រងមានបំណងរំលាយធនាគារ ឬ បញ្ឈប់ប្រតិបត្តិការ ឬ មិនមានជម្រើសជាក់ស្តែងក្រៅពីត្រូវធ្វើ និង
- ការគ្រប់គ្រងដោយមានប្រសិទ្ធភាព និងដឹកនាំធនាគារ ប្រកបដោយប្រសិទ្ធភាពលើការសម្រេចចិត្តដែលអាចមានផលប៉ះពាល់ជាសារវន្តដល់ប្រតិបត្តិការ និងដំណើរការអាជីវកម្មរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការទាំងនេះ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលបញ្ជាក់ថា ពួកគេបានបំពេញ និងអនុវត្តតាមទំនួលខុសត្រូវខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ ជាក្រុមប្រឹក្សាភិបាល បានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដូចដែលមានភ្ជាប់ជាមួយនេះ ថាបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុ ហើយនិងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

**តំណាងក្រុមប្រឹក្សាភិបាល**

ឯកឧត្តមបណ្ឌិត ផាន់ ផល្លា
រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និងជាប្រធានក្រុមប្រឹក្សាភិបាល

បណ្ឌិត លឹម អូន
អគ្គនាយក និងជាអភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះ ៖ ភាគទុនិក នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក

### មតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក (“ធនាគារ”) ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ របាយការណ៍លទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន ព្រមទាំងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ ហើយនិងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRSs”)។

### មូលដ្ឋាននៃមតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា (“CISAs”)។ ការទទួលខុសត្រូវរបស់យើងខ្ញុំ យោងតាម CISAs ត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែកនៃ ការទទួលខុសត្រូវរបស់សវនករសម្រាប់សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានភាពឯករាជ្យពីធនាគារដោយយោងតាមក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុត ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃកម្ពុជា រួមជាមួយនឹងតម្រូវការផ្នែកសីលធម៌ដែលទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំ ក៏បានបំពេញនូវទំនួលខុសត្រូវផ្នែកសីលធម៌ផ្សេងទៀតរបស់យើងខ្ញុំ ដោយស្របទៅតាមតម្រូវការទាំងនេះ។ យើងខ្ញុំ ជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### ព័ត៌មានផ្សេងទៀតក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

ព័ត៌មានផ្សេងៗទៀតដែលទទួលបាន នាកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ រួមមានរបាយការណ៍របស់ ក្រុមប្រឹក្សាភិបាល។ គណៈគ្រប់គ្រង មានទំនួលខុសត្រូវ ចំពោះព័ត៌មានផ្សេងៗនេះ។

មតិយោបល់របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុពុំគ្របដណ្តប់លើព័ត៌មានផ្សេងៗនេះទេ ហើយយើងខ្ញុំក៏មិនបង្ហាញសេចក្តីសន្និដ្ឋានធានាអះអាងក្នុងទម្រង់ណាមួយទៅលើព័ត៌មានផ្សេងៗនេះដែរ។

ទាក់ទិននឹងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺការអានព័ត៌មានផ្សេងៗនេះ ហើយធ្វើការពិចារណា ថាតើព័ត៌មានផ្សេងៗនេះ មានភាពខុសគ្នាជាសារវន្ត ឬទេ ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបាននៅក្នុងការធ្វើសវនកម្ម ឬថាតើព័ត៌មានផ្សេងៗនេះ មានកំហុសឆ្គងជាសារវន្ត ឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងៗនេះ ដោយផ្អែកលើការងារដែលបានអនុវត្ត យើងខ្ញុំ តម្រូវឲ្យរាយការណ៍តាមភាពជាក់ស្តែង។ យើងខ្ញុំ ពុំមានអ្វីដែលតម្រូវឲ្យរាយការណ៍ចំពោះព័ត៌មានផ្សេងៗនេះទេ។





### ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាម CIFRSs ហើយនិងទទួលខុសត្រូវផងដែរចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃនិរន្តរភាពអាជីវកម្មរបស់ធនាគារ និងធ្វើការលាតត្រដាង (ប្រសិនបើមាន) នូវបញ្ហាទាំងឡាយណា ដែលទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យរបស់ធនាគារ លើកលែងតែក្នុងករណីគណៈគ្រប់គ្រងមានបំណងរំលាយ ឬបញ្ឈប់ប្រតិបត្តិការធនាគារ ឬក៏គ្មានមធ្យោបាយជាក់លាក់ណាមួយទៀតក្រៅពីនេះ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យមើលលើដំណើរនៃការរាយការណ៍អំពីហិរញ្ញវត្ថុរបស់ធនាគារ។

### ការទទួលខុសត្រូវរបស់សវនករសម្រាប់សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុ ទាំងមូលមិនមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៍របស់សវនករ ដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថាការងារសវនកម្មដែលប្រព្រឹត្តទៅដោយអនុលោមតាម CISAs តែងតែរកឃើញកំហុសឆ្គងជាសារវន្តដែលមាននោះទេ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាជាសារវន្ត ប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬបញ្ចូលគ្នាជារួម) អាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយនៃការងារសវនកម្មដែលអនុលោមតាម CISAs យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ បង្កើត និងអនុវត្តនីតិវិធីសវនកម្ម ដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និងសមស្របសម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំមានកម្រិតខ្ពស់ជាង ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គង ដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការបន្លំ ការលុបចេញដោយចេតនា ការរាយការណ៍មិនត្រឹមត្រូវ ឬមិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការងារសវនកម្មដើម្បីបង្កើតជានីតិវិធីសវនកម្ម ដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារទេ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀតដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើសេចក្តីសន្និដ្ឋានទៅលើភាពសមស្រប នៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យដោយគណៈគ្រប់គ្រង និងតាមរយៈភស្តុតាងសវនកម្មដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋាន ថាតើមានវត្តមាន នៃភាពមិនប្រាកដប្រជា ជាសារវន្ត ទាក់ទងនឹងព្រឹត្តិការណ៍ ឬកាលៈទេសៈទាំងឡាយណាដែលនាំឲ្យមានការសង្ស័យជាសារវន្តទៅលើនិរន្តរភាពនៃដំណើរការ

អាជីវកម្មរបស់ធនាគារ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានវត្តមាន នៃភាពមិនប្រាកដប្រជា ជាសារវន្ត យើងខ្ញុំតម្រូវឲ្យទាញចំណាប់អារម្មណ៍ក្នុងរបាយការណ៍សវនករលើកំណត់សម្គាល់ដែលពាក់ព័ន្ធ ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើកំណត់សម្គាល់នេះពុំមានលក្ខណៈគ្រប់គ្រាន់ទេនោះ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់ថ្ងៃចេញរបាយការណ៍សវនករ។ តែទោះជាយ៉ាងណាក៏ដោយព្រឹត្តិការណ៍ និងកាលៈទេសៈនាពេលអនាគត ក៏អាចបង្កឲ្យធនាគារ មិនអាចបន្តនិរន្តរភាពរបស់អាជីវកម្មបានផងដែរ។

- វាយតម្លៃការបង្ហាញទូទៅ មាតិកា និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងកំណត់សម្គាល់ផ្សេងៗ និងវាយតម្លៃថា របាយការណ៍ហិរញ្ញវត្ថុតំណាងឲ្យប្រតិបត្តិការ និងព្រឹត្តិការណ៍ដែលជាមូលដ្ឋានដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

ក្នុងចំណោមបញ្ហាដទៃទៀត យើងខ្ញុំបានធ្វើការទំនាក់ទំនងជាមួយអ្នកទទួលបន្ទុកលើអភិបាលកិច្ចអំពីវិសាលភាពដែលបានគ្រោងទុក និងពេលវេលានៃការងារសវនកម្ម និងរបកគំហើញសំខាន់ៗ រួមបញ្ចូលផងដែរនូវកង្វះខាតសំខាន់ៗទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលយើងខ្ញុំរកឃើញក្នុងពេលធ្វើសវនកម្ម។

ខារ ហុង
Associate Partner

**អឺនស្ទ៍ អែន យ៉ាំង (ខេមបូឌា)**
ក្រុមហ៊ុនគណនេយ្យករជំនាញ
សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣





# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ២០២២ | | ២០២១ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៥ | ៥៧០.៧៥០ | ២.៣៤៩.៧៧៨ | ៣៨៤.៧៣១ | ១.៥៦៧.៣៩៤ |
| សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា (“NBC”) | ៦ | ១២.៩៧០.៣៩៨ | ៥៣.៣៩៩.១២៩ | ៣១.៥៧០.៧៦៩ | ១២៨.៦១៩.៣១៣ |
| សមតុល្យជាមួយធនាគារផ្សេងៗ | ៧ | ៥០.៤៧៨.៣៨២ | ២០៧.៨១៩.៤៩៩ | ៦.០០៣.២១៣ | ២៤.៤៥៧.០៩០ |
| ឥណទាន និងបុរេប្រទានទៅអតិថិជន – សុទ្ធ | ៨ | ២១០.៥០០.៩៣២ | ៨៦៦.៦៣២.៣៣៧ | ១០៩.៣១១.៦៥១ | ៤៤៥.៣៣៥.៦៦៦ |
| ទ្រព្យសកម្មផ្សេងៗ | ៩ | ១៨២.៩៣៩ | ៧៥៣.១៥៩ | ៥៣.៤៥៥ | ២១៧.៧៧៦ |
| ទ្រព្យអរូបី | ១០ | ៧៨៩.៧២៧ | ៣.២៥១.៣០៦ | ៩០៧.១៨២ | ៣.៦៩៥.៨៥៩ |
| ទ្រព្យ និងបរិក្ខារ | ១១ | ១.៨០៨.៨៩៧ | ៧.៤៤៧.២២៩ | ៨៤៧.៥៨៧ | ៣.៤៥៣.០៦៩ |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ១២ | ២.២៩៥.១៩១ | ៩.៤៤៩.៣០១ | ១១២.២៣៨ | ៤៥៧.២៥៨ |
| បញ្ញើតម្កល់តាមបទប្បញ្ញត្តិ | ១៣ | ៣២១.៩៦៥ | ១.៣២៥.៥៣០ | ២២.៩៤៦ | ៩៣.៤៨២ |
| ពន្ធពន្យារជាទ្រព្យសកម្ម | ១៤ | ៨២០.៩៦៩ | ៣.៣៧៩.៩២៩ | - | - |
| **ទ្រព្យសកម្មសរុប** | | **២៨០.៧៤០.១៥០** | **១.១៥៥.៨០៧.១៩៧** | **១៤៩.២១៣.៧៧២** | **៦០៧.៨៩៦.៩០៧** |
| **បំណុល និងមូលធនរបស់ភាគទុនិក** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ១៥ | ៤៩.៤៦១ | ២០៣.៦៣១ | ១៥.៨៣៩ | ៦៤.៥២៨ |
| ប្រាក់បញ្ញើពីអតិថិជន | ១៦ | ៤.៦៦០.៥២៤ | ១៩.១៨៧.៣៧៧ | ៥០៤.៩៨០ | ២.០៥៧.២៨៩ |
| កម្ចី | ១៧ | ៧៤.០១៦.២៧៤ | ៣០៤.៧២៥.០០០ | - | - |
| បំណុលពន្ធលើប្រាក់ចំណូល | ១៤ | ២៥៣.០៦៩ | ១.០៤១.៨៨៥ | ៩.៨៨៩ | ៤០.២៨៨ |
| បំណុលផ្សេងៗ | ១៨ | ៨៨៤.៦៩១ | ៣.៦៤២.២៧៣ | ៣៦៩.៥០៧ | ១.៥០៥.៣៧១ |
| បំណុលភតិសន្យា | ១២ | ២.៣១០.៦១៨ | ៩.៥១២.៨១៤ | ៩៧.២៧៧ | ៣៩៦.៣០៦ |
| **បំណុលសរុប** | | **៨២.១៧៤.៦៣៧** | **៣៣៨.៣១២.៩៨០** | **៩៩៧.៤៩២** | **៤.០៦៣.៧៨២** |
| **មូលធនរបស់ភាគទុនិក** | | | | | |
| ដើមទុន | ១៩ | ២០០.០០០.០០០ | ៨០០.០០០.០០០ | ១៥០.០០០.០០០ | ៦០០.០០០.០០០ |
| វិភាគទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២០ | ១.២៤៦.៨៨២ | ៤.៩៨៧.៥២៨ | ១.៣០៨.០៨២ | ៥.២៣២.៣២៨ |
| ខាតបង្គរ | | (២.៦៨១.៣៦៩) | (១០.៩១២.៦២៤) | (៣.០៩១.៨០២) | (១២.៥៩០.០៦៣) |
| លម្អៀងបង្គរពីការបកប្រែរូបិយប័ណ្ណ | | - | ២៣.៤១៩.៣១៣ | - | ១១.១៩០.៨៦០ |
| **មូលធនរបស់ភាគទុនិកសរុប** | | **១៩៨.៥៦៥.៥១៣** | **៨១៧.៤៩៤.២១៧** | **១៤៨.២១៦.២៨០** | **៦០៣.៨៣៣.១២៥** |
| **បំណុល និងមូលធនរបស់ភាគទុនិកសរុប** | | **២៨០.៧៤០.១៥០** | **១.១៥៥.៨០៧.១៩៧** | **១៤៩.២១៣.៧៧២** | **៦០៧.៨៩៦.៩០៧** |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីលេខ ១ ដល់ ២៩ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# របាយការណ៍លទ្ធផលពេញលេញ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ២០២២ | | ២០២១ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ ២.៣) |
| **ចំណូលប្រតិបត្តិការ** | | | | | |
| ចំណូលការប្រាក់ | ២១ | ៦.៣៨៧.៨៥៩ | ២៦.១០៧.១៨០ | ២.១៨២.៥១៨ | ៨.៨៧៨.៤៨៣ |
| ចំណាយការប្រាក់ | ២១ | (៣៦.៣៤៥) | (១៤៨.៥៤២) | (៦.៣៨១) | (២៥.៩៥៨) |
| **ចំណូលការប្រាក់សុទ្ធ** | | ៦.៣៥១.៥១៤ | ២៥.៩៥៨.៦៣៨ | ២.១៧៦.១៣៧ | ៨.៨៥២.៥២៥ |
| កម្រៃ និងសេវាជើងសារសុទ្ធ | | ២៤.០៦២ | ៩៨.៣៤១ | ៤៦.២៨៩ | ១៨៨.៣០៤ |
| ខាតពីអត្រាប្តូរប្រាក់បរទេស | | (៥២៧.៧៩៥) | (២.១៥៧.០៩៨) | (១៩២.៥០០) | (៧៨៣.០៩០) |
| **ចំណូលពីប្រតិបត្តិការសរុប** | | ៥.៨៤៧.៧៨១ | ២៣.៨៩៩.៨៨១ | ២.០២៩.៩២៦ | ៨.២៥៧.៧៣៩ |
| ចំណាយបុគ្គលិក | ២២ | (១.៩៦៤.៦៤២) | (៨.០២៩.៤៩២) | (១.២៦៦.៦៤៥) | (៥.១៥២.៧១២) |
| រំលស់ | ២៣ | (១.០២៥.១៤៨) | (៤.១៨៩.៧៨០) | (៧៧០.៨៨៤) | (៣.១៣៥.៩៥៦) |
| ចំណាយប្រតិបត្តិការទូទៅ និងរដ្ឋបាល | ២៤ | (៩២៩.៧៩៩) | (៣.៨០០.០៨៩) | (៦២៧.២១៦) | (២.៥៥១.៥១៥) |
| សំវិធានធនលើការខាតបង់តណទានរំពឹងទុក | ៨ | (២.០២៨.៦០៧) | (៨.២៩០.៩១៧) | (១.០៣២.៩៩៨) | (៤.២០២.២៣៦) |
| **ខាតមុនគិតពន្ធ** | | (១០០.៤១៥) | (៤១០.៣៩៧) | (១.៦៦៧.៨១៧) | (៦.៧៨៤.៦៨០) |
| អត្ថប្រយោជន៍ (ចំណាយ) ពន្ធលើប្រាក់ចំណូល | ១៤ | ៥១០.៨៤៨ | ២.០៨៧.៨៣៦ | (២២.៥៣៥) | (៩១.៦៧២) |
| **ចំណេញ (ខាត) សុទ្ធ** | | ៤១០.៤៣៣ | ១.៦៧៧.៤៣៩ | (១.៦៩០.៣៥២) | (៦.៨៧៦.៣៥២) |
| **ធាតុចំណូលពេញលេញផ្សេងៗ៖** | | | | | |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | | - | ១២.២២៨.៤៥៣ | - | ៦.៥៨៧.១៥១ |
| **ចំណេញ (ខាត) សរុបសម្រាប់ការិយបរិច្ឆេទ** | | **៤១០.៤៣៣** | **១៣.៩០៥.៨៩២** | **(១.៦៩០.៣៥២)** | **(២៨៩.២០១)** |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីលេខ ១ ដល់ ២៩ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*





# របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | ដើមទុន | | វិភាគទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កំណត់សម្គាល់លេខ ២០) | | ខាតបង្គរ | | ទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់លេខ ៣.១៣) | | លម្អៀងពីការបកប្រែរូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ ២.៣) | ពាន់រៀល (កំណត់សម្គាល់លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់លេខ ២.៣) |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ១៥០.០០០.០០០ | ៦០០.០០០.០០០ | ១.៣០៨.០៨២ | ៥.២៣២.៣២៨ | (៣.០៩១.៨០២) | (១២.៥៩០.០៦៣) | - | - | ១១.១៩០.៨៦០ | ១៤៨.២១៦.២៨០ | ៦០៣.៨៣៣.១២៥ |
| ដើមទុនបន្ថែម | ៥០.០០០.០០០ | ២០០.០០០.០០០ | - | - | - | - | - | - | - | ៥០.០០០.០០០ | ២០០.០០០.០០០ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | - | - | - | - | ៤១០.៤៣៣ | ១.៦៧៧.៤៣៩ | - | - | - | ៤១០.៤៣៣ | ១.៦៧៧.៤៣៩ |
| ការប្រគល់សងវិភាគទានទៅ MEF (កំណត់សម្គាល់លេខ ២០) | - | - | (៦១.២០០) | (២៤៤.៨០០) | - | - | - | - | - | (៦១.២០០) | (២៤៤.៨០០) |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | - | - | - | - | - | ១២.២២៨.៤៥៣ | - | ១២.២២៨.៤៥៣ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **២០០.០០០.០០០** | **៨០០.០០០.០០០** | **១.២៤៦.៨៨២** | **៤.៩៨៧.៥២៨** | **(២.៦៨១.៣៦៩)** | **(១០.៩១២.៦២៤)** | **-** | **-** | **២៣.៤១៩.៣១៣** | **១៩៨.៥៦៥.៥១៣** | **៨១៧.៩៩៤.២១៧** |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ១០០.០០០.០០០ | ៤០០.០០០.០០០ | ១.៣០៨.០៨២ | ៥.២៣២.៣២៨ | (១.៤៣៨.៩៩២) | (៥.៨៦៤.៧៣១) | ៣៧.០៤២ | ១៥១.០២០ | ៤.៦០៣.៧០៩ | ៩៩.៩០៦.១៣២ | ៤០៤.១២២.៣២៦ |
| ដើមទុនបន្ថែម | ៥០.០០០.០០០ | ២០០.០០០.០០០ | - | - | - | - | - | - | - | ៥០.០០០.០០០ | ២០០.០០០.០០០ |
| ខាតសុទ្ធក្នុងការិយបរិច្ឆេទ | - | - | - | - | (១.៦៩០.៣៥២) | (៦.៨៧៦.៣៥២) | - | - | - | (១.៦៩០.៣៥២) | (៦.៨៧៦.៣៥២) |
| ការផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | ៣៧.០៤២ | ១៥១.០២០ | (៣៧.០៤២) | (១៥១.០២០) | - | - | - |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | - | - | - | - | - | ៦.៥៨៧.១៥១ | - | ៦.៥៨៧.១៥១ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **១៥០.០០០.០០០** | **៦០០.០០០.០០០** | **១.៣០៨.០៨២** | **៥.២៣២.៣២៨** | **(៣.០៩១.៨០២)** | **(១២.៥៩០.០៦៣)** | **-** | **-** | **១១.១៩០.៨៦០** | **១៤៨.២១៦.២៨០** | **៦០៣.៨៣៣.១២៥** |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីលេខ ១ ដល់ ២៩ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ២០២២ | | ២០២១ | |
|---|---|---|---|---|---|
| | | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់លេខ ២.៣)** | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់លេខ ២.៣)** |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ខាតមុនគិតពន្ធ | | (១០០.៤១៥) | (៤១០.៣៩៧) | (១.៦៦៧.៨១៧) | (៦.៧៨៤.៦៨០) |
| *ការកែតម្រូវលើ៖* | | | | | |
| រំលស់ | ២៣ | ១.០២៥.១៤៨ | ៤.១៨៩.៧៨០ | ៧៧០.៨៨៤ | ៣.១៣៥.៩៥៦ |
| ការសងវិភាគទានទៅ MEF | ២០ | (៦១.២០០) | (២៥០.១២៤) | - | - |
| សំវិធានធនលើការខាតបង់ឥណទានរំពឹងទុក | ៨ | ២.០២៨.៦០៧ | ៨.២៩០.៩១៧ | ១.៧៩៨.៩៩៨ | ៧.៣១៨.៣២៤ |
| ចំណាយការប្រាក់លើបំណុលភតិសន្យា | ១២ | ២៤.២៦៤ | ៩៩.១៦៧ | ៦.០៣១ | ២៤.៥៣៤ |
| *បម្រែបម្រួលនូវ៖* | | | | | |
| បញ្ញើតម្កល់តាមបទប្បញ្ញត្តិ | | (២៩៩.០១៩) | (១.២២២.០៩១) | (១៦.៩៥៧) | (៦៨.៩៨១) |
| សមតុល្យជាមួយធនាគារផ្សេងទៀត ដែលមានកាលកំណត់ដើមលើស ៣ខែ | ៧ | (១៧.២៥៣.១៦៣) | (៧០.៥១៣.៦៧៧) | (២.៦៣៤.០០០) | (១០.៧១៥.១១២) |
| ឥណទាន និងបុរេប្រទាន | ៨ | (១០៣.២១៧.៨៨៨) | (៤២១.៨៥១.៥០៨) | (៦៤.២៨៩.១៣៧) | (២៦១.៥២៨.២០៩) |
| ទ្រព្យសកម្មផ្សេងៗ | | (១៥២.៧៩៧) | (៦២៤.៤៨១) | ២៣.០០៤ | ៩៣.៥៨០ |
| បញ្ញើពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ១៥ | ៣៣.៦២២ | ១៣៧.៤១៣ | ១២.១៤៨ | ៤៩.៤១៨ |
| បញ្ញើពីអតិថិជន | ១៦ | ៤.១៥៥.៥៤៤ | ១៦.៩៨៣.៧០៨ | ៤៩៥.៣៧៨ | ២.០១៥.១៩៨ |
| បំណុលផ្សេងទៀត | ១៨ | ៥១៥.១៨៤ | ២.១០៥.៥៥៧ | (៩១.៤១០) | (៣៧១.៨៥៦) |
| **សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ** | | (១១៣.៣០២.១១៣) | (៤៦៣.០៦៥.៧៣៦) | (៦៥.៥៩២.៨៧៨) | (២៦៦.៨៣១.៨២៨) |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | ១៤ | (៦៦.៩៤១) | (២៧៣.៥៨៨) | (១៩.៨៤០) | (៨០.៧០៩) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | | (១១៣.៣៦៩.០៥៤) | (៤៦៣.៣៣៩.៣២៤) | (៦៥.៦១២.៧១៨) | (២៦៦.៩១២.៥៣៧) |
| **សកម្មភាពវិនិយោគ** | | | | | |
| *ការទិញ៖* | | | | | |
| ទ្រព្យ និងបរិក្ខារ | ១១ | (១.៥២៧.៦៤៤) | (៦.២៤៣.៤៨១) | (១៦៩.០៨០) | (៦៨៧.៨១៧) |
| កម្មវិធីកុំព្យូទ័រ | ១០ | (៧៨.១៥៤) | (៣១៩.៤១៥) | (៣១៦.១៩៤) | (១.២៨៦.២៧៧) |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | | (១.៦០៥.៧៩៨) | (៦.៥៦២.៨៩៦) | (៤៨៥.២៧៤) | (១.៩៧៤.០៩៤) |

| | កំណត់សម្គាល់ | ២០២២ | | ២០២១ | |
|---|---|---|---|---|---|
| | | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់លេខ ២.៣)** | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់លេខ ២.៣)** |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| *សាច់ប្រាក់ទទួលបានពី៖* | | | | | |
| ដើមទុនបន្ថែម | ១៩ | ៥០.០០០.០០០ | ២០៤.៣៥០.០០០ | ៥០.០០០.០០០ | ២០៣.៤០០.០០០ |
| កម្ចី | ១៧ | ៧៤.០១៦.២៧៤ | ៣០២.៥០៤.៥១២ | - | - |
| ការទូទាត់ភតិសន្យា | ១២ | (២៣៣.៧៦៨) | (៩៥៥.៤១០) | (១២៩.០៧៥) | (៥២៥.០៧៧) |
| **សាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញវត្ថុ** | | ១២៣.៧៨២.៥០៦ | ៥០៥.៨៩៩.១០២ | ៤៩.៨៧០.៩២៥ | ២០២.៨៧៤.៩២៣ |
| **ការកើនឡើង (ថយចុះ) សុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | ៨.៨០៧.៦៥៤ | ៣៥.៩៩៦.៨៨២ | (១៦.២២៧.០៦៧) | (៦៦.០១១.៧០៨) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមគ្រា** | | ៣៥.៣២៤.៧១៣ | ១៤៣.៩១២.៨៨១ | ៥១.៥៥១.៧៨០ | ២០៨.៥២៦.៩៥០ |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | | - | ១.៧៨៣.១៩២ | - | ១.៣៩៧.៦៣៩ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងគ្រា** | ៥ | **៤៤.១៣២.៣៦៧** | **១៨១.៦៩២.៩៥៥** | **៣៥.៣២៤.៧១៣** | **១៤៣.៩១២.៨៨១** |

*ព័ត៌មានបន្ថែមទៅលើលំហូរសាច់ប្រាក់ប្រតិបត្តិការដែលបានពីការប្រាក់៖*

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់លេខ ២.៣)** | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់លេខ ២.៣)** |
| ការប្រាក់ទទួលបាន | ៥.៧២៩.៦៦៤ | ២៣.៤១៧.១៣៧ | ២.១៨២.៥១៨ | ៨.៨៧៨.៤៨៣ |
| ការប្រាក់បានបង់ | ២៥.៥១២ | ១០៤.២៦៨ | ៦.០៨៩ | ២៤.៧៧០ |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីលេខ ១ ដល់ ២៩ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់

## ១. ព័ត៌មានអំពីសាជីវកម្ម

ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក ត្រូវបានបង្កើតឡើង ក្នុងព្រះរាជាណាចក្រកម្ពុជា ជាក្រុមហ៊ុនគ្រប់គ្រងដោយរដ្ឋ ដែលរៀបចំឡើងក្រោមច្បាប់ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ជាមួយនឹងវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន ០០០១ M/២០២០ ដែលចេញដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។ ធនាគារស្ថិតនៅក្រោមការត្រួតពិនិត្យបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (“MEF”)។

ធនាគារបានទទួលអាជ្ញាបណ្ណធនាគាររបស់ខ្លួនពីធនាគារជាតិនៃកម្ពុជា (“NBC”) នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ដើម្បីដំណើរការជាធនាគារពាណិជ្ជដែលមានសុពលភាពអចិន្ត្រៃយ៍។

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារគឺការផ្តល់ហិរញ្ញប្បទាន និងសេវាធនាគារពាណិជ្ជ ដើម្បីគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អាសយដ្ឋានរបស់ការិយាល័យចុះបញ្ជីរបស់ធនាគារ មានទីតាំងនៅអគារមជ្ឈមណ្ឌលអភិវឌ្ឍន៍ធុរកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដីឡូត៍លេខ អេស ផ្លូវអូស៊ីអាយស៊ី ភូមិកៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ធនាគារមានបុគ្គលិកចំនួន ១៤៤ នាក់ (២០២១៖ ៥២ បុគ្គលិក)។

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ

របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣។

## ២. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុបង្ហាញ ជាប្រាក់ដុល្លារអាមេរិក ត្រូវបានរៀបចំឡើងតាមមូលដ្ឋានថ្លៃដើម ប្រវត្តិសាស្រ្ត លើកលែងតែមានការចង្អុលបង្ហាញផ្សេងទៀត។

### ២.១ មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារត្រូវបានរៀបចំតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិរបស់កម្ពុជា (“CIFRSs”)។

### ២.២ ឆ្នាំសារពើពន្ធ

ឆ្នាំសារពើពន្ធរបស់ធនាគារ ចាប់ផ្តើមនៅថ្ងៃទី១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។

### ២.៣ រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

*រូបិយប័ណ្ណបង្ហាញ*

របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ការបង្ហាញរបស់ធនាគារ។

*ប្រតិបត្តិការ និងសមតុល្យ*

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងក្រៅពីដុល្លារអាមេរិក ត្រូវបានបកប្រែជាដុល្លារអាមេរិកតាមការកំណត់អត្រាប្តូរប្រាក់បរទេសនាកាលបរិច្ឆេទនៃប្រតិបត្តិការ។ ទ្រព្យសកម្មរូបិយវត្ថុ និងបំណុលដែលតំណាងឲ្យរូបិយប័ណ្ណផ្សេងក្រៅពីដុល្លារអាមេរិក ដែលមាននៅកាលបរិច្ឆេទរាយការណ៍ត្រូវបានបកប្រែជាដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនោះ។ ភាពខុសគ្នានៃការផ្លាស់ប្តូរដែលកើតឡើងលើការបកប្រែត្រូវបានទទួលស្គាល់ជាប្រាក់ចំណេញ ឬខាត។

*ការបកប្រែប្រាក់ដុល្លារអាមេរិកជាប្រាក់រៀល*

ការបកប្រែប្រាក់ដុល្លារអាមេរិក ទៅជាពាន់រៀល ត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដោយប្រើអត្រាចុងគ្រា និងអត្រាមធ្យមភាគសម្រាប់ការិយបរិច្ឆេទ។

ទ្រព្យសកម្ម និងបំណុលដែលរួមបញ្ចូលក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានបកប្រែតាមអត្រាចុងគ្រានាចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ ចំណែកឯចំណូល និងចំណាយដែលបង្ហាញ ក្នុងរបាយការណ៍លទ្ធផលពេញលេញត្រូវបានបកប្រែតាមអត្រាមធ្យមសម្រាប់ការិយបរិច្ឆេទបញ្ចប់។ រាល់ភាពខុសគ្នានៃលម្អៀងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។ ការបកប្រែបែបនេះមិនគួរត្រូវបានបកស្រាយថាជាតំណាងដែលចំនួនទឹកប្រាក់ដុល្លារអាមេរិកតំណាងឲ្យ ឬត្រូវបាន ឬអាចត្រូវបានបំប្លែងទៅជាប្រាក់រៀលក្នុងអត្រានោះ ឬអត្រាផ្សេងទៀតណាមួយឡើយ។ តម្លៃទាំងអស់ជាប្រាក់រៀល ត្រូវបានបង្គត់ទៅចំនួនជិតបំផុត ពាន់រៀល លើកលែងតែមានការចង្អុលបង្ហាញផ្សេងទៀត។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់រៀលដោយផ្អែកលើអត្រាប្តូរប្រាក់ ដែលអាចអនុវត្តបានក្នុង ១ ដុល្លារអាមេរិកដូចខាងក្រោម៖

| | ២០២២ | ២០២១ |
|---|---|---|
| អត្រានាចុងគ្រា | ៤.១១៧ | ៤.០៧៤ |
| អត្រាមធ្យម | ៤.០៨៧ | ៤.០៦៨ |

### ២.៤ ការបង្គត់នៃចំនួន

លើកលែងតែមានការចង្អុលបង្ហាញបើមិនដូច្នេះទេ ចំនួនទឹកប្រាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្គត់ទៅជាប្រាក់ដុល្លារ ដែលនៅជិតបំផុតសម្រាប់ចំនួនដុល្លារអាមេរិក និងជិតបំផុតពាន់រៀលសម្រាប់ប្រាក់រៀល។

### ២.៥ ស្តង់ដាថ្មី និងវិសោធនកម្ម និងការបកស្រាយ

គោលនយោបាយគណនេយ្យដែលបានអនុវត្ត គឺសមស្របជាមួយនឹងការិយបរិច្ឆេទហិរញ្ញវត្ថុពីមុន លើកលែងតែសេចក្តីប្រកាសគណនេយ្យថ្មីដូចខាងក្រោម ដែលធនាគារបានអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២។ ការអនុម័តប្រកាសទាំងនេះ មិនមានផលប៉ះពាល់ខ្លាំងណាមួយលើស្ថានភាពហិរញ្ញវត្ថុ ឬប្រតិបត្តិការរបស់ធនាគារទេ លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ។

- កិច្ចសន្យាមានការខាតបង់ - ចំណាយ នៃការបំពេញកិច្ចសន្យា - វិសោធនកម្មលើ CIAS ៣៧
- យោងទៅក្របខ័ណ្ឌគោលគំនិត - វិសោធនកម្មលើ CIFRS ៣
- ទ្រព្យ រោងចក្រ និងបរិក្ខារ៖ ទឹកប្រាក់ទទួលបានមុនពេលមានគម្រោងប្រើប្រាស់ - វិសោធនកម្មលើ CIAS ១៦ ភតិសន្យា
- CIFRS ១ ការអនុវត្តលើកដំបូង នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ក្រុមហ៊ុនបុត្រសម្ព័ន្ធជាអ្នកអនុវត្តលើកដំបូង

- CIFRS ៩ ឧបករណ៍ហិរញ្ញវត្ថុ - កម្រៃ '១០%' ដើម្បីធ្វើតេស្តសម្រាប់ការឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ
- CIAS ៤១ កសិកម្ម - ពន្ធក្នុងការវាស់វែងតម្លៃសមស្រប

## ២.៦ ស្តង់ដាបានចេញផ្សាយ ដែលមិនទាន់ចូលជាធរមាន

ស្តង់ដា និងការបកស្រាយដែលត្រូវបានចេញផ្សាយ ប៉ុន្តែមិនទាន់ចូលជាធរមាន រហូតដល់ថ្ងៃចេញរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានបង្ហាញដូចខាងក្រោម។ ស្តង់ដាទាំងនេះ និងវិសោធនកម្មចំពោះ CIFRSs ដែលត្រូវបានចេញ ប៉ុន្តែមិនទាន់ចូលជាធរមាន មិនត្រូវបានរំពឹងថានឹងមានផលប៉ះពាល់ខ្លាំងទៅលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារនោះទេ។

*ចូលជាធរមានចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ តទៅ៖*

- CIFRS ១៧ - កិច្ចសន្យាធានារ៉ាប់រង
- វិសោធនកម្មលើ CIAS ១ - ការអនុវត្តជាលើកដំបូង នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា - ចំណាត់ថ្នាក់នៃបំណុលចរន្ត និងអចរន្ត
- វិសោធនកម្មលើ CIAS ១ - ការអនុវត្តជាលើកដំបូងនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងសេចក្តីថ្លែងការណ៍ពីការអនុវត្ត CIFRS លើការអនុវត្តរបាយការណ៍ទី២ ការវិនិច្ឆ័យសំខាន់ៗ - ការបង្ហាញ នៃគោលនយោបាយគណនេយ្យ
- វិសោធនកម្ម CIAS ៨ - គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរការសន្មតគណនេយ្យ និងកំហុស - និយមន័យនៃការសន្មតគណនេយ្យ
- វិសោធនកម្មលើ CIAS ១២ - ពន្ធលើប្រាក់ចំណូល - ពន្ធពន្យារទាក់ទងនឹងទ្រព្យសកម្ម និងបំណុលដែលកើតឡើងពីប្រតិបត្តិការតែមួយ។

# ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ

## ៣.១ សាច់ប្រាក់ និងសមមូលសាច់ប្រាក់

សមតុល្យសាច់ប្រាក់ និងសាច់ប្រាក់ មានដូចជាសាច់ប្រាក់នៅក្នុងដៃ សមតុល្យគ្មានការរឹតត្បិតជាមួយធនាគារជាតិនៃកម្ពុជា សមតុល្យជាមួយធនាគារផ្សេងទៀត និងទ្រព្យហិរញ្ញវត្ថុដែលមានលំហូរសាច់ប្រាក់ខ្ពស់ ដែលមានកាលកំណត់ដើមបីខែ ឬ តិចជាងនេះចាប់ពីថ្ងៃទិញ ដែលប្រឈមនឹងហានិភ័យតិចតួចនៃការផ្លាស់ប្តូរនៅក្នុងដែលតម្លៃសមរម្យ និងត្រូវបានប្រើប្រាស់ដោយធនាគារក្នុងការគ្រប់គ្រងការសន្យារយៈពេលខ្លីរបស់ខ្លួន។

## ៣.២ ឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុរបស់ធនាគាររួមមានសាច់ប្រាក់នៅក្នុងដៃ សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា (លើកលែងតែប្រាក់បញ្ញើតាមច្បាប់) សមតុល្យជាមួយធនាគារផ្សេងទៀត ឥណទាន និងបុរេប្រទានដល់អតិថិជន ទ្រព្យផ្សេងទៀត (លើកលែងតែប្រាក់បញ្ញើ ដែលមិនអាចដកវិញបាន និងការទូទាត់ជាមុន) ប្រាក់បញ្ញើពីស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត ប្រាក់បញ្ញើពីអតិថិជន កម្ចី និងបំណុលផ្សេងទៀត (លើកលែងតែពន្ធដែលត្រូវបង់) ដែលត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ តាមគំរូអាជីវកម្មដែលបានពិភាក្សានៅក្នុងកំណត់សម្គាល់លេខ ៣.២.១។

*ការទទួលស្គាល់ និងការវាស់វែងដំបូង*

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នៅពេលដែលធនាគារក្លាយជាភាគីនៃបទប្បញ្ញត្តិកិច្ចសន្យារបស់ឧបករណ៍។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងជាបឋមតាមតម្លៃសមស្រប។ ការចំណាយលើប្រតិបត្តិការដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការទិញ នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ក្រៅពីទ្រព្យសកម្មហិរញ្ញវត្ថុ





និងបំណុលហិរញ្ញវត្ថុក្នុងតម្លៃសមស្របតាមរយៈប្រាក់ចំណេញ ឬ ខាត) ត្រូវបានបញ្ចូលទៅក្នុង ឬ កាត់ចេញពីតម្លៃសមស្រប នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ បំណុលហិរញ្ញវត្ថុ ទៅតាមភាពសមស្រប តាមការទទួលស្គាល់ដំបូង។

ប្រសិនបើតម្លៃប្រតិបត្តិការខុសពីតម្លៃសមស្របនៅពេលទទួលស្គាល់ដំបូង ធនាគារនឹងគណនាភាពខុសគ្នាដូចខាងក្រោម៖

- ប្រសិនបើតម្លៃសមស្រប ត្រូវបានបង្ហាញដោយតម្លៃដែលបានដកស្រង់នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬ បំណុលដូចគ្នា ឬ ផ្អែកលើបច្ចេកទេសវាយតម្លៃដែលប្រើតែទិន្នន័យពីទីផ្សារដែលអាចសង្កេតបាន នោះភាពខុសគ្នាត្រូវបានទទួលស្គាល់ជាប្រាក់ចំណេញ ឬ ខាតលើការទទួលស្គាល់ដំបូង (ពោលគឺ ប្រាក់ចំណេញថ្ងៃទី ១ ឬ ខាត)
- ក្នុងគ្រប់ករណីផ្សេងទៀត តម្លៃសមស្របនឹងត្រូវបានកែតម្រូវ ដើម្បីនាំឲ្យស្របទៅនឹងតម្លៃប្រតិបត្តិការ (ឧទាហរណ៍ ប្រាក់ចំណេញ ឬ ការបាត់បង់នៅថ្ងៃទី១ នឹងត្រូវពន្យារពេលដោយបញ្ចូលវាទៅក្នុងតម្លៃយោងដំបូង នៃទ្រព្យសកម្ម ឬ បំណុល)។

### ៣.២.១ គំរូអាជីវកម្ម

ធនាគារ វាស់វែងសមតុល្យជាមួយធនាគារជាតិនៃកម្ពុជា (លើកលែងតែប្រាក់បញ្ញើតាមច្បាប់) សមតុល្យជាមួយធនាគារផ្សេងទៀត ឥណទាន និងបុរេប្រទានដល់អតិថិជន និងទ្រព្យសកម្មផ្សេងទៀត (លើកលែងតែប្រាក់បញ្ញើដែលមិនអាចដកវិញបាន និងការទូទាត់ជាមុន) តាមតម្លៃរំលស់ដោយផ្អែកលើគំរូអាជីវកម្ម ឬ ការគ្រប់គ្រងនៃលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្ម នៅពេលដែលលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានកាន់កាប់ក្នុងគំរូអាជីវកម្មដែល មានគោលបំណងរក្សាទ្រព្យសកម្មហិរញ្ញវត្ថុដើម្បីប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា។
- លក្ខខណ្ឌកិច្ចសន្យា នៃទ្រព្យសកម្មហិរញ្ញវត្ថុផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ដែលទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") តាមប្រាក់ដើមដែលនៅសល់។

ព័ត៌មានលម្អិតនៃលក្ខខណ្ឌទាំងនេះត្រូវបានរៀបរាប់ខាងក្រោម។

ធនាគារធ្វើការវាយតម្លៃលើគោលបំណង នៃគំរូអាជីវកម្មដែលទ្រព្យសកម្ម ត្រូវបានកាន់កាប់នៅកម្រិតផលប័ត្រ ដែលឆ្លុះបញ្ចាំងយ៉ាងល្អបំផុតពីរបៀបដែលទ្រព្យសកម្មត្រូវបានគ្រប់គ្រង។ កត្តាដែលបានពិចារណារួមមាន៖

- គោលនយោបាយ និងគោលបំណងដែលបានចែងសម្រាប់ផលប័ត្រ និង ការអនុវត្តជាក់ស្តែងនៃគោលនយោបាយទាំងនោះ។ ជាពិសេស ថាតើយុទ្ធសាស្រ្តរបស់អ្នកគ្រប់គ្រងផ្តោតលើការទទួលបានប្រាក់ចំណូលការប្រាក់តាមកិច្ចសន្យា រក្សាទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ធ្វើឲ្យបន្សុីគ្នារវាងរយៈពេល នៃទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹងរយៈពេល នៃបំណុលដែលជាហិរញ្ញប្បទាន ដល់ទ្រព្យសកម្មទាំងនោះ ឬ ដឹងពីលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម។
- របៀបក្នុងការវាយតម្លៃលទ្ធផល នៃផលប័ត្រ និងវិធីរាយការណ៍ទៅគណៈគ្រប់គ្រងរបស់ធនាគារ។
- ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងយុទ្ធសាស្រ្តសម្រាប់របៀប គ្រប់គ្រងហានិភ័យទាំងនោះត្រូវបានគ្រប់គ្រង។
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មត្រូវបានផ្តល់ការទូទាត់ (ឧ. ថាតើការទូទាត់គឺផ្អែកលើតម្លៃសមរម្យនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬ លំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលប្រមូលបាន) និង
- ភាពញឹកញាប់ បរិមាណ និងពេលវេលានៃការលក់ក្នុងគ្រាមុន ហេតុផលសម្រាប់ការលក់បែបនេះ និងការរំពឹងទុករបស់វាអំពីសកម្មភាពលក់នាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពលក់មិនត្រូវបានយកមកពិចារណា ដាច់ដោយឡែកនោះទេ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃទាំងមូល នៃវិធីសាស្រ្តដែល ធនាគារបានចែងអំពីគោលបំណងសម្រាប់ការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានសម្រេច និងរបៀបដែលលំហូរសាច់ប្រាក់ត្រូវបានទទួល។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលរក្សាទុកសម្រាប់ការជួញដូរ ឬ គ្រប់គ្រង ហើយលទ្ធផលរបស់ទ្រព្យសម្បត្តិនោះ ត្រូវបានវាយតម្លៃលើមូលដ្ឋានតម្លៃសមស្របត្រូវបានវាស់វែងនៅ FVTPL ព្រោះទ្រព្យសកម្មទាំងនោះមិនត្រូវបានទុកសម្រាប់ដើម្បីប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា ឬ រក្សាទុកទាំងការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និងសម្រាប់លក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើយ។

## ៣.២.២ គោលការណ៍តេស្តតាមការទូទាត់ប្រាក់ដើម និងការប្រាក់ (“SPPI”)

ជាជំហានទីពីរនៃដំណើរការចាត់ថ្នាក់របស់ខ្លួន ធនាគារវាយតម្លៃលក្ខខណ្ឌកិច្ចសន្យា នៃទ្រព្យសកម្មហិរញ្ញវត្ថុដើម្បីកំណត់ថា តើពួកគេបំពេញតាមការធ្វើតេស្ត SPPI ដែរ ឬ ទេ។

សម្រាប់គោលបំណងនៃការវាយតម្លៃនេះ 'ប្រាក់ដើម' ត្រូវបានកំណត់ថាជាតម្លៃសមស្រប នៃទ្រព្យសកម្មហិរញ្ញវត្ថុនៅលើការទទួលស្គាល់ដំបូង។ 'ការប្រាក់' ត្រូវបានកំណត់ថាជាការពិចារណាលើតម្លៃពេលវេលានៃទឹកប្រាក់ និងសម្រាប់ហានិភ័យឥណទានដែលទាក់ទងនឹងចំនួនទឹកប្រាក់ដើមដែលជាប់ជំពាក់ក្នុងអំឡុងពេលជាក់លាក់ណាមួយ និងសម្រាប់ហានិភ័យ និងការចំណាយលើប្រាក់កម្ចីជាមូលដ្ឋានផ្សេងទៀត (ឧទាហរណ៍ ហានិភ័យសន្ទនីយភាព និងការចំណាយរដ្ឋបាល) រួមទាំងកម្រិត ប្រាក់ចំណេញ។

ក្នុងការវាយតម្លៃថា តើលំហូរសាច់ប្រាក់តាមកិច្ចសន្យាជា SPPI ដែរ ឬ ទេ ធនាគារពិចារណាលើលក្ខខណ្ឌកិច្ចសន្យានៃឧបករណ៍។ នេះរួមបញ្ចូលទាំងការវាយតម្លៃថា តើទ្រព្យសកម្មហិរញ្ញវត្ថុមានលក្ខខណ្ឌកិច្ចសន្យា ដែលអាចផ្លាស់ប្តូរពេលវេលា ឬ ចំនួនលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលវានឹងមិនបំពេញតាមលក្ខខណ្ឌនេះ។

ក្នុងការវាយតម្លៃ ធនាគារពិចារណា៖

- ព្រឹត្តិការណ៍យថាហេតុដែលនឹងផ្លាស់ប្តូរចំនួន និងពេលវេលានៃលំហូរសាច់ប្រាក់
- លក្ខណៈពិសេសអានុភាព
- លក្ខខណ្ឌបង់ប្រាក់មុនកាលកំណត់ និងការពន្យារពេលសង
- លក្ខខណ្ឌ ដែលកំណត់ក្នុងការទាមទាររបស់ធនាគារចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម ជាក់លាក់ (ឧ. ឥណទានមានទ្រព្យដាក់បញ្ចាំជាក់លាក់) និង
- លក្ខណៈពិសេស ដែលកែប្រែការពិចារណាលើតម្លៃទឹកប្រាក់នៃពេលវេលា (ឧ. ការកំណត់អត្រាការប្រាក់ឡើងវិញតាមកាលកំណត់)។

***ឥណទានមានទ្រព្យដាក់បញ្ចាំជាក់លាក់***

ក្នុងករណីខ្លះ ឥណទានដែលធ្វើឡើងដោយធនាគារ ត្រូវបានធានាដោយវត្ថុបញ្ចាំរបស់អ្នកខ្ចី បានកម្រិតការទាមទាររបស់ធនាគារចំពោះលំហូរសាច់ប្រាក់នៃវត្ថុបញ្ចាំ (ឥណទានដែលមានទ្រព្យដាក់បញ្ចាំជាក់លាក់)។ ធនាគារធ្វើការវិនិច្ឆ័យក្នុងការវាយតម្លៃថា តើឥណទាននោះបំពេញតាមលក្ខខណ្ឌ SPPI ដែរ ឬទេ។ ធនាគារជាធម្មតាពិចារណាព័ត៌មានខាងក្រោមនៅពេលធ្វើការវិនិច្ឆ័យនេះ៖

- ថាតើការរៀបចំកិច្ចសន្យាមានបញ្ជាក់ច្បាស់ពី ចំនួន និងកាលបរិច្ឆេទនៃការបង់ប្រាក់ជាសាច់ប្រាក់នៃឥណទានដែរ ឬទេ។
- តម្លៃសមរម្យនៃវត្ថុបញ្ចាំដែលទាក់ទងទៅនឹងចំនួន នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការធានា។
- សមត្ថភាព និងឆន្ទៈរបស់អ្នកខ្ចីក្នុងការទូទាត់តាមកិច្ចសន្យា ទោះបីជាមានការធ្លាក់ចុះនៃតម្លៃវត្ថុបញ្ចាំក៏ដោយ។
- ថាតើអ្នកខ្ចីគឺជាបុគ្គល ឬអង្គភាពប្រតិបត្តិការសំខាន់ៗ ឬ ជាអង្គភាពដែលមានគោលបំណងពិសេស។
- ហានិភ័យ នៃការបាត់បង់របស់ធនាគារលើទ្រព្យសកម្មទាក់ទងទៅនឹងឥណទានដែលមានទ្រព្យដាក់បញ្ចាំពេញលេញ
- វិសាលភាពដែលវត្ថុបញ្ចាំបង្ហាញ ទាំងអស់ ឬ មួយភាគធំនៃទ្រព្យសកម្មរបស់អ្នកខ្ចី និង
- ថាតើធនាគារនឹងទទួលបានអត្ថប្រយោជន៍ពីការកើនឡើងតម្លៃណាមួយ ពីទ្រព្យសកម្មមូលដ្ឋានទេ។





***ការចាត់ថ្នាក់ឡើងវិញ នៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ***

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានចាត់ថ្នាក់ឡើងវិញបន្ទាប់ពីការទទួលស្គាល់ដំបូងឡើយ លើកលែងតែក្នុងរយៈពេលបន្ទាប់ពីធនាគារផ្លាស់ប្តូរគំរូអាជីវកម្ម របស់ខ្លួនសម្រាប់ការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

## ៣.២.៣ ការឈប់ទទួលស្គាល់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

***ទ្រព្យសកម្មហិរញ្ញវត្ថុ***

ធនាគារនឹងឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិក្នុងកិច្ចសន្យាចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬផ្ទេរសិទ្ធិក្នុងការទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការដែលក្នុងនោះហានិភ័យនិងផលចំណេញ នៃភាពជាម្ចាស់នៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរ ឬដែលធនាគារមិនផ្ទេរ ឬមិនរក្សាទុកនូវហានិភ័យនិងផលចំណេញ ទាំងអស់នៃភាពជាម្ចាស់ ហើយមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុឡើយ។

នៅពេលដែលមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពខុសគ្នារវាងតម្លៃយោង នៃទ្រព្យសកម្ម (ឬ តម្លៃយោងដែលបានបែងចែកទៅផ្នែកនៃទ្រព្យសកម្ម ដែលត្រូវបានឈប់ទទួលស្គាល់) និងផលបូកនៃ (i) តម្លៃតបស្នងដែលទទួលបាន (រួមទាំងទ្រព្យសកម្មថ្មីដែលទទួលបានដកចេញនូវបំណុលថ្មីដែលបានសន្មត) និង (ii) ផលចំណេញ ឬ ការបាត់បង់បង្គរដែលត្រូវបានទទួលស្គាល់នៅក្នុង OCI ត្រូវបានទទួលស្គាល់ជាប្រាក់ចំណេញ ឬខាត។

***បំណុលហិរញ្ញវត្ថុ***

បំណុលហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់នៅពេលដែលកាតព្វកិច្ចនូវបំណុលត្រូវបានបោះបង់ចោល លុបចោល ឬផុតកំណត់។ នៅពេលដែលបំណុលហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយអ្នកផ្សេងទៀតពីអ្នកឲ្យខ្ចីដូចគ្នាក្នុងលក្ខខណ្ឌខុសគ្នាខ្លាំង ឬ លក្ខខណ្ឌនៃការទទួលខុសត្រូវដែលមានស្រាប់ត្រូវបានកែប្រែ ការផ្លាស់ប្តូរឬការកែប្រែនេះត្រូវបានចាត់ទុកថាជា ការឈប់ទទួលស្គាល់បំណុលដើម ហើយទទួលស្គាល់បំណុលថ្មី។ ភាពខុសគ្នារវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដើម និងការពិចារណាដែលបានបង់ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬ ខាត។

## ៣.២.៤ ការកែប្រែ និងការពន្យារពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះធនាគារនឹងវាយតម្លៃថា តើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែមានភាពខុសគ្នាខ្លាំង ឬយ៉ាងណា។

ប្រសិនបើលំហូរសាច់ប្រាក់មានភាពខុសប្លែកគ្នាខ្លាំង នោះសិទ្ធិក្នុងកិច្ចសន្យាចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវបានចាត់ទុកថាបានផុតកំណត់ហើយ។ ក្នុងករណីនេះ ទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវបានឈប់ទទួលស្គាល់ ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មីត្រូវបានទទួលស្គាល់ដោយតម្លៃសមស្រប បូកនឹងតម្លៃប្រតិបត្តិការដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ រាល់កម្រៃដែលទទួលបានជាផ្នែកនៃការកែប្រែត្រូវគិតដូចខាងក្រោម៖

- កម្រៃសេវាដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងកម្រៃដែលតំណាងឲ្យការទូទាត់សងថ្លៃប្រតិបត្តិការ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានរួមបញ្ចូលនៅក្នុងការវាស់វែងដំបូង នៃទ្រព្យសកម្ម។ និង
- កម្រៃផ្សេងទៀតត្រូវបានរួមបញ្ចូលនៅក្នុងប្រាក់ចំណេញ និងខាត ដែលជាផ្នែកនៃប្រាក់ចំណេញ ឬ ខាតលើការឈប់ទទួលស្គាល់។ ប្រសិនបើលំហូរសាច់ប្រាក់ត្រូវបានកែប្រែ នៅពេលដែលអ្នកខ្ចីមានការលំបាកផ្នែកហិរញ្ញវត្ថុ នោះគោលបំណងនៃការកែប្រែជាទូទៅ គឺទទួលបានមកវិញជាអតិបរិមានូវលក្ខខណ្ឌនៃកិច្ចសន្យាដើម ជាជាងបង្កើតទ្រព្យសកម្មថ្មីជាមួយនឹងលក្ខខណ្ឌខុសគ្នាខ្លាំង។ ប្រសិនបើធនាគារមានគម្រោងកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយ ដែលនាំឲ្យមានការលើកលែងចំពោះលំហូរសាច់ប្រាក់ នោះដំបូងគេនឹងពិចារណាថាតើផ្នែកមួយនៃទ្រព្យសកម្មគួរតែត្រូវបានលុបចេញពីបញ្ជី ការកែប្រែកើតឡើង ឬទេ (សូមមើលខាងក្រោមសម្រាប់គោលការណ៍កាត់ចេញ)។ វិធីសាស្ត្រនេះ ជះឥទ្ធិពលដល់លទ្ធផលនៃការវាយតម្លៃបរិមាណ និងមានន័យថា លក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ជាធម្មតាមិនត្រូវបានបំពេញនៅក្នុងករណីបែបនេះទេ។

- ប្រសិនបើការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃរំលស់ ឬ FVOCI មិនបណ្តាលឲ្យមានការឈប់ទទួលស្គាល់ ទ្រព្យសកម្មហិរញ្ញវត្ថុទេ នោះធនាគារនឹងគណនាឡើងវិញនូវតម្លៃយោងសរុបដុល នៃទ្រព្យសកម្មហិរញ្ញវត្ថុដោយប្រើប្រាស់អត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម ហើយទទួលស្គាល់លទ្ធផលនៃការកែតម្រូវជា ចំណេញ ឬ ខាតក្នុងរបាយការណ៍ចំណេញ និងខាត។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ប្រែប្រួល អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាការកែប្រែចំណេញ ឬ ការខាតត្រូវបានកែសម្រួលដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលនៃការកែប្រែ។ រាល់ការចំណាយ ឬ កម្រៃដែលបានកើតឡើង និងកម្រៃដែលបានទទួលជាផ្នែកនៃការកែប្រែ ធ្វើការកែតម្រូវតម្លៃយោងសរុបដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែ ហើយត្រូវបានរំលស់ក្នុងរយៈពេលដែលនៅសល់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែ។
- ប្រសិនបើការកែប្រែបែបនេះ ត្រូវបានអនុវត្តដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុរបស់អ្នកខ្ចី នោះប្រាក់ចំណេញ ឬ ខាតត្រូវបានបង្ហាញរួមជាមួយនឹងខាតអ៊ីមភែរមិន។ ក្នុងករណីផ្សេងទៀត វាត្រូវបានបង្ហាញជាចំណូលការប្រាក់ដែលបានគណនាដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

## ៣.២.៥ ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កងគ្នា ហើយត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុង របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ហើយនៅពេលដែលធនាគារមានសិទ្ធិស្របច្បាប់ក្នុងការកាត់កងចំនួននេះបាន និងមានបំណងទូទាត់លើមូលដ្ឋានសុទ្ធ ឬដើម្បីកំណត់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

## ៣.២.៦ ការវាស់វែងតម្លៃសមស្រប

'តម្លៃសមស្រប' គឺជាតម្លៃដែលនឹងត្រូវបានទទួលនៅពេលលក់ទ្រព្យសកម្ម ឬបានបង់ដើម្បីផ្ទេរបំណុលក្នុងប្រតិបត្តិការ រវាងអ្នកចូលរួមក្នុងទីផ្សារនៅកាលបរិច្ឆេទវាស់វែងក្នុងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអាទិភាពបំផុត ដែលធនាគារអាចកំណត់រកបាននៅក្នុងកាលបរិច្ឆេទដែលវាស់វែង។ តម្លៃសមស្របនៃបំណុលឆ្លុះបញ្ចាំងពីហានិភ័យ មិនមែនប្រតិបត្តិការរបស់វា។

នៅពេលដែលមាន ធនាគារវាស់វែងតម្លៃសមស្របនៃឧបករណ៍ដោយប្រើប្រាស់តម្លៃដែលបានដកស្រង់នៅក្នុងទីផ្សារសកម្មសម្រាប់ឧបករណ៍នោះ។ ទីផ្សារត្រូវបានចាត់ទុកថាជា 'សកម្ម' ប្រសិនបើប្រតិបត្តិការសម្រាប់ទ្រព្យសកម្ម ឬបំណុលកើតឡើងញឹកញាប់ និងបរិមាណគ្រប់គ្រាន់ដើម្បីផ្តល់ព័ត៌មានតម្លៃនៅលើមូលដ្ឋានដែលកំពុងបន្ត។

ប្រសិនបើមិនមានតម្លៃបានប្រកាសនៅក្នុងទីផ្សារសកម្មទេ នោះធនាគារប្រើបច្ចេកទេសវាយតម្លៃដែលបង្កើនការប្រើប្រាស់អតិបរមា នៃធាតុចូលដែលអាចសង្កេតបាន និងកាត់បន្ថយការប្រើប្រាស់ធាតុចូលដែលមិនអាចអង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើសរួមបញ្ចូលកត្តាទាំងអស់ដែលអ្នកចូលរួមទីផ្សារនឹងគិតគូរក្នុងការកំណត់តម្លៃប្រតិបត្តិការមួយ។

ភស្តុតាងដ៏ល្អបំផុតនៃតម្លៃសមស្រប នៃឧបករណ៍ហិរញ្ញវត្ថុនៅលើការទទួលស្គាល់ដំបូង ជាធម្មតាគឺតម្លៃប្រតិបត្តិការ - ពោលគឺតម្លៃសមស្របនៃចំនួនប្រាក់ដែលបានផ្តល់ឲ្យ ឬទទួលបាន។ ប្រសិនបើធនាគារកំណត់ថាតម្លៃសមស្របលើការទទួលស្គាល់ដំបូងខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្រប មិនត្រូវបានបង្ហាញ ដោយតម្លៃដកស្រង់នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬបំណុលដូចគ្នា ឬផ្អែកលើបច្ចេកទេសវាយតម្លៃដែលធាតុចូលដែលមិនអាចសង្កេតបានណាមួយត្រូវបានវិនិច្ឆ័យ មិនសំខាន់ទាក់ទងនឹងការវាស់វែង នោះឧបករណ៍ហិរញ្ញវត្ថុត្រូវបានវាស់វែងដំបូងនៅតម្លៃសមស្រប កែតម្រូវដើម្បីពន្យារភាពខុសគ្នារវាងតម្លៃសមស្រប លើការទទួលស្គាល់ដំបូង និងតម្លៃប្រតិបត្តិការ។ ក្រោយមក ភាពខុសគ្នានោះត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ និងខាតដោយផ្អែកលើមូលដ្ឋានសមស្របមួយក្នុងអាយុកាល នៃឧបករណ៍នេះ ប៉ុន្តែមិនលើសពីពេលដែលការវាយតម្លៃ ត្រូវបានគាំទ្រទាំងស្រុងដោយទិន្នន័យទីផ្សារដែលអាចសង្កេតបាន ឬប្រតិបត្តិការត្រូវបានបិទ។

ប្រសិនបើទ្រព្យសកម្ម ឬបំណុលដែលវាស់វែងដោយតម្លៃសមស្របមានតម្លៃដេញថ្លៃ និងតម្លៃសួរ នោះធនាគារវាស់វែងទ្រព្យសកម្ម និងស្ថានភាពរយៈពេលវែងក្នុងតម្លៃដេញថ្លៃ និងបំណុល និងស្ថានភាពរយៈពេលខ្លីក្នុងតម្លៃសួរ។





ផលប័ត្រនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលប្រឈមនឹងហានិភ័យទីផ្សារ និងហានិភ័យឥណទានដែលត្រូវបានគ្រប់គ្រង ដោយធនាគារដោយផ្អែកលើមូលដ្ឋាននៃការប៉ះពាល់សុទ្ធលើទីផ្សារ ឬ ហានិភ័យឥណទានត្រូវបានវាស់វែងដោយផ្អែកលើតម្លៃដែលនឹងទទួលបានពីការលក់ក្នុងស្ថានភាពវែងសុទ្ធ (ឬ បានបង់ដើម្បីផ្ទេរស្ថានភាពខ្លីសុទ្ធ) សម្រាប់ហានិភ័យជាក់លាក់។ ការកែតម្រូវកម្រិតផលប័ត្រ - ឧ. ការកែតម្រូវការដេញថ្លៃ ឬ ការកែតម្រូវហានិភ័យឥណទានដែលឆ្លុះបញ្ចាំងពីការវាស់វែងដោយផ្អែកលើការប៉ះពាល់សុទ្ធ - ត្រូវបានបែងចែកទៅឲ្យទ្រព្យសកម្ម និងបំណុលនីមួយៗដោយផ្អែកលើការកែតម្រូវហានិភ័យ ដែលទាក់ទងនៃឧបករណ៍នីមួយៗនៅក្នុងផលប័ត្រ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុដែលមានលក្ខណៈតម្រូវការពិសេស (ឧ. ប្រាក់បញ្ញើតាមតម្រូវការ) គឺមិនតិចជាងចំនួនដែលត្រូវបង់សងតាមតម្រូវការ ដោយបញ្ចុះតម្លៃចាប់ពីថ្ងៃដំបូង ដែលចំនួនទឹកប្រាក់អាចតម្រូវបង់។

ធនាគារ ទទួលស្គាល់ការផ្ទេរប្រាក់ រវាងដំណាក់កាលនៃឋានានុក្រមតម្លៃសមស្របនៅចុងការិយបរិច្ឆេទនៃរយៈពេលរបាយការណ៍កំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

## ៣.២.៧ ការខាតបង់ឥណទានដែលរំពឹងទុក ("ECLs")

ធនាគារទទួលស្គាល់នូវការខាតបង់ សម្រាប់ ការខាតបង់ឥណទានដែលបានរំពឹងទុក (“ECLs”) លើឧបករណ៍ហិរញ្ញវត្ថុដូចខាងក្រោមដែលមិនត្រូវបានវាស់តាមថ្លៃដើមរំលស់។

- សមតុល្យជាមួយធនាគារផ្សេងទៀត
- ឥណទាន និងបុរេប្រទានដល់អតិថិជន និង
- ការសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុដែលបានចេញ។

ECLs ត្រូវបានតម្រូវឲ្យវាស់វែងតាមរយៈសំវិធានធនលើការខាតបង់ដែលមានចំនួនស្មើនឹង៖

- ECL រយៈពេល ១២ខែ ពោល គឺ ECL ពេញមួយអាយុកាល ដែលកើតចេញពីព្រឹត្តិការណ៍មិនមានលទ្ធភាពសងប្រាក់នៅលើឧបករណ៍ហិរញ្ញវត្ថុដែលអាចធ្វើទៅបានក្នុងរយៈពេល ១២ខែបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ (សំដៅដល់ដំណាក់កាលទី ១) ឬ
- ECL ពេញមួយអាយុកាល ពោល គឺ ECL ពេញមួយអាយុកាល ដែលកើតចេញពីព្រឹត្តិការណ៍មិនមានលទ្ធភាពសងប្រាក់ក្នុង អាយុកាលរំពឹងទុកនៃឧបករណ៍ហិរញ្ញវត្ថុ (ហៅថាដំណាក់កាលទី ២ និងដំណាក់កាលទី ៣)។

សំវិធានធនខាតបង់សម្រាប់ ECL ពេញមួយអាយុកាល ត្រូវតម្រូវឲ្យមានសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ប្រសិនបើហានិភ័យឥណទានលើឧបករណ៍ហិរញ្ញវត្ថុនោះបានកើនឡើង ហើយជះឥទ្ធិពលខ្លាំង ចាប់តាំងពីការទទួលស្គាល់ដំបូង។ សម្រាប់ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតទាំងអស់ ECLs ត្រូវបានវាស់វែងក្នុងចំនួនទឹកប្រាក់ស្មើនឹង ECL រយៈពេល ១២ខែ។ ព័ត៌មានលម្អិតបន្ថែមអំពីការកំណត់នៃការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទានត្រូវបានផ្តល់ជូនខាងក្រោម។

ECLs គឺជាការប៉ាន់ប្រមាណដែលបានថ្លឹងតាមប្រូបាប៊ីលីតេនៃតម្លៃបច្ចុប្បន្ននៃការបាត់បង់ឥណទាន។ ECLs ត្រូវបានវាស់ជាតម្លៃបច្ចុប្បន្ន នៃភាពខុសគ្នារវាងលំហូរសាច់ប្រាក់យោងតាមកិច្ចសន្យាធនាគារ និងលំហូរសាច់ប្រាក់ដែលធនាគាររំពឹងថានឹងទទួលបានដែលកើតឡើងពីការថ្លឹងថ្លែងនៃសេណារីយ៉ូសេដ្ឋកិច្ចនាពេលអនាគតជាច្រើន ដោយបញ្ចុះតម្លៃនៅ EIR របស់ទ្រព្យសកម្ម។

- សម្រាប់ការសន្យាឥណទានដែលមិនបានប្រើប្រាស់ ECL គឺជាភាពខុសគ្នារវាងតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលជំពាក់ ធនាគារ ប្រសិនបើការសន្យាឥណទានត្រូវបានប្រើប្រាស់ និងលំហូរសាច់ប្រាក់ ដែលធនាគាររំពឹងថានឹងទទួលបានប្រសិនបើ ឥណទានត្រូវបានដកចេញ និង
- សម្រាប់កិច្ចសន្យាធានាហិរញ្ញវត្ថុ ECL គឺជាភាពខុសគ្នារវាងការទូទាត់ដែលរំពឹងទុកដើម្បីទូទាត់សងអ្នកកាន់កាប់ឧបករណ៍បំណុលដែលត្រូវបានធានា ដកចេញនូវចំនួនទឹកប្រាក់ដែលធនាគាររំពឹងថានឹងទទួលបានពីអ្នកកាន់កូនបំណុល ឬ ភាគីផ្សេងទៀត។

ធនាគារវាស់វែង ECL លើមូលដ្ឋានបុគ្គល ឬ ផ្អែកលើមូលដ្ឋានសមូហភាពសម្រាប់ផលប័ត្រឥណទាន ដែលចែករំលែកលក្ខណៈហានិភ័យសេដ្ឋកិច្ចស្រដៀងគ្នា។ ការវាស់វែង នៃសំវិធានធនលើការខាតបង់ គឺផ្អែកលើតម្លៃបច្ចុប្បន្ន នៃលំហូរ

សាច់ប្រាក់ដែលរំពឹងទុករបស់ទ្រព្យសកម្មដោយប្រើ EIR ដើមរបស់ទ្រព្យសកម្ម ដោយមិនគិតពីថា តើវាត្រូវបានវាស់វែងលើមូលដ្ឋានបុគ្គល ឬ មូលដ្ឋានសមូហភាពនោះទេ។

### *ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាន*

ទ្រព្យសកម្មហិរញ្ញវត្ថុមាន 'ឱនភាពនៃតម្លៃឥណទាន' នៅពេលដែលព្រឹត្តិការណ៍មួយ ឬ ច្រើនដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគត នៃទ្រព្យសកម្មហិរញ្ញវត្ថុបានកើតឡើង។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការអន់ថយឥណទានត្រូវបានសំដៅថាជាទ្រព្យសកម្មដំណាក់កាលទី ៣។ ភស្តុតាងនៃអ៊ីមតៃរមិននៃឥណទានរួមមានទិន្នន័យ ដែលអាចសង្កេតបានអំពីព្រឹត្តិការណ៍ខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុជាសារវន្ត របស់អ្នកខ្ចី ឬ អ្នកបោះផ្សាយ
- ការរំលោភកិច្ចសន្យាដូចជាការខកខានសង ឬ ហួសកាលបរិច្ឆេទកំណត់
- អ្នកអោយខ្ចីរបស់អ្នកខ្ចី សម្រាប់ហេតុផលសេដ្ឋកិច្ច ឬ កិច្ចសន្យាដែលទាក់ទងនឹងការលំបាកផ្នែកហិរញ្ញវត្ថុរបស់អ្នកខ្ចី ដោយបានផ្តល់សម្បទានដល់អ្នកខ្ចីដែលមិនបានពិចារណា។
- ការបាត់បង់នៃទីផ្សារសកម្មមួយចំពោះទ្រព្យដាក់បញ្ចាំដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ ឬ
- ការទិញទ្រព្យសកម្មហិរញ្ញវត្ថុ ដោយមានការបញ្ចុះតម្លៃយ៉ាងច្រើនដែលឆ្លុះបញ្ចាំងពីការខាតបង់ឥណទានដែលបានកើតឡើង។

វាប្រហែលជាមិនអាចកំណត់អត្តសញ្ញាណព្រឹត្តិការណ៍ដាច់ដោយឡែកតែមួយបានទេ ផ្ទុយទៅវិញ ឥទ្ធិពលរួមបញ្ចូលគ្នានៃព្រឹត្តិការណ៍ ជាច្រើនអាចបណ្តាលឲ្យទ្រព្យសកម្មហិរញ្ញវត្ថុក្លាយជាឱនភាពនៃតម្លៃឥណទាន។ ធនាគារ វាយតម្លៃថាតើឧបករណ៍បំណុលដែលជាទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងដោយតម្លៃរំលស់ ឬ FVTOCI ត្រូវបានអន់ថយនៃតម្លៃឥណទាននៅកាលបរិច្ឆេទរាយការណ៍នីមួយៗ។ ដើម្បីវាយតម្លៃថាតើឧបករណ៍បំណុលរបស់រដ្ឋ និងសាជីវកម្មមានឱនភាពនៃតម្លៃឥណទាន ធនាគារពិចារណាលើកត្តាមួយចំនួនដូចជា ទិន្នផលសញ្ញាប័ណ្ណ ចំណាត់ថ្នាក់ឥណទាន និងសមត្ថភាពរបស់អ្នកខ្ចីក្នុងការប្រមូលមូលនិធិ។

ឥណទានត្រូវបានចាត់ទុកថាមានឱនភាពនៅពេល ដែលសម្បទានត្រូវបានផ្តល់ទៅឲ្យអ្នកខ្ចីដោយសារការថយចុះនៃស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី លុះត្រាតែមានភស្តុតាងថាជាលទ្ធផលនៃការផ្តល់សម្បទានហានិភ័យ នៃការមិនទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាបានកាត់បន្ថយយ៉ាងខ្លាំង និងមិនមានសូចនាករផ្សេងទៀតនៃភាពអន់ថយទេ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលសម្បទានត្រូវបានគិតគូរ ប៉ុន្តែមិនត្រូវបានផ្តល់ ទ្រព្យសកម្មត្រូវបានចាត់ទុកថាមានឱនភាពឥណទាន នៅពេលដែលមានភស្តុតាងដែលអាចសង្កេតបាននៃឱនភាពឥណទាន រួមទាំងការបំពេញតាមនិយមន័យនៃការដែលគ្មានលទ្ធភាពសង។

និយមន័យនៃការគ្មានលទ្ធភាពសង (សូមមើលខាងក្រោម) រួមបញ្ចូលការមិនទំនងក្នុងការបង់ប្រាក់សូចនាករ និងការឈប់សម្រាក ប្រសិនបើចំនួនលើសកំណត់សម្រាប់រយៈពេល ៩០ថ្ងៃ ឬ ច្រើនជាងនេះ។

### *និយមន័យនៃការគ្មានលទ្ធភាពសង*

សារៈសំខាន់ចំពោះការកំណត់របស់ ECL គឺជានិយមន័យនៃការគ្មានលទ្ធភាពសង ។ និយមន័យនៃការគ្មានលទ្ធភាពសងបានប្រើក្នុងការវាស់បរិមាណ ECL និងក្នុងការកំណត់ថាតើសំវិធានធនលើខាតបង់ គឺផ្អែកលើ ECL ១២ ខែ ឬ ពេញមួយអាយុកាល ដោយសារការគ្មានលទ្ធភាពសង គឺជាធាតុផ្សំនៃប្រូបាប៊ីលីតេ នៃការខកខានសង("PD") ដែលប៉ះពាល់ដល់ទាំង ការវាស់វែងនៃ ECLs និងការកំណត់អត្តសញ្ញាណ នៃការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន។

ធនាគារចាត់ទុកចំណុចដូចខាងក្រោមនេះថាជាព្រឹត្តិការណ៍នៃការគ្មានលទ្ធភាពសង៖

- អ្នកខ្ចីផុតកំណត់សងលើសពី ៩០ ថ្ងៃលើកាតព្វកិច្ចឥណទានណាមួយដល់ធនាគារ។ ឬ
- អ្នកខ្ចីទំនងជាមិនអាចបង់កាតព្វកិច្ចឥណទានរបស់ខ្លួនដល់ធនាគារពេញលេញទេ។





និយមន័យនៃការគ្មានលទ្ធភាពសងនេះ ត្រូវបានប្រើដោយធនាគារសម្រាប់គោលបំណងគណនេយ្យ ក៏ដូចជាសម្រាប់គោលបំណងគ្រប់គ្រងហានិភ័យឥណទានខាងក្នុង ហើយត្រូវបានតម្រឹមយ៉ាងទូលំទូលាយទៅនឹងនិយមន័យបទប្បញ្ញត្តិនៃការគ្មានលទ្ធភាពសង។ និយមន័យ នៃការគ្មានលទ្ធភាពសង ត្រូវបានកែសម្រួលយ៉ាងសមស្របដើម្បីឆ្លុះបញ្ចាំងពីលក្ខណៈផ្សេងៗ នៃប្រភេទទ្រព្យសកម្មផ្សេងៗគ្នា។ ឥណទានវិបារូបណ៍ត្រូវបានចាត់ទុកថាហួសកាលកំណត់សងនៅពេលដែលអតិថិជនបានបំពានដែនកំណត់ដែលបានណែនាំ ឬត្រូវបានណែនាំពីដែនកំណត់តូចជាងចំនួនបច្ចុប្បន្នដែលមិនទាន់សង។

នៅពេលវាយតម្លៃថាតើអ្នកខ្ចីទំនងជាមិនបង់កាតព្វកិច្ចឥណទានរបស់ខ្លួនទេ ធនាគារត្រូវគិតគូរទាំងសូចនាករគុណភាព និងបរិមាណ។ ព័ត៌មានដែលបានវាយតម្លៃអាស្រ័យលើប្រភេទ នៃទ្រព្យសកម្ម ឧទាហរណ៍ក្នុងការផ្តល់ឥណទានសាជីវកម្ម សូចនាករគុណភាព ដែលត្រូវបានប្រើ គឺជាការរំលោភលើកិច្ចព្រមព្រៀង ដែលមិនពាក់ព័ន្ធសម្រាប់ការផ្តល់ឥណទានលក់រាយ។ សូចនាករបរិមាណ ដូចជាស្ថានភាពហួសកាលកំណត់សង និងការមិនបង់ប្រាក់លើកាតព្វកិច្ចផ្សេងទៀតរបស់ភាគីដូចគ្នា គឺជាធាតុចូលសំខាន់នៅក្នុងការវិភាគនេះ។ ធនាគារប្រើប្រាស់ប្រភពព័ត៌មានជាច្រើនប្រភេទ ដើម្បីវាយតម្លៃការខកខានសងដែលត្រូវបានបង្កើតឡើងពីខាងក្នុង ឬទទួលបានពីប្រភពខាងក្រៅ។ ដូចដែលបានកត់សម្គាល់នៅក្នុងនិយមន័យ នៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានអ៊ីមតៃរមិនឥណទានខាងលើ ការគ្មានលទ្ធភាពសង គឺជាភស្តុតាងដែលបង្ហាញថាទ្រព្យសកម្មមួយត្រូវបានអន់ថយនៃតម្លៃឥណទាន។ ដូច្នេះ អ៊ីមតៃរមិនទ្រព្យសកម្មឥណទាននឹងរាប់បញ្ចូលទាំងទ្រព្យសកម្មដែលគ្មានលទ្ធភាពសង ប៉ុន្តែក៏នឹងរួមបញ្ចូលផងដែរនូវទ្រព្យសកម្មផ្សេងទៀតដែល មានលទ្ធភាពសង ដែលបានផ្តល់ឲ្យនិយមន័យនៃអ៊ីមតៃរមិន ឥណទាន គឺទូលំទូលាយជាងនិយមន័យនៃការគ្មានលទ្ធភាពសង។

### *ការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន*

ធនាគារ តាមដានទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ ការសន្យាឥណទានដែលបានចេញ និងកិច្ចសន្យាធានាហិរញ្ញវត្ថុដែលស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវនៃអ៊ីមតៃរមិន ដើម្បីវាយតម្លៃថាតើមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង។ ប្រសិនបើមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន ធនាគារនឹងវាស់វែងសំវិធានធនខាតបង់ដោយផ្អែកលើអាយុកាលជាជាង ECL រយៈពេល ១២ខែ។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានហានិភ័យឥណទាន 'ទាប' នៅកាលបរិច្ឆេទរាយការណ៍ ត្រូវបានចាត់ទុកថាមិនមានការកើនឡើងយ៉ាងខ្លាំង នៃហានិភ័យឥណទាន។ ជាលទ្ធផល ធនាគារតាមដានរាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ការសន្យាផ្តល់ឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុ ដែលទទួលរងអ៊ីមតៃរមិនសម្រាប់ការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន។

ក្នុងការវាយតម្លៃថាតើហានិភ័យឥណទាន លើឧបករណ៍ហិរញ្ញវត្ថុបានកើនឡើងយ៉ាងខ្លាំងចាប់តាំងពីការទទួលស្គាល់ដំបូង ធនាគារប្រៀបធៀបហានិភ័យនៃការគ្មានលទ្ធភាពសងកើតឡើងលើឧបករណ៍ហិរញ្ញវត្ថុនៅកាលបរិច្ឆេទរាយការណ៍ដោយផ្អែកលើអាយុកាលកំណត់ ដែលនៅសល់របស់ឧបករណ៍ ជាមួយនឹងហានិភ័យ នៃការគ្មានលទ្ធភាពសងកើតឡើងហើយ ត្រូវបានរំពឹងទុកសម្រាប់កាលវសាន្ត ដែលនៅសល់នៅកាលបរិច្ឆេទ នៃរបាយការណ៍បច្ចុប្បន្ន ដែលឧបករណ៍ហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ជាលើកដំបូង។ ក្នុងការវាយតម្លៃនេះ ធនាគារពិចារណាទាំងព័ត៌មានបរិមាណ និងគុណភាព ដែលសមហេតុផល និងអាចគាំទ្របាន រួមទាំងបទពិសោធន៍ពីមុនៗ និងព័ត៌មានដែលមើលទៅមុខ ដែលអាចរកបានដោយមិនចាំបាច់ចំណាយ ឬ កិច្ចខិតខំប្រឹងប្រែង ដោយផ្អែកលើបទពិសោធន៍កន្លងមករបស់ធនាគារ និងជំនាញការវាយតម្លៃឥណទាន រួមទាំងព័ត៌មានដែលអាចកើតមានឡើងពេលខាងមុខ។

សេណារីយ៉ូសេដ្ឋកិច្ចជាច្រើនបង្កើតជាមូលដ្ឋាន នៃការកំណត់ប្រូបាប៊ីលីតេនៃការខកខានសងនៅពេលទទួលស្គាល់ដំបូង និងនៅកាលបរិច្ឆេទរាយការណ៍ជាបន្តបន្ទាប់។ សេណារីយ៉ូសេដ្ឋកិច្ចផ្សេងគ្នានឹងនាំឲ្យមានប្រូបាប៊ីលីតេខុសគ្នានៃការគ្មានលទ្ធភាពសង។ ការថ្លឹងថ្លែងនៃសេណារីយ៉ូផ្សេងៗគ្នាទាំងនេះ ដែលបង្កើតជាមូលដ្ឋាននៃប្រូបាប៊ីលីតេមធ្យមដែលមានទម្ងន់នៃការគ្មានលទ្ធភាពសងដែលត្រូវបានប្រើដើម្បីកំណត់ថា តើហានិភ័យឥណទានបានកើនឡើងយ៉ាងខ្លាំង ឬ អត់។

សម្រាប់ការផ្តល់ឥណទានសាជីវកម្ម ព័ត៌មានដែលត្រូវការរួមមានការរំពឹងទុកនាពេលអនាគតនៃវិស័យដែលសមភាគីធនាគារដំណើរការ ទទួលបានពីរបាយការណ៍អ្នកជំនាញសេដ្ឋកិច្ច អ្នកវិភាគហិរញ្ញវត្ថុ ស្ថាប័នរដ្ឋាភិបាល ស្ថាប័ន

គិតគូរដែលពាក់ព័ន្ធ និងអង្គការស្រដៀងគ្នាផ្សេងទៀត ក៏ដូចជាការពិចារណាលើប្រភពខាងផ្ទៃក្នុងផ្សេងៗ និងប្រភពខាងក្រៅនៃព័ត៌មានសេដ្ឋកិច្ចជាក់ស្តែង និងការព្យាករណ៍ព័ត៌មានសេដ្ឋកិច្ច។ សម្រាប់ការលក់រាយ ការផ្តល់ព័ត៌មានឥណទានដែលមើលទៅមុខ រួមមានការព្យាករណ៍សេដ្ឋកិច្ចដូចគ្នា ទៅនឹងការផ្តល់ឥណទានសាជីវកម្មជាមួយនឹងការព្យាករណ៍បន្ថែម នៃសូចនាករសេដ្ឋកិច្ចក្នុងស្រុក ជាពិសេសសម្រាប់តំបន់ដែលមានការប្រមូលផ្តុំទៅឧស្សាហកម្មជាក់លាក់ ក៏ដូចជាព័ត៌មានដែលបានបង្កើតផ្ទៃក្នុងនៃឥរិយាបថទូទាត់របស់អតិថិជន។ ធនាគារបែងចែកសមភាគីរបស់ខ្លួនទៅក្នុងចំណាត់ថ្នាក់ហានិភ័យឥណទានផ្ទៃក្នុង ដែលពាក់ព័ន្ធ អាស្រ័យលើគុណភាពឥណទានរបស់ពួកគេ។ ព័ត៌មានបរិមាណ គឺជាសូចនាករចម្បងនៃការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន ហើយផ្អែកលើការផ្លាស់ប្តូរនៅក្នុង PD ពេញមួយអាយុកាលដោយការប្រៀបធៀប៖

- PD ពេញមួយអាយុកាលដែលនៅសល់នៅកាលបរិច្ឆេទរាយការណ៍ ជាមួយ
- PD ពេញមួយអាយុកាលដែលនៅសេសសល់សម្រាប់ចំណុចនេះនៅក្នុងពេលវេលា ដែលត្រូវបានប៉ាន់ប្រមាណដោយផ្អែកលើការពិត និងកាលៈទេសៈនៅពេលនៃការទទួលស្គាល់ដំបូងនៃការប៉ះពាល់។

PDs ដែលត្រូវបានប្រើប្រាស់គឺមានការរំពឹងទុក ហើយធនាគារប្រើវិធីសាស្ត្រ និងទិន្នន័យដូចគ្នាដែលត្រូវបានប្រើដើម្បីវាស់ស្ទង់ការខាតបង់សម្រាប់ ECL។ កត្តាគុណភាពដែលបង្ហាញពីការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទានត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគំរូ PD ទាន់ពេលវេលា។ ទោះជាយ៉ាងណាក៏ដោយ ធនាគារនៅតែពិចារណាដាច់ដោយឡែកពីគ្នានូវកត្តាគុណភាពមួយចំនួន ដើម្បីវាយតម្លៃថាតើហានិភ័យឥណទានមានការកើនឡើងគួរឲ្យកត់សម្គាល់ដែរ ឬទេ។ សម្រាប់ការផ្តល់ឥណទានសាជីវកម្ម មានការផ្តោតជាពិសេសទៅលើទ្រព្យសកម្ម ដែលត្រូវបានបញ្ចូលក្នុង 'បញ្ជីតាមដាន' ដែលបានផ្តល់ឲ្យការលេចចេញនូវបញ្ជីតាមដាន នៅពេលដែលមានការព្រួយបារម្ភថាភាពសក្តិសម នៃឥណទានរបស់ដៃគូជាក់លាក់បានធ្លាក់ចុះ។ សម្រាប់ការផ្តល់ឥណទានលក់រាយ ធនាគារពិចារណាលើការរំពឹងទុកនៃការពន្យាពេលនិងរយៈពេលលើកលែងនៃការទូទាត់ ពិន្ទុឥណទាន និងព្រឹត្តិការណ៍នានាដូចជា ភាពអត់ការងារធ្វើ ការក្ស័យធន ការលែងលះ ឬ មរណភាព។

ដោយសារការកើនឡើងយ៉ាងខ្លាំង នៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង គឺជាវិធានការទាក់ទង ការផ្លាស់ប្តូរដែលបានផ្តល់ឲ្យក្នុងន័យដាច់ខាតនៅក្នុង PD នឹងមានសារៈសំខាន់ជាងសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមាន PD ដំបូងទាបជាងបើប្រៀបធៀបទៅនឹងឧបករណ៍ហិរញ្ញវត្ថុដែលមាន PD ខ្ពស់ជាង។

នៅពេលដែលទ្រព្យសកម្មមួយបានហួសកំណត់ ៣០ថ្ងៃ ធនាគារពិចារណាថាការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទានបានកើតឡើង ហើយទ្រព្យសកម្មស្ថិតនៅក្នុងដំណាក់កាលទី ២ នៃគំរូអ៊ឹមតែរមែន ពោលគឺ ការខាតបង់ត្រូវបានវាស់វែងជា ECL ពេញមួយអាយុកាល។ លើសពីនេះ ឥណទានដែលត្រូវបានវាយតម្លៃជាលក្ខណៈបុគ្គល និងត្រូវបានដាក់បញ្ចូលក្នុងបញ្ជីតាមដាន គឺស្ថិតនៅក្នុងដំណាក់កាលទី ២ នៃគំរូអ៊ឹមតែរមែន។ ដូចដែលបានកត់សម្គាល់ប្រសិនបើមានភស្តុតាង នៃការថយចុះឥណទាន ទ្រព្យសកម្មគឺស្ថិតនៅដំណាក់កាលទី ៣ នៃគំរូនៃអ៊ឹមតែរមិន។

### *ការលុបចោល*

ឥណទាន និងមូលបត្របំណុលត្រូវបានលុបចោល នៅពេលដែលធនាគារមិនមានការរំពឹងទុកសមហេតុផលក្នុងការប្រមូលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុ (ទាំងស្រុង ឬ មួយផ្នែករបស់វា)។ នេះគឺជាករណីនៅពេលដែលធនាគារកំណត់ថាអ្នកខ្ចីមិនមានទ្រព្យសកម្ម ឬ ប្រភពនៃប្រាក់ចំណូលដែលអាចបង្កើតលំហូរសាច់ប្រាក់គ្រប់គ្រាន់ដើម្បីសងបំណុលតាមចំនួនដែលត្រូវលុបចេញ។ ការលុបចេញបង្កើតបានជាព្រឹត្តិការណ៍មិនទទួលស្គាល់។ ធនាគារ អាចអនុវត្តសកម្មភាពចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានលុបចោល។ ទឹកប្រាក់ដែលប្រមូលបានមកវិញពីចំនួនបានលុបចេញពីបញ្ជី ដែលកើតចេញពីសកម្មភាពអនុវត្តរបស់ធនាគារនឹងបណ្តាលឲ្យចំណេញអ៊ឹមតែរមែន ដែលនឹងត្រូវបានបង្ហាញនៅក្នុង "ការបាត់បង់អ៊ឹមតែរមិនសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ/ប្រាក់ចំណូលផ្សេងទៀត" នៅក្នុងប្រាក់ចំណេញ ឬ ការបាត់បង់។





### *ការបង្ហាញសំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ*

សំវិធានធនសម្រាប់ខាតបង់ ECL ត្រូវបានបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដូចខាងក្រោម៖

- សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលវាស់វែងតាមតម្លៃដើមរំលស់៖ ជាការកាត់ចេញពីតម្លៃយោងសរុបនៃទ្រព្យសកម្ម
- សម្រាប់ការសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុ៖ ជាការផ្តល់សំវិធានធន និង
- ក្នុងករណីដែលឧបករណ៍ហិរញ្ញវត្ថុរួមបញ្ចូលទាំងធាតុផ្សំដែលបានប្រើប្រាស់ និងមិនទាន់បានប្រើប្រាស់ ហើយធនាគារមិនអាចកំណត់អត្តសញ្ញាណ ECL លើធាតុផ្សំ នៃការសន្យាឥណទានដោយឡែកពីសមាសធាតុដែលបានប្រើប្រាស់នោះទេ៖ ធនាគារបង្ហាញសំវិធានធនខាតបង់រួមគ្នាសម្រាប់សមាសភាគទាំងពីរ។ ចំនួនទឹកប្រាក់រួមបញ្ចូលគ្នាត្រូវបានបង្ហាញ ជាការកាត់ចេញពីចំនួនសរុបដុលនៃតម្លៃយោងនៃធាតុដែលបានដកចេញ។ រាល់ការលើស នៃសំវិធានធនបាត់បង់លើសពីចំនួនសរុប នៃសមាសភាគដែលបានប្រើប្រាស់ ត្រូវបានបង្ហាញជាសំវិធានធន។

## ៣.២.៨ បំណុលហិរញ្ញវត្ថុ និងមូលធន

បំណុល និងឧបករណ៍មូលធនដែលត្រូវបានបោះផ្សាយបានចាត់ថ្នាក់ជាបំណុលហិរញ្ញវត្ថុ ឬ ជាភាគហ៊ុនស្របតាមខ្លឹមសារនៃការរៀបចំកិច្ចសន្យា។

បំណុលហិរញ្ញវត្ថុ គឺជាកាតព្វកិច្ចតាមកិច្ចសន្យាក្នុងការប្រគល់សាច់ប្រាក់ ឬ ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ឬ ផ្លាស់ប្តូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬ បំណុលហិរញ្ញវត្ថុជាមួយអង្គភាពមួយផ្សេងទៀតក្រោមលក្ខខណ្ឌដែលអាចមិនអំណោយផលដល់ធនាគារ ឬ កិច្ចសន្យាដែលនឹង ឬ អាចនឹងត្រូវទូទាត់នៅក្នុងឧបករណ៍ភាគហ៊ុនផ្ទាល់ខ្លួនរបស់ធនាគារ និង គឺជាកិច្ចសន្យាដែលមិនមែនជានិស្សន្ទវត្ថុដែលធនាគារមាន ឬ អាចមានកាតព្វកិច្ចផ្តល់ចំនួនអថេរ នៃឧបករណ៍មូលធនរបស់ខ្លួន ឬ កិច្ចសន្យានិស្សន្ទវត្ថុលើភាគហ៊ុនផ្ទាល់ខ្លួនដែលនឹង ឬ អាចត្រូវបានទូទាត់ក្រៅពីការផ្លាស់ប្តូរសាច់ប្រាក់ថេរ (ឬ ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត) សម្រាប់ចំនួនថេរនៃឧបករណ៍មូលធនផ្ទាល់ខ្លួនរបស់ធនាគារ។

ឧបករណ៍មូលធន គឺជាកិច្ចសន្យាណាមួយដែលបង្ហាញពីការប្រាក់ដែលនៅសេសសល់នៅក្នុងទ្រព្យសកម្មរបស់អង្គភាពបន្ទាប់ពីកាត់បំណុលទាំងអស់របស់ខ្លួន។

ឧបករណ៍មូលធនដែលចេញដោយធនាគារ ត្រូវបានទទួលស្គាល់នៅប្រាក់ចំណូលដែលទទួលបានដកចេញនូវចំណាយផ្ទាល់។ ការទិញឧបករណ៍មូលធនផ្ទាល់ខ្លួនឡើងវិញរបស់ធនាគារត្រូវបានទទួលស្គាល់ និងកាត់ដោយផ្ទាល់នៅក្នុងមូលធន។ គ្មានការចំណេញ/ខាតណាមួយត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬ ការបាត់បង់លើការទិញ ការលក់ ការចេញ ឬ ការលុបចោលឧបករណ៍ភាគហ៊ុនផ្ទាល់ខ្លួនរបស់ធនាគារនោះទេ។

### *បំណុលហិរញ្ញវត្ថុផ្សេងទៀត*

បំណុលហិរញ្ញវត្ថុផ្សេងទៀត រួមទាំងការខ្ចីប្រាក់ត្រូវបានវាស់វែងជាបឋមតាមតម្លៃសមស្របដកចេញនូវថ្លៃប្រតិបត្តិការ។ បំណុលហិរញ្ញវត្ថុផ្សេងទៀតត្រូវបានវាស់វែងជាបន្តបន្ទាប់ក្នុងតម្លៃដើមរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

### *ចំណេញ និងខាតក្នុងអត្រាប្តូរប្រាក់បរទេស*

សម្រាប់បំណុលហិរញ្ញវត្ថុដែលកំណត់ជារូបិយប័ណ្ណបរទេស ហើយត្រូវបានវាស់វែងដោយតម្លៃរំលស់នៅចុងការិយបរិច្ឆេទ រាយការណ៍នីមួយៗ ប្រាក់ចំណេញ និងខាតនៃការផ្លាស់ប្តូររូបិយប័ណ្ណបរទេសត្រូវបានកំណត់ដោយផ្អែកលើតម្លៃរំលស់នៃឧបករណ៍។ ប្រាក់ចំណេញ និងខាត នៃការផ្លាស់ប្តូររូបិយប័ណ្ណបរទេសទាំងនេះត្រូវបានទទួលស្គាល់នៅក្នុងធាតុបន្ទាត់ 'ចំណេញ និងខាតផ្សេងទៀត' នៅក្នុងប្រាក់ចំណេញ និងខាតសម្រាប់បំណុលហិរញ្ញវត្ថុដែលមិនមែនជាផ្នែក នៃទំនាក់ទំនងការពារហានិភ័យដែលបានកំណត់។ សម្រាប់បំណុលហិរញ្ញវត្ថុត្រូវបានកំណត់ថាជា ឧបករណ៍ការពារហានិភ័យសម្រាប់ការការពារហានិភ័យ នៃរូបិយប័ណ្ណបរទេស ការចំណេញ និងខាត នៃការផ្លាស់ប្តូររូបិយប័ណ្ណបរទេស ត្រូវបានទទួលស្គាល់នៅក្នុងធាតុចំណូលពេញលេញផ្សេងៗ ហើយបង្គរនៅក្នុងផ្នែកដាច់ដោយឡែកនៃភាគហ៊ុន។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុដែលជារូបិយប័ណ្ណបរទេស ត្រូវបានកំណត់ជារូបិយប័ណ្ណបរទេសនោះ ហើយត្រូវបានបកប្រែតាមអត្រាប្តូរប្រាក់នៅចុងការិយបរិច្ឆេទរាយការណ៍។ សម្រាប់បំណុលហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាម FVTPL សមាសធាតុប្តូរប្រាក់បរទេសបង្កើតបានជាផ្នែកនៃការកើនឡើង ឬ ខាតនៃតម្លៃសមស្រប ហើយត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬ ខាតសម្រាប់បំណុលហិរញ្ញវត្ថុដែលមិនមែនជាផ្នែក នៃទំនាក់ទំនងការពារហានិភ័យ ដែលបានកំណត់។

### *ការកែប្រែ និងការឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ*

ធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុនៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែប្រែ ហើយលំហូរសាច់ប្រាក់នៃបំណុលដែលបានកែប្រែគឺខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មីដោយផ្អែកលើលក្ខខណ្ឌដែលបានកែប្រែត្រូវបានទទួលស្គាល់ដោយតម្លៃសមស្រប។ ភាពខុសគ្នារវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលត្រូវបានឈប់ស្គាល់ និងទឹកប្រាក់ដែលបានបង់ត្រូវបានទទួលស្គាល់ជាប្រាក់ចំណេញ និងខាត។ ការពិចារណាដែលបានបង់រួមមានទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរប្រសិនបើមាន និងការប៉ាន់ស្មាននៃបំណុល រួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែប្រែថ្មី។

ប្រសិនបើការកែប្រែបំណុលហិរញ្ញវត្ថុមិនត្រូវបានរាប់បញ្ចូលជាការឈប់ទទួលស្គាល់ទេ នោះតម្លៃរំលស់ នៃបំណុលត្រូវបានគណនា ឡើងវិញដោយការបញ្ចុះតម្លៃលំហូរសាច់ប្រាក់ដែលបានបញ្ចុះតាមអត្រាការប្រាក់ប្រសិទ្ធភាព ដើម ហើយផលចំណេញ ឬ ខាតត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ និងខាត។ សម្រាប់បំណុលហិរញ្ញវត្ថុដែលមានអត្រាប្រែប្រួល អត្រាការប្រាក់ប្រសិទ្ធភាពដើមដែលបានប្រើដើម្បីគណនាការកែប្រែចំណេញ ឬ ខាតត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលនៃការកែប្រែ។ រាល់ការចំណាយ និងកម្រៃនានាដែលកើតឡើងត្រូវបានទទួលស្គាល់ថាជាការកែតម្រូវលើតម្លៃយោងបំណុលហិរញ្ញវត្ថុ និងរំលស់ក្នុងរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុ ដែលបានកែប្រែដោយគណនាឡើងវិញនូវអត្រាការប្រាក់ប្រសិទ្ធភាពលើឧបករណ៍។

## ៣.៣ ទ្រព្យ និងបរិក្ខារ

ធាតុនៃទ្រព្យសកម្ម និងបរិក្ខារ ត្រូវបានបង្ហាញក្នុងតម្លៃដើម ដកចេញនូវការរំលស់បង្គរ និងការខាតបង់លើអ៊ីមតែរមិនបង្គរ ប្រសិនបើមាន។ នៅពេលដែលធាតុនៃទ្រព្យសកម្ម និងបរិក្ខារមានអាយុកាលប្រើប្រាស់ខុសៗគ្នា នោះពួកវាត្រូវបានគណនាជាធាតុដាច់ដោយឡែក (ធាតុផ្សំសំខាន់ៗ) នៃទ្រព្យសកម្ម និងឧបករណ៍។

ចំណេញ ឬ ខាតលើការជម្រះចោលធាតុនៃទ្រព្យសកម្ម និងបរិក្ខារត្រូវបានទទួលស្គាល់ជាចំណេញ ឬ ខាត។

ការរំលស់ត្រូវបានគណនាដើម្បីលុបចោលថ្លៃដើមនៃទ្រព្យ និងបរិក្ខារ ដោយដកចេញនូវតម្លៃសំណល់ដែលបានប៉ាន់ប្រមាណ ដោយប្រើវិធីសាស្រ្តរំលស់ថេរលើអាយុកាលដែលបានប៉ាន់ប្រមាណ ហើយជាទូទៅត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ និងខាត និងរបាយការណ៍ចំណូលពេញលេញផ្សេងៗ។

| | *អាយុកាលតាមចំនួនឆ្នាំ* |
|---|---|
| ការកែលម្អអគារ | ៥ |
| បរិក្ខារ | ៤ |
| បរិក្ខារកុំព្យូទ័រ | ៣ |
| សង្ហារឹម និងគ្រឿងបំពាក់ | ៤ |
| យានយន្ត | ៥ |

វិធីសាស្រ្តរំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានពិនិត្យនៅកាលបរិច្ឆេទរាយការណ៍នីមួយៗ និងកែតម្រូវប្រសិនបើសមស្រប។





ក្នុងការិយបរិច្ឆេទ ធនាគារបានផ្លាស់ប្តូរអាយុកាលប្រើប្រាស់នៃការកែលម្អការជួលពី ៣ឆ្នាំទៅ ៥ឆ្នាំ ដើម្បីឆ្លុះបញ្ចាំងពីរយៈពេលខ្លីជាង នៃរយៈពេលភតិសន្យាដែលពាក់ព័ន្ធ។

ការងារកំពុងដំណើរការ មិនត្រូវបានរំលស់ទេ រហូតទាល់តែពួកវារួចរាល់សម្រាប់ប្រើប្រាស់តាមការចង់បានដោយអ្នកគ្រប់គ្រង។

ចំណាយបន្តបន្ទាប់ត្រូវបានបញ្ចូលជាថ្លៃដើមទ្រព្យនៅពេល ដែលចំណាយនោះអាចមានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចកើតឡើងនាពេលអនាគត ហើយចំណាយនោះអាចកំណត់បានតាមតម្លៃដែលគួរជឿជាក់បាន។ ការជួសជុល និងថែទាំបន្តបន្ទាប់ត្រូវបានកត់ត្រាជាចំណាយនៅពេលកើតឡើង។

ចំណេញ ឬ ខាតលើការជម្រះចោលធាតុ នៃទ្រព្យសកម្ម និងបរិក្ខារត្រូវបានកំណត់ដោយការប្រៀបធៀបប្រាក់ចំណូលដែលបានមកពីការបោះចោលជាមួយនឹងតម្លៃយោងរបស់ទ្រព្យសកម្ម និងបិរក្ខារ ហើយត្រូវបានទទួលស្គាល់សុទ្ធនៅក្នុង "ប្រាក់ចំណូលផ្សេងទៀត" នៅក្នុងរបាយការណ៍ចំណេញ និងខាត។

ទ្រព្យសកម្ម និងបរិក្ខារដែលរំលស់ទាំងស្រុងត្រូវបានរក្សាទុកក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរហូតដល់ពួកគេត្រូវបានបោះចោល ឬ លុបចោល។

## ៣.៤ កម្មវិធីកុំព្យូទ័រ

កម្មវិធីកុំព្យូទ័រ និងថ្លៃដើមដែលពាក់ព័ន្ធត្រូវបានបង្ហាញតាមតម្លៃដើម ដកចេញនូវរំលស់បង្គរ និងការបាត់បង់អ៊ីមតែរមិនបង្គរ ប្រសិនបើមាន។ រំលស់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ និងខាតតាមវិធីសាស្រ្តរំលស់ថេរក្នុងអត្រា ២០% ក្នុងមួយឆ្នាំ។ ប្រសិនបើមានការចង្អុលបង្ហាញថា មានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់នៅក្នុងអត្រារំលស់ ឬ អាយុកាលប្រើប្រាស់នៃទ្រព្យសកម្មអរូបី រំលស់ត្រូវបានកែសម្រួលជាអនាគត ដើម្បីឆ្លុះបញ្ចាំងពីការរំពឹងទុកថ្មី។

កម្មវិធីដែលកំពុងដំណើរការ មិនត្រូវបានកាត់រំលស់ទេ រហូតទាល់តែពួកវារួចរាល់សម្រាប់ការប្រើប្រាស់តាមការចង់បានដោយអ្នកគ្រប់គ្រង។

## ៣.៥ ភតិសន្យា

នៅដំណាក់កាលដំបូងនៃកិច្ចសន្យា ធនាគារ វាយតម្លៃថាតើកិច្ចសន្យាមួយមាន ឬ ជាភតិសន្យាដែរឬទេ ។

ធនាគារ ទទួលស្គាល់សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាយោងតាមកិច្ចព្រមព្រៀងជួលទាំងអស់ដែលខ្លួនជាអ្នកជួល លើកលែងតែការជួលទ្រព្យមានតម្លៃទាប។ សម្រាប់ការជួលទាំងនេះ ធនាគារទទួលស្គាល់ការទូទាត់ការជួលជាការចំណាយប្រតិបត្តិការដោយឈរលើមូលដ្ឋានរំលស់ថេរក្នុងរយៈពេលនៃការជួល។

### *សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម*

សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មត្រូវបានវាស់វែងដំបូង តាមបំណុលភតិសន្យារួមមានការបង់ប្រាក់ជួលដែលបានធ្វើឡើងនៅ ឬ មុនថ្ងៃចាប់ផ្តើម និងការចំណាយផ្ទាល់ដំបូងប្រសិនបើមាន។ ពួកវាត្រូវបានវាស់វែងជាបន្តបន្ទាប់តាមថ្លៃដើមដកចេញនូវ រំលស់បង្គរ និងការខាតបង់អ៊ីមតែរមិន។

សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានរំលស់តាមរយៈពេលនៃភតិសន្យា និងអាយុកាលប្រើប្រាស់ទ្រព្យសកម្មមូលដ្ឋាន។ រំលស់ ចាប់ផ្តើមនៅកាលបរិច្ឆេទចាប់ផ្តើមនៃការជួល។

សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានបង្ហាញជាបន្ទាត់ដាច់ដោយឡែកនៅក្នុងរបាយការណ៍នៃស្ថានភាពហិរញ្ញវត្ថុ។

***បំណុលភតិសន្យា***

បំណុលភតិសន្យាត្រូវបានវាស់វែងជាបឋមតាមតម្លៃបច្ចុប្បន្ន នៃការទូទាត់ជួលភតិសន្យាដែលមិនទាន់ បានបង់នៅកាលបរិច្ឆេទចាប់ផ្តើម ធ្វើអប្បហារដោយប្រើអត្រាការប្រាក់បន្ថែមរបស់ខ្លួនដែលជាការប្រាក់ដែលធនាគារនឹងត្រូវបង់ដើម្បីខ្ចីក្នុងរយៈពេលស្រដៀងគ្នា និង ធានាទូរមូលនិធិ ដែលចាំបាច់ដើម្បីទទួលបានទ្រព្យសកម្ម នៃតម្លៃស្រដៀងគ្នាទៅនឹងសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មក្នុងបរិយាកាសសេដ្ឋកិច្ចស្រដៀងគ្នា។

ការទូទាត់ភតិសន្យារួមបញ្ចូលនៅក្នុងការវាស់វែងនៃបំណុលភតិសន្យា រួមមានៈ

- ការទូទាត់ការជួលថេរ ដកចេញនូវរាល់អត្ថប្រយោជន៍នៃភតិសន្យា
- ការបង់ប្រាក់ពិន័យសម្រាប់ការបញ្ចប់ភតិសន្យា ប្រសិនបើរយៈពេលជួលឆ្លុះបញ្ចាំងពីការអនុវត្តជម្រើសដើម្បីបញ្ចប់ភតិសន្យា។

បំណុលភតិសន្យាត្រូវបានបង្ហាញជាបន្ទាត់ដាច់ដោយឡែកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

បំណុលភតិសន្យា ត្រូវបានវាស់វែងជាបន្តបន្ទាប់ដោយការបង្កើនចំនួនតម្លៃយោង ដើម្បីឆ្លុះបញ្ចាំងការប្រាក់លើបំណុលភតិសន្យា (ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព) និងដោយកាត់បន្ថយតម្លៃយោង ដើម្បីឆ្លុះបញ្ចាំងពីការបង់ថ្លៃជួល។

ធនាគារ វាស់វែងឡើងវិញនូវបំណុលភតិសន្យា (និងធ្វើការកែតម្រូវដែលត្រូវគ្នាទៅនឹងទ្រព្យសកម្ម សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម) នៅពេលណាដែលៈ

- រយៈពេលជួលបានផ្លាស់ប្តូរ ក្នុងករណីបំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញដោយការអប្បហារលើការបង់ប្រាក់ជួល ដែលបានកែប្រែដោយប្រើអត្រាអប្បហារដែលបានកែប្រែ។
- កិច្ចសន្យាជួលត្រូវបានកែប្រែ ហើយការកែប្រែការជួលមិនត្រូវបានរាប់បញ្ចូលជាកិច្ចសន្យាជួលដាច់ដោយឡែកទេ ក្នុងករណីនេះ បំណុលភតិសន្យា ត្រូវបានវាស់វែងឡើងវិញដោយការអប្បហារលើការទូទាត់ការជួលដែលបានកែប្រែដោយប្រើអត្រាអប្បហារដែលបានកែប្រែ។

***ភតិសន្យាមានរយៈពេលខ្លី និងការជួលទ្រព្យសកម្មមានតម្លៃទាប***

ធនាគារ អនុវត្តការលើកលែងការទទួលស្គាល់ ភតិសន្យាមានរយៈពេលខ្លីចំពោះការជួលរយៈពេលខ្លីនៃ យានយន្តរបស់ខ្លួន (ឧ. ការជួលទាំងនោះដែលមានរយៈពេលជួល ១២ខែ ឬ តិចជាងនេះចាប់ពីថ្ងៃចាប់ផ្តើម ហើយមិនមានជម្រើសទិញ)។ មានការអនុវត្តផងដែរនូវភតិសន្យានៃការលើកលែងការទទួលស្គាល់ទ្រព្យសកម្មតម្លៃទាប ប្រសិនបើមាន។ ការទូទាត់លើភតិសន្យារយៈពេលខ្លី និងការជួលទ្រព្យសកម្មមានតម្លៃទាប ត្រូវបានទទួលស្គាល់ថាជាការចំណាយលើវិធីសាស្ត្ររំលស់ថេរតាមរយៈពេលជួល។

## ៣.៦ អ៊ីមតែរមិននៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ត្រូវបានពិនិត្យ នៅកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានការបង្ហាញពីអ៊ីមតែរមិន ឬអត់។ ប្រសិនបើមានការបង្ហាញបែបនេះ ចំនួនទឹកប្រាក់ដែលអាចទទួលបានមកវិញរបស់ទ្រព្យសកម្មត្រូវបានប៉ាន់ប្រមាណ។

ចំនួនទឹកប្រាក់ ដែលអាចទទួលបានមកវិញបាននៃទ្រព្យសកម្ម ឬ ឯកតាបង្កើតសាច់ប្រាក់ធំជាងនៃតម្លៃរបស់វាដែលកំពុងប្រើប្រាស់ ហើយតម្លៃសមស្របដកចេញនូវការចំណាយក្នុងការលក់។ ក្នុងការវាយតម្លៃ តម្លៃដែលកំពុងប្រើប្រាស់លំហូរសាច់ប្រាក់នាពេលអនាគតប៉ាន់ស្មាន ត្រូវបានអប្បហារមកតម្លៃបច្ចុប្បន្នរបស់ពួកគេ ដោយប្រើអត្រាអប្បហារមុនពន្ធ ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារលើតម្លៃនៃពេលវេលានៃសាច់ប្រាក់ និងហានិភ័យជាក់លាក់ចំពោះទ្រព្យសកម្ម។ សម្រាប់គោលបំណងនៃការធ្វើតេស្តអ៊ីមតែរមិន ទ្រព្យសកម្ម ត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចបំផុត នៃទ្រព្យសកម្មដែលបង្កើតលំហូរសាច់ប្រាក់ចូលពីការបន្តប្រើប្រាស់ ដែលភាគច្រើនមិនអាស្រ័យលើលំហូរសាច់ប្រាក់ចូលនៃទ្រព្យសកម្ម ឬ ក្រុមនៃទ្រព្យសកម្មផ្សេងទៀត ("ឯកតាបង្កើតសាច់ប្រាក់")។

ការខាតបង់លើអ៊ីមតែរមិនត្រូវបានទទួលស្គាល់ ប្រសិនបើ តម្លៃយោងនៃទ្រព្យសកម្ម ឬ ឯកតាបង្កើតសាច់ប្រាក់របស់វា លើសពីចំនួនប៉ាន់ស្មានដែលអាចទទួលបានមកវិញ។ ការខាតបង់លើអ៊ីមតែរមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

## ៣.៧ អត្ថប្រយោជន៍បុគ្គលិក

***អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី***

អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី ត្រូវបានបង្កើតឡើងក្នុងរយៈពេល ដែលសេវាកម្មដែលពាក់ព័ន្ធត្រូវបានបំពេញដោយនិយោជិតរបស់ធនាគារ។

## ៣.៨ សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលធនាគារមានកាតព្វកិច្ចផ្លូវច្បាប់ ឬ ការសន្យាដែលជាលទ្ធផល នៃព្រឹត្តិការណ៍អតីតកាល ហើយវាទំនងជាចាលំហូរចេញនៃធនធាន ដែលរួមបញ្ចូលអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងត្រូវបានទាមទារដើម្បីទូទាត់កាតព្វកិច្ច។ ប្រសិនបើផលប៉ះពាល់ជាសារវន្ត នោះសំវិធានធនត្រូវបានកំណត់ដោយការអប្បហារលំហូរសាច់ប្រាក់នាពេលអនាគត ដែលរំពឹងទុកក្នុងអត្រាមុនគិតពន្ធដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលានៃប្រាក់ ហើយហានិភ័យជាក់លាក់ចំពោះបំណុល។

## ៣.៩ វិភាគទានពី MEF

វិភាគទានពី MEF តំណាងឲ្យថ្លៃចំណាយមុនចាប់ផ្តើមអាជីវកម្មរបស់ធនាគារ និងការកែលម្អអគារ ដោយMEF។ ធនាគារ បានទទួលស្គាល់ថ្លៃចំណាយមុនចាប់ផ្តើមអាជីវកម្មក្នុងរបាយការណ៍ចំណេញ ឬ ខាត ខណៈពេលដែលថ្លៃដើមធ្វើមូលធនកម្មត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងត្រូវបានរំលស់ទៅតាមអាយុកាលរបស់វា។

ថ្លៃដើម នៃការចាប់ផ្តើមអាជីវកម្ម និងការកែលម្អអគារ ត្រូវបានផ្ទេរទាំងស្រុងដោយ MEF ទៅធនាគារដោយគ្មានលក្ខខណ្ឌបង្វិលសងវិញ។ ដូច្នេះ ការរួមចំណែកពី MEF ត្រូវបានចាត់ទុកថាជាមូលធន។

## ៣.១០ អត្រាការប្រាក់ប្រសិទ្ធភាព

អត្រាការប្រាក់ប្រសិទ្ធភាព ("EIR") គឺជាអត្រាអប្បហារការទទួល ឬទូទាត់សាច់ប្រាក់នាពេលអនាគតតាមរយៈអាយុកាលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ បំណុលហិរញ្ញវត្ថុចំពោះតម្លៃយោងដុល នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ តម្លៃរំលស់នៃបំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព ធនាគារប៉ាន់ស្មានលំហូរសាច់ប្រាក់ដែលរំពឹងទុកដោយពិចារណាលើលក្ខខណ្ឌកិច្ចសន្យាទាំងអស់ នៃឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនគិតពីការបាត់បង់ឥណទានដែលរំពឹងទុកនោះទេ។ ការគណនារួមបញ្ចូលកម្រៃ និងចំណាយបន្ថែម ឬទទួលបានរវាងភាគីនៃកិច្ចសន្យា ដែលជាផ្នែកសំខាន់មួយ នៃអត្រាការប្រាក់ ប្រសិទ្ធភាព ថ្លៃប្រតិបត្តិការ និងបុព្វលាភ ឬអប្បហារផ្សេងទៀតទាំងអស់។

ការចំណាយលើប្រតិបត្តិការ គឺជាការចំណាយបន្ថែមដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការទិញយក ការបោះផ្សាយ ឬការលក់ចេញនូវ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ ការចំណាយបន្ថែម គឺជាការចំណាយមួយដែលនឹងមិនកើតឡើងទេ ប្រសិនបើអង្គភាពមិនបានទិញ បោះផ្សាយ ឬលក់ចេញឧបករណ៍ហិរញ្ញវត្ថុ។

### ៣.១០.១ ចំណូលការប្រាក់

ចំណូលការប្រាក់ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ និងខាត ដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព។ វាត្រូវបានគណនាដោយការអនុវត្តអត្រាការប្រាក់ប្រសិទ្ធភាព ចំពោះតម្លៃយោងដុល នៃទ្រព្យសកម្មហិរញ្ញវត្ថុ លើកលែងតែ៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានអ៊ីមភែរមិនតណទានដែលបានទិញ ឬបានផ្តល់។ EIR ដែលមាននិយ័តកម្មតណទាន ត្រូវបានអនុវត្តតាម ថ្លៃដើមរំលស់ នៃទ្រព្យសកម្មហិរញ្ញវត្ថុ។
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនត្រូវបានទិញ ឬបានផ្តល់ ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពឱនភាពនៃតណទាន នោះ ប៉ុន្តែក្រោយមក បានក្លាយទៅជាទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតណទាន។ EIR តាមថ្លៃដើម រំលស់ នៃទ្រព្យសកម្មហិរញ្ញវត្ថុនៅក្នុងរយៈពេលរាយការណ៍ជាបន្តបន្ទាប់ត្រូវបានអនុវត្ត។

អត្រាការប្រាក់ប្រសិទ្ធភាព ដែលបានមាននិយ័តកម្មតណទាន គឺជាអត្រាអប្បហារការទទួល ឬទូទាត់ សាច់ប្រាក់នាពេលអនាគតរំពឹងទុក ឬតាមរយៈអាយុកាលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុ តាមថ្លៃដើមរំលស់ នៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលជាទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតណទាន ដែលបានទិញ ឬបានផ្តល់។

ចំណូលការប្រាក់ត្រូវបានគណនា ដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព ដែលបង្ហាញក្នុងរបាយការណ៍ លទ្ធផលពេញលេញសរុបរួមមានការប្រាក់ លើទ្រព្យសកម្មហិរញ្ញវត្ថុ ដែលវាស់វែងតាមតម្លៃរំលស់។

### ៣.១០.២ ចំណាយការប្រាក់

ចំណាយការប្រាក់ ក៏ត្រូវបានគណនាផងដែរដោយប្រើវិធីសាស្រ្ត EIR សម្រាប់បំណុលហិរញ្ញវត្ថុទាំងអស់ ដែលធ្វើឡើងតាមតម្លៃរំលស់។ ការចំណាយលើការប្រាក់ ដែលបង្ហាញក្នុងរបាយការណ៍លទ្ធផលពេញលេញរួមមានបំណុលហិរញ្ញវត្ថុ ដែលវាស់វែងតាមថ្លៃដើមរំលស់។

## ៣.១១ កម្រៃ និងចំណូលផ្សេងទៀត

ចំណូល និងចំណាយលើកម្រៃ និងសេវាជើងសារ ដែលរួមបញ្ចូលទៅនឹងអត្រាការប្រាក់ប្រសិទ្ធភាពលើទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលក្នុងអត្រាការប្រាក់ប្រសិទ្ធភាព។

កិច្ចសន្យាជាមួយអតិថិជន ដែលមានលទ្ធផលនៃការទទួលស្គាល់ឧបករណ៍ហិរញ្ញវត្ថុ នៅក្នុងធនាគារ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារអាចជាផ្នែកមួយនៃវិសាលភាពនៃ CIFRS ៩ និងផ្នែកខ្លះនៅក្នុងវិសាលភាពនៃ CIFRS ១៥។ ប្រសិនបើករណីនេះ ធនាគារអនុវត្ត CIFRS ៩ ជាមុនសិន ដើម្បីបំបែក និងវាស់វែងផ្នែកនៃកិច្ចសន្យាដែលមាននៅក្នុងវិសាលភាពនៃ CIFRS ៩ ហើយបន្ទាប់មកអនុវត្ត CIFRS ១៥ ចំពោះផ្នែកនៅសល់។

ធនាគារ ធ្វើតាមគំរូ៥ជំហាន ដើម្បីគណនាប្រាក់ចំណូលដែលកើតឡើងពីកិច្ចសន្យាជាមួយអតិថិជនក្រោម CIFRS ១៥។ គំរូ៥ជំហាន មានដូចខាង ក្រោម៖

i) កំណត់កិច្ចសន្យាជាមួយអតិថិជន
ii) កំណត់កាតព្វកិច្ចអនុវត្តក្នុងកិច្ចសន្យា
iii) កំណត់តម្លៃនៃប្រតិបត្តិការ
iv) បែងចែកតម្លៃនៃប្រតិបត្តិការទៅតាមកាតព្វកិច្ចអនុវត្តក្នុងកិច្ចសន្យា
v) ទទួលស្គាល់ប្រាក់ចំណូលនៅពេល (ឬ ដូច) អង្គភាពបានបំពេញកាតព្វកិច្ចអនុវត្ត
vi) ចំណូលកម្រៃ និងសេវាជើងសារ ត្រូវបានទទួលស្គាល់ថាជាសេវាដែលទាក់ទងត្រូវបានអនុវត្ត។

## ៣.១២ ពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណូលលើរបាយការណ៍លទ្ធផលពេញលេញ សម្រាប់ការិយបរិច្ឆេទ រួមមានពន្ធក្នុងលើប្រាក់ចំណូលបច្ចុប្បន្ន និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណូលត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ និងខាត លើកលែងតែក្នុងវិសាលភាពដែលវាទាក់ទងនឹងខ្ទង់ ដែលត្រូវបានទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន ក្នុងករណីនេះវាត្រូវបានទទួលស្គាល់ក្នុងមូលធន។

ពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន គឺជាពន្ធដែលរំពឹងទុកដែលត្រូវបង់លើប្រាក់ចំណូលជាប់អាករសម្រាប់ការិយបរិច្ឆេទ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬ បានអនុម័តយ៉ាងសំខាន់នៅកាលបរិច្ឆេទរាយការណ៍ និងការកែសម្រួលណាមួយចំពោះពន្ធដែលត្រូវបង់ទាក់ទងនឹងឆ្នាំមុន។

ពន្ធពន្យារ ត្រូវបានផ្តល់ជូនដោយប្រើវិធីសាស្រ្តតារាងតុល្យការ ដោយផ្តល់សម្រាប់ភាពខុសគ្នាបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលសម្រាប់គោលបំណងរាយការណ៍ហិរញ្ញវត្ថុ និងចំនួនទឹកប្រាក់ ប្រើប្រាស់សម្រាប់គោលបំណងពន្ធ។

ចំនួនទឹកប្រាក់នៃពន្ធពន្យារដែលបានផ្តល់ គឺផ្អែកលើវិធីដែលរំពឹងទុកនៃការសម្រេច ឬ ការទូទាត់នៃតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល ដោយប្រើអត្រាពន្ធដែលបានអនុម័តនៅកាលបរិច្ឆេទរាយការណ៍។

ពន្ធពន្យារ ជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ តែក្នុងកម្រិតដែលវាទំនងជាប្រាក់ចំណេញជាប់អាករនាពេលអនាគតនឹងអាចរកបានធៀបនឹងទ្រព្យសកម្មដែលអាចប្រើប្រាស់បាន។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានពិនិត្យឡើងវិញនៅកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ ហើយត្រូវបានកាត់បន្ថយដល់កម្រិត ដែលវាលែងមានលទ្ធភាព ដែលអត្ថប្រយោជន៍ពន្ធដែលពាក់ព័ន្ធនឹងត្រូវបានទទួលស្គាល់។

ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុល ត្រូវបានកាត់កងតែក្នុងករណី ដែលលក្ខខណ្ឌជាក់លាក់ត្រូវបានបំពេញប៉ុណ្ណោះ។

## ៣.១៣ ទុនបម្រុងបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានបង្កើតឡើង សម្រាប់ភាពខុសគ្នារវាង សំវិធានធនតាម ECL ដែលកំណត់ដោយ CIFRS ៩ និងសំវិធានធនតាមបទប្បញ្ញត្តិនៃប្រកាស លេខ ធ៧-០១៧-៣៨៤ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ របស់ធនាគារជាតិនៃកម្ពុជា និងសារាចរណែនាំ លេខ ធ៧-០១៨-០០១ ស.រ.ច.ណ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការអនុវត្តប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យតណទាន និងសំវិធានធនលើអ៊ីមភែរមិន សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។ ធនាគារ ត្រូវធ្វើការប្រៀបធៀបនឹង សំវិធានធនតាមបទប្បញ្ញត្តិ ជាមួយនឹងសំវិធានធនដែលគណនាតាម CIFRS ៩ ដូចខាងក្រោម៖

(i) ក្នុងករណីសំវិធានធនតាមបទប្បញ្ញត្តិ ទាបជាងសំវិធានធនដែលគណនាតាម CIFRS ៩ គ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន តាម CIFRS ៩។
(ii) ក្នុងករណីសំវិធានធនតាមបទប្បញ្ញត្តិ ខ្ពស់ជាងសំវិធានធនដែលគណនាតាម CIFRS ៩ គ្រឹះស្ថានត្រូវកត់ត្រាសំវិធានធនតាម CIFRSs ហើយត្រូវផ្ទេរចំនួនខុសគ្នាពីគណនីប្រាក់ចំណេញរក្សាទុក ឬ ខាតបង្គរទៅក្នុងគណនីទុនបម្រុងតាមបទប្បញ្ញត្តិ ក្នុងខ្ទង់មូលនិធិ នៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ប្រកាសស្តីពីសំវិធានធនតាមបទប្បញ្ញត្តិ តម្រូវឲ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុធ្វើចំណាត់ថ្នាក់ឥណទានជា ៥ ថ្នាក់ និងធ្វើសំវិធានធនទូទៅ និងជាក់លាក់ដោយផ្អែកតាមចំណាត់ថ្នាក់ឥណទានដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| ស្តង់ដារ | ចាប់ពី ០ ដល់ ១៤ថ្ងៃ (ឥណទានរយៈពេលខ្លី)<br>ចាប់ពី ០ ដល់ ២៩ថ្ងៃ (ឥណទានរយៈពេលវែង) | ១% |
| ឃ្លាំមើល | ចាប់ពី ១៥ ដល់ ៣០ថ្ងៃ (ឥណទានរយៈពេលខ្លី)<br>ចាប់ពី ៣០ ដល់ ៨៩ថ្ងៃ (ឥណទានរយៈពេលវែង) | ៣% |
| ក្រោមស្តង់ដារ | ចាប់ពី ៣១ ដល់ ៦០ថ្ងៃ (ឥណទានរយៈពេលខ្លី)<br>ចាប់ពី ៩០ ដល់ ១៧៩ថ្ងៃ (ឥណទានរយៈពេលវែង) | ២០% |
| សង្ស័យ | ចាប់ពី ៦១ ដល់ ៩០ថ្ងៃ (ឥណទានរយៈពេលខ្លី)<br>ចាប់ពី ១៨០ ដល់ ៣៥៩ថ្ងៃ (ឥណទានរយៈពេលវែង) | ៥០% |
| បាត់បង់ | លើសពី ៩១ថ្ងៃ (ឥណទានរយៈពេលខ្លី)<br>លើសពី ៣៦០ថ្ងៃ (ឥណទានរយៈពេលវែង) | ១០០% |

នៅខែធ្នូ ឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជា បានចេញសារាចរលេខ ធ៧-០២១-២៣១៤ ដើម្បីផ្តល់ការណែនាំបន្ថែមដល់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ក្នុងការចាត់ថ្នាក់ឥណទានរៀបចំឡើងវិញ ដែលបានធ្វើឡើងរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងការធ្វើសំវិធានធនតាមបទប្បញ្ញត្តិ។

សារាចរនេះ តម្រូវឲ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ធ្វើការចាត់ថ្នាក់ឥណទានរៀបចំឡើងវិញ ដូចខាងក្រោម៖

- ឃ្លាំមើល ប្រសិនបើឥណទានរៀបចំឡើងវិញ មានស្ថានភាពល្អ ឬ ជាឥណទានដំណើរការ
- ក្រោមស្តង់ដា ប្រសិនបើឥណទានរៀបចំឡើងវិញលើកទីមួយ មានស្ថានភាពដែលត្រូវការរៀបចំឥណទានឡើងវិញបន្ថែម
- សង្ស័យ ប្រសិនបើឥណទានរៀបចំឡើងវិញលើកទីពីរ មានស្ថានភាពដែលត្រូវការរៀបចំឥណទានឡើងវិញបន្ថែម
- បាត់បង់ ប្រសិនបើឥណទានរៀបចំឡើងវិញ មានស្ថានភាពមិនល្អ ដែលកំណត់ថាជាឥណទាន មិនដំណើរការ

សំវិធានធនតាម ECLs មានចំនួន ៣.៨២៧.៦០៥ ដុល្លារអាមេរិក ឬ ១៥.៧៥៨.២៥០ ពាន់រៀល (២០២១៖ ១.៧៩៨.៩៩៨ ដុល្លារអាមេរិក ឬ ៧.៣២៩.១១៨ ពាន់រៀល) លើស សំវិធានធនតាមបទប្បញ្ញត្តិដែលមានចំនួន ២.៨៤៣.៩២៧ ដុល្លារអាមេរិក ឬ ១១.៧០៨.៤៤៧ ពាន់រៀល (២០២១៖ ១.១៧១.១៣៨ ដុល្លារអាមេរិក ឬ ៤.៧៧១.២១៦ ពាន់រៀល)។ ដូច្នេះ ពុំមានតម្រូវអោយមានទុនបម្រុងតាមបទប្បញ្ញត្តិ នោះទេ។

## ៣.១៤ ភាគីពាក់ព័ន្ធ

ភាគី ត្រូវបានចាត់ទុកថាមានទំនាក់ទំនងជាមួយធនាគារ ប្រសិនបើភាគីម្ខាងមានសមត្ថភាព ដោយផ្ទាល់ ឬ ដោយប្រយោល ដើម្បីគ្រប់គ្រងភាគីម្ខាងទៀត ឬ ប្រើឥទ្ធិពលយ៉ាងសំខាន់លើភាគីម្ខាងទៀតក្នុងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬ កន្លែងដែលធនាគារ និងភាគីម្ខាងទៀតជាកម្មវត្ថុ ទៅនឹងការគ្រប់គ្រងទូទៅ ឬ ឥទ្ធិពលសំខាន់។ ភាគីពាក់ព័ន្ធអាចជាបុគ្គល ឬ អង្គភាពសាជីវកម្ម ហើយរួមបញ្ចូលសមាជិកគ្រួសារជិតស្និទ្ធរបស់បុគ្គលណាមួយដែលត្រូវបានចាត់ទុកថាជាភាគីពាក់ព័ន្ធ។

## ៣.១៥ ការបង្គត់ចំនួន

ចំនួនទឹកប្រាក់ទាំងអស់ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់សម្គាល់ត្រូវបានបង្គត់ឲ្យនៅជិតបំផុតទៅនឹងខ្ទង់ពាន់រៀល ហើយចំនួនទឹកប្រាក់ទាំងអស់ជាដុល្លារ ត្រូវបានបង្គត់ទៅឯកតារូបិយប័ណ្ណទាំងមូល លុះត្រាតែមានការបញ្ជាក់ផ្សេងទៀត។





# ៤. ការវិនិច្ឆ័យ និងការប៉ាន់ស្មានគណនេយ្យសំខាន់ៗ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាម CIFRSs តម្រូវឲ្យមានការប្រើប្រាស់ការវិនិច្ឆ័យ ការប៉ាន់ប្រមាណ និងការសន្មតដែលប៉ះពាល់ដល់តម្លៃនៅក្នុងរបាយការណ៍ និងការបង្ហាញពីទ្រព្យសកម្ម និងបំណុលនៅកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃនៅក្នុងរបាយការណ៍ និងការបង្ហាញពីចំណូល និងចំណាយក្នុងការិយបរិច្ឆេទនៃរបាយការណ៍។ លទ្ធផលការវិនិច្ឆ័យ និងការប៉ាន់ស្មាន គណនេយ្យគឺតែងតែមានភាពមិនស្មើគ្នាទៅនឹងលទ្ធផលជាក់ស្តែង។

ការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ដោយផ្អែកលើបទពិសោធន៍ពីមុនៗ និងកត្តាផ្សេងទៀត រួមទាំងការរំពឹងទុក នៃព្រឹត្តិការណ៍នាពេលអនាគតដែលត្រូវបានគេជឿថាសមហេតុផលតាមកាលៈទេសៈ។

## ៤.១ ការវិនិច្ឆ័យ

ខាងក្រោមនេះ គឺជាការវិនិច្ឆ័យសំខាន់ៗ ក្រៅពីការប៉ាន់ប្រមាណ (កំណត់សម្គាល់លេខ ៤.២) ដែលការគ្រប់គ្រងបានធ្វើឡើងក្នុងដំណើរការអនុវត្តគោលការណ៍គណនេយ្យរបស់ធនាគារ ដែលមានឥទ្ធិពលខ្លាំងបំផុតទៅលើចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

***(i) ការកើនឡើងខ្លាំងនៃហានិភ័យឥណទាន***

ដូចដែលបានពន្យល់នៅក្នុងកំណត់សម្គាល់លេខ ៣ ECLs ត្រូវបានវាស់វែងជាសំវិធានធន ស្មើនឹង ECL រយៈពេល ១២ ខែសម្រាប់ទ្រព្យសកម្មដំណាក់កាលទី ១ ឬ ECLពេញមួយអាយុកាលសម្រាប់ទ្រព្យសកម្មដំណាក់កាលទី ២ ឬ ដំណាក់កាលទី ៣។ ទ្រព្យសកម្មផ្លាស់ទីទៅដំណាក់កាលទី ២ នៅពេលដែលហានិភ័យឥណទានរបស់វាបានកើនឡើងយ៉ាងខ្លាំងចាប់តាំងពីការទទួលស្គាល់ដំបូង។ CIFRS ៩ មិនកំណត់នូវអ្វីដែលបង្កើតបានជាការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាននោះទេ។ ក្នុងការវាយតម្លៃថា តើហានិភ័យឥណទាននៃទ្រព្យសកម្មមួយបានកើនឡើងយ៉ាងខ្លាំង ឬ យ៉ាងណា ធនាគារ គិតគូរពីគុណភាព និងបរិមាណ ដោយសមហេតុផល និងព័ត៌មានដែលអាចទុកចិត្តបាននាពេលខាងមុខ។

***(ii) ការវាយតម្លៃនៃគំរូអាជីវកម្ម***

ចំណាត់ថ្នាក់ និងការវាស់វែងនៃទ្រព្យសកម្មហិរញ្ញវត្ថុ អាស្រ័យលើលទ្ធផលនៃ SPPI និងការធ្វើតេស្តគំរូអាជីវកម្ម។ ធនាគារ កំណត់គំរូអាជីវកម្មនៅកម្រិតមួយដែលឆ្លុះបញ្ចាំងពីរបៀបដែលក្រុម នៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគ្រប់គ្រងរួមគ្នា ដើម្បីសម្រេចបាននូវគោលបំណងអាជីវកម្មជាក់លាក់មួយ។ ការវាយតម្លៃនេះរួមបញ្ចូលទាំងការវិនិច្ឆ័យ ដែលឆ្លុះបញ្ចាំងពីភស្តុតាងពាក់ព័ន្ធទាំងអស់រួមទាំងរបៀបដែលការប្រតិបត្តិនៃទ្រព្យសកម្មត្រូវបានវាយតម្លៃ និងការអនុវត្តរបស់ពួកគេត្រូវបានវាស់វែងហានិភ័យដែលប៉ះពាល់ដល់ការអនុវត្តទ្រព្យសកម្ម និងរបៀបដែលត្រូវបានគ្រប់គ្រងនិងរបៀបដែលអ្នកគ្រប់គ្រងទ្រព្យសកម្មត្រូវបានផ្តល់សំណង។

ធនាគារ តាមដានទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃរំលស់ ឬតម្លៃសមស្របតាមរយៈចំណូលពេញលេញផ្សេងៗ ដែលត្រូវបានឈប់ទទួលស្គាល់មុនកាលកំណត់ ដើម្បីស្វែងយល់ពីហេតុផលសម្រាប់ការលក់ និងថាតើហេតុផលត្រូវគ្នានឹងកម្មវត្ថុនៃអាជីវកម្មដែលទ្រព្យសកម្មត្រូវបានកាន់កាប់ដែរ ឬទេ។ ការត្រួតពិនិត្យគឺជាផ្នែកមួយនៃការវាយតម្លៃបន្តរបស់ធនាគារថាតើគំរូអាជីវកម្មដែលទ្រព្យសកម្មហិរញ្ញវត្ថុដែល នៅសល់បន្តមានលក្ខណៈសមស្របដែរ ឬទេ ហើយប្រសិនបើវាមិនសមស្របថាតើមានការផ្លាស់ប្តូរគំរូអាជីវកម្មដែរ ឬទេ ដូច្នេះហើយ នឹងមានការផ្លាស់ប្តូរ ចំពោះចំណាត់ថ្នាក់ នៃទ្រព្យសកម្មទាំងនោះ។

***(iii) ការបង្កើតក្រុមនៃទ្រព្យសកម្មដែលមានលក្ខណៈហានិភ័យឥណទានស្រដៀងគ្នា***

នៅពេលដែល ECLs ត្រូវបានវាស់វែងលើមូលដ្ឋានសមូហភាព ឧបករណ៍ហិរញ្ញវត្ថុត្រូវបានដាក់ជាក្រុមដោយផ្អែកលើលក្ខណៈហានិភ័យរួម។ កំណត់សម្គាល់លេខ ៣.២ ផ្តល់ព័ត៌មានលម្អិតអំពីលក្ខណៈដែលបានពិចារណានៅក្នុងការវិនិច្ឆ័យនេះ។ ធនាគារ តាមដានភាពសមស្របនៃលក្ខណៈហានិភ័យឥណទានលើមូលដ្ឋានបន្ត ដើម្បីវាយតម្លៃថា

តើពួកគេបន្តមានលក្ខណៈស្រដៀងគ្នាដែរ ឬទេ។ វាត្រូវបានទាមទារដើម្បីធានាថា គួរតែផ្លាស់ប្តូរលក្ខណៈហានិភ័យឥណទាន មានការចាត់ថ្នាក់ឡើងវិញសមស្របនៃទ្រព្យសកម្ម។ នេះអាចបណ្តាលឲ្យផលប័ត្រថ្មីត្រូវបានបង្កើតឡើង ឬទ្រព្យសកម្មផ្លាស់ប្តូរទៅកាន់ផលប័ត្រដែលមានស្រាប់ ដែលឆ្លុះបញ្ចាំងឲ្យកាន់តែច្បាស់អំពីលក្ខណៈហានិភ័យឥណទានស្រដៀងគ្នា នៃក្រុមទ្រព្យសកម្មនោះ។

ការបែងចែកផលប័ត្រឡើងវិញ និងបម្រែបម្រួលរវាងផលប័ត្រ គឺជារឿងធម្មតាជាងនៅពេលដែលមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន (ឬ នៅពេលដែលការកើនឡើងគួរឲ្យកត់សម្គាល់នោះបញ្ច្រាស) ដូច្នេះហើយទ្រព្យសកម្មផ្លាស់ទីពី ១២ខែទៅ ECLs ពេញមួយអាយុកាល ឬ ផ្ទុយមកវិញ ប៉ុន្តែវាក៏អាចកើតឡើងផងដែរ នៅក្នុងផលប័ត្រដែលបន្តត្រូវបានវាស់វែងនៅលើមូលដ្ឋានដូចគ្នានៃ ECLs រយៈពេល ១២ខែ ឬ ពេញមួយអាយុកាល ប៉ុន្តែចំនួនទឹកប្រាក់នៃ ECL ផ្លាស់ប្តូរ ដោយសារហានិភ័យឥណទាននៃផលប័ត្រមានភាពខុសគ្នា។

### *(iv) ម៉ូដែល និងការសន្មតដែលបានប្រើ*

ធនាគារ ប្រើម៉ូដែល និងការសន្មតផ្សេងៗក្នុងការវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ ក៏ដូចជាក្នុងការប៉ាន់ប្រមាណ ECL។ ការវិនិច្ឆ័យ ត្រូវបានអនុវត្តក្នុងការកំណត់អត្តសញ្ញាណគំរូសមស្របបំផុតសម្រាប់ប្រភេទ នៃទ្រព្យសកម្មនីមួយៗ ក៏ដូចជាសម្រាប់កំណត់ការសន្មត ដែលប្រើក្នុងគំរូទាំងនេះ រួមទាំងការសន្មត ដែលទាក់ទងនឹងកត្តាជំរុញសំខាន់ៗ នៃហានិភ័យឥណទាន។

### *(v) ភតិសន្យា*

ធនាគារ កំណត់រយៈពេលភតិសន្យានេះថាជារយៈពេល ដែលមិនអាចលុបចោលបាននៃភតិសន្យានេះរួមជាមួយនឹងរយៈពេលណាមួយ ដែលគ្របដណ្តប់ដោយជម្រើសមួយដើម្បីពង្រីកភតិសន្យា ប្រសិនបើវាពិតជាប្រាកដ ក្នុងការអនុវត្ត ឬ រយៈពេលណាមួយដែលគ្របដណ្តប់ដោយជម្រើសមួយដើម្បីបញ្ចប់ភតិសន្យានេះ ប្រសិនបើវាពិតជាមិនត្រូវបានអនុវត្តដោយសមហេតុផល។

### *(vi) រូបិយប័ណ្ណមុខងារ*

CIAS ២១ តម្រូវឲ្យគណៈគ្រប់គ្រងប្រើប្រាស់ការវិនិច្ឆ័យរបស់ខ្លួន ដើម្បីកំណត់រូបិយប័ណ្ណមុខងាររបស់អង្គភាពដែលបង្ហាញពីកាលៈទេសៈ និង ផលប៉ះពាល់សេដ្ឋកិច្ច នៃជំនួញប្រតិបត្តិការ និងលក្ខខណ្ឌដែលទាក់ទងទៅនឹងអង្គភាព។ ក្នុងការធ្វើការវិនិច្ឆ័យនេះ ធនាគារចាត់ទុកដូចខាងក្រោម៖

- i) រូបិយប័ណ្ណដែលមានឥទ្ធិពលជាចម្បងលើតម្លៃសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ និងសេវាកម្ម (នេះជាញឹកញាប់នឹងក្លាយជារូបិយប័ណ្ណដែលតម្លៃសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ និងសេវាកម្មរបស់ខ្លួនត្រូវបានគិតនិងដោះស្រាយ)
- ii) រូបិយប័ណ្ណដែលមូលនិធិពីសកម្មភាពហិរញ្ញប្បទានត្រូវបានបង្កើត និង
- iii) រូបិយប័ណ្ណដែលទទួលពីសកម្មភាពប្រតិបត្តិការ ដែលជាធម្មតាត្រូវបានរក្សាទុក។

## ៤.២ ការប៉ាន់ស្មាន

ការសន្មតសំខាន់ៗទាក់ទងនឹងអនាគត និងប្រភពសំខាន់ៗផ្សេងទៀតនៃភាពមិនប្រាកដប្រជា នៃការប៉ាន់ប្រមាណនៅការិយបរិច្ឆេទនៃរបាយការណ៍ ដែលមានហានិភ័យយ៉ាងសំខាន់ក្នុងការបង្កឲ្យមានការកែតម្រូវ ជាសារវន្តចំពោះតម្លៃយោង នៃទ្រព្យសកម្ម និងបំណុលក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់ ត្រូវបានបកស្រាយខាងក្រោម។

ធនាគារ ផ្អែកលើការសន្មត និងការប៉ាន់ប្រមាណរបស់ខ្លួនលើប៉ារ៉ាម៉ែត្រដែលមាននៅពេលដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំ។ ទោះជាយ៉ាងនេះក្តី កាលៈទេសៈ និងការសន្មតដែលមានស្រាប់អំពីការវិវឌ្ឍន៍នាពេលអនាគតអាចផ្លាស់ប្តូរដោយសារការផ្លាស់ប្តូរទីផ្សារ ឬ កាលៈទេសៈដែលកើតឡើងលើសពីការគ្រប់គ្រងរបស់ធនាគារ។ ការផ្លាស់ប្តូរបែបនេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការសន្មតនៅពេលដែលវាកើតឡើង។





### *(i) ពន្ធ*

ពន្ធ ត្រូវបានគណនាដោយផ្អែកលើច្បាប់ និងបទប្បញ្ញត្តិពន្ធ និងការបកស្រាយបច្ចុប្បន្នរបស់វា។ ទោះជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាំងនេះមានការប្រែប្រួលតាមកាលកំណត់ ហើយការកំណត់ចុងក្រោយនៃការចំណាយពន្ធ នឹងត្រូវធ្វើឡើងបន្ទាប់ពីការត្រួតពិនិត្យដោយអគ្គនាយកដ្ឋានពន្ធដារ។ ការបង់ពន្ធរបស់ធនាគារ គឺស្ថិតនៅក្រោមការត្រួតពិនិត្យតាមកាលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។ ដោយសារការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពន្ធចំពោះប្រតិបត្តិការជាច្រើនប្រភេទ គឺងាយនឹងមានការបកស្រាយផ្សេងៗគ្នា ចំនួនទឹកប្រាក់ ដែលមានក្នុងរបាយការណ៍ហិរញ្ញវត្ថុ អាចត្រូវបានផ្លាស់ប្តូរតាមការកំណត់ចុងក្រោយដោយអគ្គនាយកដ្ឋានពន្ធដារ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់សម្រាប់ការខាតបង់ពន្ធ ដែលមិនបានប្រើប្រាស់ទាំងអស់ និងភាពខុសគ្នាបណ្តោះអាសន្នចំពោះវិសាលភាពដែលវាអាចទៅរួចដែលថាប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតនឹងអាចរកបានធៀប នឹងការខាតបង់ដែលអាចប្រើប្រាស់បាន។ ការវិនិច្ឆ័យសំខាន់នៃការគ្រប់គ្រង ត្រូវបានទាមទារដើម្បីកំណត់ចំនួនពន្យារលើទ្រព្យសកម្មពន្ធ ដែលអាចទទួលស្គាល់បាន ដោយផ្អែកលើពេលវេលា និងកម្រិតនៃប្រាក់ចំណូលជាប់ពន្ធនាពេលអនាគតទំនងជាកើតមានឡើង រួមជាមួយនឹងយុទ្ធសាស្រ្តរៀបចំផែនការពន្ធ នាពេលអនាគត។

### *(ii) ការបង្កើតចំនួន និងទម្ងន់ដែលទាក់ទងនៃសេណារីយ៉ូដែលឆ្ពោះទៅមុខ សម្រាប់ប្រភេទផលិតផល/ទីផ្សារនីមួយៗ និងកំណត់ព័ត៌មានឆ្ពោះទៅមុខ ដែលទាក់ទងនឹងសេណារីយ៉ូនីមួយៗ៖*

នៅក្នុងការវាស់វែង ECL ធនាគារប្រើព័ត៌មានសមហេតុផល និងអាចគាំទ្របាន ដែលផ្អែកលើការសន្មតសម្រាប់បម្រែបម្រួល នាពេលអនាគតនៃកត្តាជំរុញសេដ្ឋកិច្ចផ្សេងៗគ្នា និងរបៀបដែលកត្តាជំរុញទាំងនេះប៉ះពាល់ដល់គ្នាទៅវិញទៅមក។ កំណត់សម្គាល់លេខ ៣.២ ផ្តល់ព័ត៌មានលម្អិតបន្ថែមទាក់ទងនឹងព័ត៌មានប៉ាន់ស្មានទៅមុខ។

### *(iii) ប្រូបាប៊ីលីតេនៃការគ្មានលទ្ធភាពសង*

PD បង្កើតជាធាតុបញ្ចូលសំខាន់ក្នុងការវាស់វែង ECL។ PD គឺជាការប៉ាន់ស្មានអំពីលទ្ធភាពនៃការគ្មានលទ្ធភាពសងក្នុងរយៈពេលកំណត់ ការគណនាដែលរួមបញ្ចូលទិន្នន័យប្រវត្តិសាស្រ្ត ការសន្មត និងការរំពឹងទុក នៃលក្ខខណ្ឌនាពេលអនាគត។ កំណត់សម្គាល់លេខ ៣.២ ផ្តល់ព័ត៌មានលម្អិតបន្ថែម រួមទាំងការវិភាគអំពីភាពប្រែប្រួលនៃរបាយការណ៍ ECL ចំពោះការផ្លាស់ប្តូរនៅក្នុង PD ដែលបណ្តាលមកពីការផ្លាស់ប្តូរនៅក្នុងកត្តាជំរុញសេដ្ឋកិច្ច។

### *(iv) ការបាត់បង់ដែលបណ្តាលមកពីការគ្មានលទ្ធភាពសង ("LGD")*

LGD គឺជាការប៉ាន់ប្រមាណនៃការបាត់បង់ ដែលកើតឡើងតាមការគ្មានលទ្ធភាពសង។ វាផ្អែកលើភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលដល់ពេលកំណត់ និងអ្នកផ្តល់ឥណទាន រំពឹងថានឹងទទួលបាន ដោយគិតគូរពីលំហូរសាច់ប្រាក់ពីវត្ថុបញ្ចាំ និងការបង្កើនឥណទានរួម។ សូមមើលកំណត់សម្គាល់លេខ ៣.២ សម្រាប់ព័ត៌មានលម្អិតបន្ថែម រួមទាំងការវិភាគអំពីភាពប្រែប្រួលនៃរបាយការណ៍ ECL ចំពោះការផ្លាស់ប្តូរនៅក្នុង LGD ដែលបណ្តាលមកពីការផ្លាស់ប្តូរនៅក្នុងកត្តាជំរុញសេដ្ឋកិច្ច។

### *(v) ការប៉ាន់ស្មានអត្រាកម្ចីដែលកើនតាមកម្រិត (“IBR”)*

ធនាគារមិនអាចកំណត់អត្រាការប្រាក់ជាក់ច្បាស់នៅក្នុងភតិសន្យានេះ បានទេដូច្នេះធនាគារប្រើ IBR ដើម្បីវាស់វែងបំណុលភតិសន្យា។ IBR សម្រាប់បំណុលភតិសន្យាគឺជាអត្រា នៃការប្រាក់ ដែលធនាគារនឹងត្រូវបង់ដើម្បីខ្ចីក្នុងរយៈពេលស្រដៀងគ្នានេះហើយជាមួយនឹងទ្រព្យធានាស្រដៀងគ្នានេះ មូលនិធិចាំបាច់ដើម្បីទទួលបានទ្រព្យសកម្មនៃតម្លៃស្រដៀងគ្នាទៅនឹងទ្រព្យសកម្ម ROU នៅក្នុងស្ថានភាពសេដ្ឋកិច្ចស្រដៀងគ្នានេះ។ ធនាគារបានប៉ាន់ស្មានថា IBR សម្រាប់បំណុលភតិសន្យាដោយប្រើធាតុចូលដែលអាចសង្កេតបាន (ដោយយោងទៅលើអត្រាគ្មានហានិភ័យបច្ចុប្បន្ន) ដែលបានកែសម្រួលដើម្បីពិចារណាពីហានិភ័យឥណទានរបស់ធនាគារ។

## ៥. សាច់ប្រាក់ក្នុងដៃ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) |
| សាច់ប្រាក់ក្នុងដៃ | | | | |
| ដុល្លារអាមេរិក | ៣២៥.២២៨ | ១.៣៣៨.៩៦៤ | ២២៥.៣១៥ | ៩១៧.៩៣៣ |
| ខ្មែររៀល | ២៤៥.៥២២ | ១.០១០.៨១៤ | ១៥៩.៤១៦ | ៦៤៩.៤៦១ |
| | **៥៧០.៧៥០** | **២.៣៤៩.៧៧៨** | **៣៨៤.៧៣១** | **១.៥៦៧.៣៩៤** |

សម្រាប់គោលបំណងរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) |
| សាច់ប្រាក់ក្នុងដៃ | ៥៧០.៧៥០ | ២.៣៤៩.៧៧៨ | ៣៨៤.៧៣១ | ១.៥៦៧.៣៩៤ |
| សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា *(កំណត់សម្គាល់លេខ ៦)* | ១២.៩៧០.៣៩៨ | ៥៣.៣៩៩.១២៩ | ៣១.៥៧០.៧៦៩ | ១២៨.៦១៩.៣១៣ |
| សមតុល្យនៅធនាគារផ្សេងៗ *(កំណត់សម្គាល់លេខ ៧)* | ៣០.៥៩១.២១៩ | ១២៥.៩៤៤.០៤៨ | ៣.៣៦៩.២១៣ | ១៣.៧២៦.១៧៤ |
| | **៤៤.១៣២.៣៦៧** | **១៨១.៦៩២.៩៥៥** | **៣៥.៣២៤.៧១៣** | **១៤៣.៩១២.៨៨១** |

## ៦. សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) |
| គណនីចរន្ត | | | | |
| ដុល្លារអាមេរិក | ៥.០១២.៧៩៦ | ២០.៦៣៧.៦៨១ | ១៩.៧៧៤.០១៤ | ៨០.៥៥៩.៣៣៣ |
| ខ្មែររៀល | ៧.៩៥៧.៦០២ | ៣២.៧៦១.៤៤៨ | ១១.៧៩៦.៧៥៥ | ៤៨.០៥៩.៩៨០ |
| | **១២.៩៧០.៣៩៨** | **៥៣.៣៩៩.១២៩** | **៣១.៥៧០.៧៦៩** | **១២៨.៦១៩.៣១៣** |

គណនីចរន្ត មិនទទួលបានការប្រាក់នោះទេ។

## ៧. សមតុល្យជាមួយធនាគារផ្សេងៗ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) |
| ប្រាក់បញ្ញើចរន្ត | ៣.៣៨៦.៩៤៤ | ១៣.៩៤៤.០៤៨ | ៣.៣៦៩.២១៣ | ១៣.៧២៦.១៧៤ |
| ប្រាក់បញ្ញើមានកាលកំណត់ដើម៖ | | | | |
| បីខែ ឬ តិចជាងបីខែ | ២៧.២០៤.២៧៥ | ១១២.០០០.០០០ | - | - |
| ច្រើនជាងបីខែ | ១៩.៤៣១.៦២៥ | ៨០.០០០.០០០ | ២.៥៨៦.៩៣៩ | ១០.៥៣៩.១៨៩ |
| ការប្រាក់បង្គរត្រូវទទួល | ៤៥៥.៥៣៨ | ១.៨៧៥.៤៥១ | ៤៧.០៦១ | ១៩១.៧២៧ |
| | **៥០.៤៧៨.៣៨២** | **២០៧.៨១៩.៤៩៩** | **៦.០០៣.២១៣** | **២៤.៤៥៧.០៩០** |





*អត្រាការប្រាក់*

អត្រាការប្រាក់ប្រចាំឆ្នាំលើសមតុល្យជាមួយធនាគារផ្សេងៗ មានដូចខាងក្រោម៖

| | ២០២២ | ២០២១ |
|---|---|---|
| គណនីចរន្ត | គ្មាន | គ្មាន |
| ប្រាក់បញ្ញើមានកាលកំណត់ | ៣,៧៥% - ៤,៥០% | ១,៥០% - ៤,០០% |

## ៨. ឥណទាន និងបុរេប្រទានទៅអតិថិជន - សុទ្ធ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) |
| ឥណទានរយៈពេលវែង | ២១២.៦៣៣.៤០៥ | ៨៧៥.៤១១.៧២៨ | ១១០.៦៩៣.៥៣០ | ៤៥០.៩៦៥.៤៤១ |
| ឥណទានទៅបុគ្គលិក | ១.០៣២.១៨៧ | ៤.២៤៩.៥១៤ | ២៧៦.៩៦៩ | ១.១២៨.៣៧២ |
| ឥណទានរយៈពេលខ្លី | ៧៤៤.០៧០ | ៣.០៦៣.៣៣៦ | - | - |
| ការប្រាក់បង្គរត្រូវទទួល | ៣៨៩.៨៦៨ | ១.៦០៥.០៨៧ | ១៤០.១៥០ | ៥៧០.៩៧១ |
| ប្រាក់ដើម និងបង្គរការប្រាក់ដែលត្រូវទទួលសរុប | ២១៤.៧៩៩.៥៣០ | ៨៨៤.៣២៩.៦៦៥ | ១១១.១១០.៦៤៩ | ៤៥២.៦៦៤.៧៨៤ |
| កម្រៃឥណទាន មិនទាន់រំលស់ | (៤៧០.៩៩៣) | (១.៩៣៩.០៧៨) | - | - |
| តម្លៃយោងឥណទាន និងបុរេប្រទាន-ដុល | ២១៤.៣២៨.៥៣៧ | ៨៨២.៣៩០.៥៨៧ | ១១១.១១០.៦៤៩ | ៤៥២.៦៦៤.៧៨៤ |
| សំវិធានធនលើ ECLs | (៣.៨២៧.៦០៥) | (១៥.៧៥៨.២៥០) | (១.៧៩៨.៩៩៨) | (៧.៣២៩.១១៨) |
| **តម្លៃយោងឥណទាន និងបុរេប្រទាន- សុទ្ធ** | **២១០.៥០០.៩៣២** | **៨៦៦.៦៣២.៣៣៧** | **១០៩.៣១១.៦៥១** | **៤៤៥.៣៣៥.៦៦៦** |

ដំណាក់កាលសំវិធានលើ ECLs នៃឥណទាន និងបុរេប្រទានទៅអតិថិជនមានដូចខាងក្រោម៖

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) |
| ដំណាក់កាលទី ១ | ៣.៣៤៤.១៧៨ | ១៣.៧៦៧.៩៨១ | ១.៧៩៨.៩៩៨ | ៧.៣២៩.១១៨ |
| ដំណាក់កាលទី ២ | ២២៦.៩៣២ | ៩៣៤.២៧៩ | - | - |
| ដំណាក់កាលទី ៣ | ២៥៦.៤៩៥ | ១.០៥៥.៩៩០ | - | - |
| **សរុប** | **៣.៨២៧.៦០៥** | **១៥.៧៥៨.២៥០** | **១.៧៩៨.៩៩៨** | **៧.៣២៩.១១៨** |

បម្រែបម្រួលនៃសំវិធានធនសម្រាប់ ECL លើឥណទាន និងបុរេប្រទានមានដូចខាងក្រោម៖

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) |
| នាថ្ងៃទី៣១ ខែមករា | ១.៧៩៨.៩៩៨ | ៧.៣២៩.១១៨ | ៧៦៦.០០០ | ៣.០៩៨.៤៧០ |
| សំវិធានធនលើការខាតបង់ឥណទានរំពឹងទុក | ២.០២៨.៦០៧ | ៨.២៩០.៩១៧ | ១.០៣២.៩៩៨ | ៤.២០២.២៣៦ |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | ១៣៨.២១៥ | - | ២៨.៤១២ |
| **នាថ្ងៃទី៣១ ខែធ្នូ** | **៣.៨២៧.៦០៥** | **១៥.៧៥៨.២៥០** | **១.៧៩៨.៩៩៨** | **៧.៣២៩.១១៨** |

ការវិភាគបន្ថែមនៃឥណទាន និងបុរេប្រទានទៅអតិថិជន មានដូចខាងក្រោម៖

*(i) ដំណាក់កាលនៃផលប័ត្រឥណទានដុល*

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) |
| ដំណាក់កាលទី ១ | ២១៣.៤១៨.៥៨២ | ៨៧៨.៦៤៤.៣០២ | ១១១.១១០.៦៤៩ | ៤៥២.៦៦៤.៧៨៤ |
| ដំណាក់កាលទី ២ | ១.១២៤.៤៥៣ | ៤.៦២៩.៣៧៣ | - | - |
| ដំណាក់កាលទី ៣ | ២៥៦.៤៩៥ | ១.០៥៥.៩៩០ | - | - |
| **សរុប** | **២១៤.៧៩៩.៥៣០** | **៨៨៤.៣២៩.៦៦៥** | **១១១.១១០.៦៤៩** | **៤៥២.៦៦៤.៧៨៤** |

*(ii) បម្រែបម្រួលនៃសំវិធានធនលើការខាតបង់ឥណទាន និងបុរេប្រទាន*

| | ២០២២ | | | |
|---|---|---|---|---|
| | ដំណាក់កាលទី ១ | ដំណាក់កាលទី ២ | ដំណាក់កាលទី ៣ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| នាថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ | ១.៧៩៨.៩៩៨ | - | - | ១.៧៩៨.៩៩៨ |
| ទ្រព្យសកម្មដើមថ្មី | ២.៤៦៦.០០៨ | - | - | ២.៤៦៦.០០៨ |
| បម្រែបម្រួលពីការផ្លាស់ប្តូរដំណាក់កាល៖ | | | | |
| ទ្រព្យសកម្មដើមថ្មីផ្ទេរទៅ ដំណាក់កាលទី ២ និង ដំណាក់កាលទី ៣ | (៤៨៣.៤២៧) | ២២៦.៩៣២ | ២៥៦.៤៩៥ | - |
| ការវាស់វែងឡើងវិញនៃការខាតបង់ សំវិធានធន សុទ្ធ | (៣៨៧.៧០៨) | - | - | (៣៨៧.៧០៨) |
| ការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុង ការិយបរិច្ឆេទ ដោយមិនរាប់បញ្ចូលការលុបចោល | (៤៩.៦៩៣) | - | - | (៤៩.៦៩៣) |
| **សំវិធានធនលើ ECL** | **៣.៣៤៤.១៧៨** | **២២៦.៩៣២** | **២៥៦.៤៩៥** | **៣.៨២៧.៦០៥** |
| **ពាន់រៀល (កំណត់សម្គាល់លេខ ២.៣)** | **១៣.៧៦៧.៩៨១** | **៩៣៤.២៧៩** | **១.០៥៥.៩៩០** | **១៥.៧៥៨.២៥០** |

| | ២០២១ | | | |
|---|---|---|---|---|
| | ដំណាក់កាលទី ១ | ដំណាក់កាលទី ២ | ដំណាក់កាលទី ៣ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| នាថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ | ៧៦៦.០០០ | - | - | ៧៦៦.០០០ |
| ទ្រព្យសកម្មដើមថ្មី | ១.១៧៩.៧១៤ | - | - | ១.១៧៩.៧១៤ |
| បម្រែបម្រួលពីការផ្លាស់ប្តូរដំណាក់កាល៖ | | | | |
| ការវាស់វែងឡើងវិញនៃការខាតបង់ សំវិធានធន សុទ្ធ | (១២៩.៧២១) | - | - | (១២៩.៧២១) |
| ការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងការិយបរិច្ឆេទ ដោយមិនរាប់បញ្ចូល ការលុបចោល | (១៦.៩៩៥) | - | - | (១៦.៩៩៥) |
| **សំវិធានធនលើ ECL** | **១.៧៩៨.៩៩៨** | **-** | **-** | **១.៧៩៨.៩៩៨** |
| **ពាន់រៀល (កំណត់សម្គាល់លេខ ២.៥)** | **៧.៣២៩.១១៨** | **-** | **-** | **៧.៣២៩.១១៨** |

*(iii) យោងទៅកំណត់សម្គាល់លេខ ២៨.២ ស្តីពីហានិភ័យឥណទានសម្រាប់ការវិភាគ នៃគុណភាពឥណទាន។*

*(iv) យោងទៅកំណត់សម្គាល់លេខ ២៨.២ ស្តីពីហានិភ័យឥណទានសម្រាប់ការវិភាគនៃឥណទាន តាមកាលកំណត់ វិស័យ រូបិយប័ណ្ណ វត្ថុធានា និវាសនភាព ទំនាក់ទំនង និងហានិភ័យ*

*(v) តាមអត្រាការប្រាក់ (ប្រចាំឆ្នាំ)៖*

| | ២០២២ | ២០២១ |
|---|---|---|
| អត្រាការប្រាក់ | ២,០០% - ៨,៥០% | ២,០០% - ៧,៥០% |

## ៩. ទ្រព្យសកម្មផ្សេងៗ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ លេខ ២.៣) |
| បុរេប្រទាន និងប្រាក់បង់មុន | ១០០.១៤៣ | ៤១២.២៨៩ | ៤៤.៩៨៦ | ១៨៣.២៧៣ |
| ប្រាក់កក់ធានា | ៥១.៥៤៧ | ២១២.២១៩ | - | - |
| ផ្សេងៗ | ៣១.២៤៩ | ១២៨.៦៥១ | ៨.៤៦៩ | ៣៤.៥០៣ |
| | **១៨២.៩៣៩** | **៧៥៣.១៥៩** | **៥៣.៤៥៥** | **២១៧.៧៧៦** |

## ១០. ទ្រព្យសកម្មអរូបិយ

| | ២០២២ | | | |
|---|---|---|---|---|
| | កម្មវិធីកុំព្យូទ័រ | កម្មវិធីកុំព្យូទ័រ កំពុងដំណើរការ | ទ្រព្យសកម្ម អរូបិយផ្សេងៗ | សរុប |
